សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# ការលែងលះនៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា ម៉េង ដាណេ**

**កញ្ញា ហុង ស៊ីវម្លួយ**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ប៊្លួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំឈ្មោះ **ម៉េង ដាណេ** និងនាងខ្ញុំឈ្មោះ **ហុង ស៊ីវម្លួយ** ជានិស្សិតជំនាន់ទី១៤ ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ មហាវិទ្យាល័យរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ៖

១. លោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើតដល់កូន ព្រមទាំងពុះពាររាល់ឧបសគ្គ ការនឿយហត់ទាំងឡាយ ក្នុងការចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងសព្វគ្រប់បែបយ៉ាង អប់រំទូន្មានប្រៀនប្រដៅ និងលើកទឹកចិត្តដល់កូនឱ្យកូនក្លាយទៅជាកូនល្អ និស្សិតល្អ និងពលរដ្ឋល្អសម្រាប់សង្គមជាតិទាំងមូល។ ដោយសារតែការយកចិត្តទុកដាក់ និងការខិតខំប្រឹងប្រែងរបស់លោកទាំងពីរ ទើបធ្វើឱ្យកូនឈានដល់ថ្ងៃនេះ គឺថ្ងៃដែលកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្របានជោគជ័យ។

២. **ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំលះបង់ ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងការដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀនដល់យើងខ្ញុំនូវមេរៀនទាក់ទងក្នុងវិស័យរដ្ឋបាល និងស្ថានភាពសង្គមជាក់ស្តែង។ ជាពិសេស

ឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ បានផ្តល់ដំបូន្មានដល់យើងខ្ញុំយ៉ាងច្រើនដែលជាទុនក្នុងការស្រាវជ្រាវ និងតាក់តែងបង្កើតស្នាដៃនេះឡើង ។

៣. **លោកស្រី ម៉ិួយ ធីតា** ដែលជាគ្រូណែនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលលោកបានប្រឹងប្រែងមិនខ្លាចនឿយហត់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ក្នុងការណែនាំ និងជួយជ្រោមជ្រែង ផ្តល់គំនិតយោបល់ ហើយជួយកែសម្រួលរាល់កំហុសឆ្គងក្នុងការសរសេរសារណាមួយនេះឡើង។

៤. ម្យ៉ាងវិញទៀត យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ សិស្សច្បង មិត្តភក្តិរួមជំនាន់ និងបងប្អូននិស្សិតទាំងអស់ដែលបានជួយផ្តល់ជាគំនិតល្អៗ ជួយពិនិត្យ ព្រមទាំងបានជួយកែសម្រួលនូវអក្ខរាវិរុទ្ធ និងការប្រើប្រាស់ពាក្យពេចន៍យ៉ាងច្រើន នៅក្នុងសៀវភៅសារណាមួយនេះ ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរសូមឱ្យវត្ថុស័ក្តសិទ្ធិទាំងឡាយក្នុងលោកតាមថែរក្សាការពារ និងប្រសិទ្ធពរជ័យសិរីសួស្តីជូនដល់អស់លោកទាំងអស់ ដែលបានរៀបរាប់ខាងលើសូមឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ កាយសម្បទារឹងមាំ អាយុយឺនយូរ និងទទួលជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

បន្ទាប់ពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈអស់រយៈពេល ០៤ ឆ្នាំកន្លងមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនរួចមក យើងខ្ញុំទាំងពីរ បានទទួលនូវចំណេះដឹងទូលំទូលាយលើមុខវិជ្ជាទាំងអស់នោះ ក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់មកដល់ពួកយើងខ្ញុំ។ ដោយការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយ កម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យយើងខ្ញុំអាចឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ។ ការរៀបចំសរសេរសារណានេះឡើង ក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈជំនាន់ទី ១៤ នេះ និងដើម្បីចូលរួមចំណែកនៅក្នុងសង្គម។ ការសរសេរសារណា ត្រូវតម្រូវឱ្យយើងមានសមត្ថភាព និងចំណេះដឹងខ្ពស់ក្នុងការចងក្រងវាឡើងមក ព្រោះការចងក្រងសារណាមួយឡើងមក យើងត្រូវជួបប្រទះនូវការលំបាកជាច្រើន ទើបយើងអាចទទួលបាននូវលទ្ធផលល្អ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ គឺក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទមួយដែលមានចំណងជើងថា "**ការលែងលះនៅកម្ពុជាបច្ចុប្បន្ន**"។ ការជ្រើសរើសប្រធានបទនេះឡើងមក គឺដើម្បីឱ្យបុគ្គល ដែលមានបញ្ហាក្នុងចំណងអាពាហ៍ពិពាហ៍ មានភាពរកាំរកូស មានភាពមិនចុះសម្រុងក្នុងគ្រួសារ ហើយមានបំណងផ្តាច់ចំណងអាពាហ៍ពិពាហ៍នោះឱ្យជ្រាបច្បាស់អំពីនីតិវិធីនៃការលែងលះ ការបែងចែកទ្រព្យសម្បត្តិ និងការផ្តល់អាហារកាតព្វកិច្ចជាដើម។

យើងខ្ញុំសង្ឃឹមថាសារណានេះនឹងអាចជាជំនួយក្នុងការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត និងប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលចង់ស្វែងយល់បន្ថែមទាក់ទងនឹងការលែងលះ ហើយនឹងទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមឱ្យកាន់តែច្បាស់អំពីនីតិវិធីក្នុងការលែងលះក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់ចំនុចខ្វះខាតមួយចំនួនដូចជា ពាក្យពេចន៍ ខ្លឹមសារអត្ថន័យ ឬអក្ខរាវិរុទ្ធទាំងឡាយ ដែលមានក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា។ ហើយក្រុមយើងខ្ញុំ នឹងទទួលស្វាគមន៍ជានិច្ចនូវរាល់ការិះគន់ក្នុងន័យស្ថាបនាជាមួយនឹងគំនិតយោបល់ល្អៗផ្សេងៗ របស់មិត្តអ្នកអានទាំងអស់ដើម្បីធ្វើការកែលម្អនឹងធ្វើឱ្យល្អប្រសើរជាងមុន។

# មាតិកា

ទំព័រ

**តារាងសម្គាល់ពាក្យកាត់** ....iv

**សេចក្តីផ្តើម** ....១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការលែងលះ**

**១.១. និយមន័យនៃការលែងលះ** ....៣

**១.២. លក្ខខណ្ឌដែលអាចលែងលះបាន** ....៣

**១.៣. មូលហេតុនៃការលែងលះចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧** ....៤

១.៣.១. ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ ....៤

១.៣.២. ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ ....៥

១.៣.៣. ការបាត់ដំណឹងរបស់សហព័ទ្ធអស់រយៈពេលជាង ០១ (មួយ) ឆ្នាំ ដោយមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ ....៥

១.៣.៤. ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ (មួយឆ្នាំ) ....៦

១.៣.៥. ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយមិនអាចបដិទានវិញបាន ....៧

**១.៤. មូលហេតុដែលមិនអាចលែងលះបាន** ....៧

១.៤.១. ការលែងលះដែលប៉ះពាល់ទៅដល់ការទ្រទ្រង់ជីវភាព ឬការឈឺចាប់របស់សហព័ទ្ធ ឬ កូន ....៧

១.៤.២. ការលែងលះដោយមានគំនិតទុច្ចរិត ....៨

**១.៥. ប្រភេទនៃការលែងលះ** ....៨

១.៥.១. ការលែងលះដោយគ្មានការព្រមព្រៀងគ្នា ....៨

១.៥.២. ការលែងលះដោយការព្រមព្រៀង ....៩

**ជំពូកទី២**

**ការលែងលះដោយការព្រមព្រៀង**

**២.១. នីតិវិធីនៃការលែងលះដោយការព្រមព្រៀង** ....១០

២.១.១. ពាក្យសុំលែងលះ ....១០

២.១.១.១. ពាក្យសុំលែងលះជាលាយលក្ខណ៍អក្សរ ....១០

២.១.១.២. ពាក្យសុំលែងលះដោយផ្ទាល់មាត់ ........ ១២
២.១.២.សមត្ថកិច្ចដោះស្រាយ ........ ១២
២.១.២.១. ឃុំ-សង្កាត់ ........ ១២
២.១.២.២. សាលាដំបូងរាជធានីខេត្ត ........ ១៣
២.១.៣. ការសម្រេចសេចក្តី ........ ១៦
២.១.៣.១. អំពីដីកាសម្រេច ........ ១៦
២.១.៣.២. ការជូនដំណឹងអំពីដីកាសម្រេច ........ ១៧
២.១.៣.៣. ការចូលជាស្ថាពរនៃដីកាសម្រេច ........ ១៧
**២.២. អានុភាពនៃការលែងលះដោយការព្រមព្រៀង** ........ ១៧
២.២.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត ........ ១៧
២.២.១.១. ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ ........ ១៧
២.២.១.២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ ........ ១៨
២.២.២. សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ ........ ១៨
២.២.២.១. សិទ្ធិបន្សល់ក្រោយការលែងលះ ........ ១៨
២.២.២.២. កាតព្វកិច្ចបន្សល់ក្រោយការលែងលះ ........ ២១
**ជំពូកទី៣**
**ការលែងលះដោយគ្មានការព្រមព្រៀង**
**៣.១. នីតិវិធីបណ្តឹងលែងលះ** ........ ២៣
៣.១.១. ការផ្តើមនៃបណ្តឹងលែងលះ ........ ២៣
៣.១.១.១. ការសរសេរពាក្យបណ្តឹង ........ ២៣
៣.១.១.២. ការដាក់ពាក្យបណ្តឹង ........ ២៤
៣.១.១.៣. ការទទួលពាក្យបណ្តឹង ........ ២៥
៣.១.១.៤. ការពិនិត្យ និងការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ........ ២៦
៣.១.២. ការចាត់ចែងរក្សាការពារ ........ ២៧
៣.១.២.១. វិធានការដាក់ឱ្យសហព័ទ្ធរស់នៅបែកគ្នាជាបណ្តោះអាសន្ន ........ ២៧
៣.១.២.២. វិធានការដាក់ឱ្យមានការថែរក្សាកូនជាបណ្តោះអាសន្ន ........ ២៨
៣.១.២.៣. វិធានការទាក់ទងទៅនឹងការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ........ ២៨

៣.១.២.៤. វិធានការទាក់ទងនឹងការផ្គត់ផ្គង់សហព័ទ្ធ ឬកូនជាបណ្ដោះអាសន្ន ....................២៩

៣.១.២.៥. ការរឹបអូសជាបណ្ដោះអាសន្ន ....................................................................៣០

**៣.២. នីតិវិធីនៃការជម្រះក្ដី** ....................................................................................៣០

៣.២.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ....................................................៣០

៣.២.១.១. ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ..........................៣០

៣.២.១.២. ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................៣១

៣.២.១.៣. ការរៀបចំអះអាងចំណុចវិវាទ ....................................................................៣១

៣.២.១.៤. ការរៀបចំពិនិត្យភស្តុតាង ........................................................................ ៣២

៣.២.២. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ........................................................ ៣៣

៣.២.២.១. ការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............ ៣៣

៣.២.២.២. ការពិនិត្យភស្តុតាងដោយសមូហវិធី .............................................................៣៤

**៣.៣. ការសម្រេចសេចក្ដី** ......................................................................................៣៥

៣.៣.១.សាលក្រមលែងលះ ....................................................................................៣៥

៣.៣.២.ទម្រង់នៃសាលក្រមលែងលះ ....................................................................... ៣៧

៣.៣.៣. ការប្រកាសសាលក្រម ................................................................................ ៣៧

៣.៣.៤. ការចូលជាស្ថាពរនៃសាលក្រម .....................................................................៣៨

**៣.៤. អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង** ...............................................៣៨

៣.៤.១. ការកាត់ផ្ដាច់ទំនាក់ទំនងគតិយុត្ត ...................................................................៣៨

៣.៤.២. សិទ្ធិ និងកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះ ..........................................៣៨

៣.៤.២.១. សិទ្ធិដែលបន្សល់ទុកក្រោយការលែងលះ ......................................................៣៨

៣.៤.២.២. កាតព្វកិច្ចដែលបន្សល់ទុកក្រោយការលែងលះ ............................................... ៤១

**សេចក្ដីសន្និដ្ឋាន** ..............................................................................................៤៣

**អនុសាសន៍** ...................................................................................................... ៤៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# តារាងសម្គាល់ពាក្យកាត់

| | | | |
|---|---|---|---|
| ១. | រដ្ឋធម្មនុញ្ញ | ៖ | រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ |
| ២. | ក្រមរដ្ឋប្បវេណី | ៖ | ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់ ដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងអនុវត្តទូទាំងប្រទេសនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ |
| ៣. | ក្រមនីតិវិធីរដ្ឋប្បវេណី | ៖ | ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់ ដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ |
| ៤. | ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧ | ៖ | ច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារពីដែលប្រកាសឱ្យប្រើ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩ |
| ៥. | ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ | ៖ | ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ |
| ៦. | ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ | ៖ | ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ |
| ៧. | អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន | ៖ | អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ |

# សេចក្តីផ្តើម

គ្រួសារ គឺជាកោសិកាដ៏សំខាន់សម្រាប់សង្គម។ មនុស្សនៅក្នុងសង្គមជាតិមួយតែងតែរមែងមានគូគាប់ និងបង្កើតបានជាគ្រួសារដែលជាក្រឹត្យក្រមនៃច្បាប់ធម្មជាតិ។ តាំងពីយូរទម្រាំងណាស់មកហើយ នៅប្រទេសកម្ពុជា គ្រួសារនីមួយៗត្រូវបានបង្កើតឡើងតាមរយៈអាពាហ៍ពិពាហ៍តាមលក្ខណៈទំនៀមទម្លាប់ប្រពៃណី។ រហូតមកដល់ប្រទេសកម្ពុជាទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិលឡ ការរៀបអាពាហ៍ពិពាហ៍ត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩២០ បន្ទាប់មកទៀតមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ និងបច្ចុប្បន្នមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ការរៀបអាពាហ៍ពិពាហ៍តាមបែបប្រពៃណីទំនៀមទម្លាប់ គឺគ្រាន់តែជាការរក្សា អភិរក្ស និងប្រតិបត្តិនូវអរិយធម៌ ដ៏មានតម្លៃរបស់ប្រទេសកម្ពុជាតាំងពីបុរាណកាលមកដល់បច្ចុប្បន្នប៉ុណ្ណោះ។ ដោយឡែកនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើង មានបញ្ញត្តិអំពីនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍តាមច្បាប់។ អាពាហ៍ពិពាហ៍តាមច្បាប់ សំដៅលើការបង្ហាញឆន្ទៈក្នុងការបង្កើតចំណងគតិយុត្តចងភ្ជាប់រូបវន្តបុគ្គលឱ្យក្លាយទៅជាសហព័ទ្ធស្របច្បាប់ តាមរយៈការចុះសំបុត្រអាពាហ៍ពិពាហ៍។ ចំពោះបុរស និងនារីណាដែលជាគូនឹងគ្នា ដែលមានបំណងរួមរស់នៅជាមួយគ្នាជាគូអនាគត ហើយគិតថាមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវគោរពលក្ខខណ្ឌគតិយុត្តបង្កើតអាពាហ៍ពិពាហ៍។ ការបង្កើតអាពាហ៍ពិពាហ៍ដែលអាចទទួលស្គាល់ថាត្រឹមត្រូវតាមច្បាប់ គឺត្រូវអនុវត្តតាមនីតិវិធីដូចកំណត់ក្នុងច្បាប់ជាធរមាន មានដូចជាត្រូវបំពេញលក្ខខណ្ឌសារធាតុ ដូចជាបុរស និងនារីដល់នីតិភាព មានឆន្ទៈពិតប្រាកដក្នុងការបង្កើតកិច្ចសន្យាអាពាហ៍ពិពាហ៍ ដាក់ពាក្យសុំនៅមន្ត្រីអត្រានុកូលដ្ឋានឃុំ-សង្កាត់ខាងស្រី បិទផ្សាយជាសាធារណៈ ១០ (ដប់) ថ្ងៃ មុនរៀបអាពាហ៍ពិពាហ៍ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ទើបអាពាហ៍ពិពាហ៍នោះមានអានុភាពតាមផ្លូវច្បាប់។ ជាចុងក្រោយមន្ត្រីអត្រានុកូលដ្ឋាននៃលំនៅឋានខាងស្រីដែលបានចុះបញ្ជីរួច ត្រូវចេញសំបុត្រអាពាហ៍ពិពាហ៍ដល់គូស្វាមីភរិយានោះ។ ហេតុនេះហើយ ការរំលាយអាពាហ៍ពិពាហ៍ គឺមិនអាចធ្វើបានតាមទំនើងចិត្តបានឡើយ គឺត្រូវធ្វើតាមផ្លូវតុលាការ ព្រោះថាបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ ប្តី និងប្រពន្ធ មានចំណងគតិយុត្តជាច្រើនកើតឡើងរវាងគ្នា ជាអាទិ៍ ទំនាក់ទំនងនៃឋានៈបុគ្គល និងទំនាក់ទំនងទ្រព្យ។

គ្រប់គូ និងក្រុមគ្រួសារទាំងអស់ សុទ្ធតែប្រាថ្នាចង់បានការរស់នៅប្រកបដោយសុភមង្គល និងភាពសុខដុមរមនា។ ទំនាក់ទំនងទាំងឡាយ ដែលកើតឡើងតាមរយៈការរៀបអាពាហ៍ពិពាហ៍ គ្មាននរណាម្នាក់ដែលចង់ផ្តាច់ឡើយ។ ប៉ុន្តែជួនកាលការរស់នៅជាមួយគ្នាជាជីវិតប្តីប្រពន្ធ ជីវិតគ្រួសារមានការផ្លាស់ប្តូរ ឬមានជួបប្រទះបញ្ហាដូចជាសហព័ទ្ធណាម្ខាងផិតក្បត់ បាត់ដំណឹងពីផ្ទះ បោះបង់ចោលគ្នា រស់នៅបែកគ្នាអស់រយៈពេល

យូរ ឬអស់មនោសញ្ចេតនានឹងមិនអាចរួមរស់ជាមួយគ្នាតទៅទៀត។ ហេតុនេះផ្លូវមួយដែលអាចបញ្ចប់ការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ និងបញ្ចប់បញ្ហាទាំងឡាយឱ្យស្របច្បាប់បានគឺការលែងលះ។ ប្រសិនបើ ប្ដី និងប្រពន្ធមានវិវាទគ្នាក្នុងគ្រួសារ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើការបដិទានឡើងវិញ ឬអស់មនោសញ្ចេតនារស់នៅជាមួយគ្នាជាប្ដីប្រពន្ធហើយនោះ ពួកគេអាចរំលាយចំណងអាពាហ៍ពិពាហ៍របស់ខ្លួនវិញបាន ដោយវិធីនៃការលែងលះតាមផ្លូវតុលាការ។ តើការលែងលះជាអ្វី? តើមូលហេតុអ្វីខ្លះអាចបណ្ដាលឱ្យមានការលែងលះ? តើសមត្ថកិច្ចណាដែលអាចដោះស្រាយរឿងលែងលះ? តើបន្ទាប់ពីលែងលះមានបញ្ហាប្រឈមអ្វីខ្លះ?

ដោយសង្កេតឃើញថា ការលែងលះគឺជាបញ្ហាប្រឈមដែលកើតស្ទើរជារៀងរាល់ថ្ងៃ ហើយការលែងលះមានលក្ខណៈស្មុគស្មាញ និងការលែងលះជាចម្ងល់របស់ពលរដ្ឋក្នុងសង្គម អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាយើងទាំងពីរ ទើបនាំឱ្យមានការស្រាវជ្រាវប្រធានបទ "ការលែងលះនៅប្រទេសកម្ពុជាបច្ចុប្បន្ន" នេះឡើង។

ប្រធានបទ **ការលែងលះនៅប្រទេសកម្ពុជាបច្ចុប្បន្ន** នេះមានវិសាលភាពគ្របដណ្ដប់ទៅលើសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ដែលបានបំពេញគ្រប់លក្ខខណ្ឌ និងនីតិវិធីបង្កើតអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ហើយចំណុចដែលត្រូវលើកយកមកសិក្សាគឺ ប្រភេទនៃការលែងលះ មូលហេតុនៃការលែងលះ នីតិវិធីនៃការលែងលះ និងអានុភាពនៃការលែងលះដែលស្ថិតនៅក្រោមវិសាលភាពនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ ច្បាប់ស្ដីពីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០ ដែលកំពុងអនុវត្តសព្វថ្ងៃប៉ុណ្ណោះ។

ដើម្បីឆ្លើយតបទៅនឹងភាពស្មុគស្មាញនៃការលែងលះ និងដើម្បីទទួលបានមូលដ្ឋានមួយក្នុងការអនុវត្តដំណើរការនីតិវិធីនៃការលែងលះប្រកបដោយភាពត្រឹមត្រូវតាមច្បាប់នាពេលបច្ចុប្បន្ន ដូចបានលើកឡើងខាងលើប្រធានបទសារណាស្ដីពី **ការលែងលះនៅប្រទេសកម្ពុជា** ត្រូវបានបែងចែកជា ០៣ (បី) ជំពូក ដែលមានខ្លឹមសារដូចខាងក្រោម៖

**ជំពូកទី១ ៖ សញ្ញាណទូទៅនៃការលែងលះ**

**ជំពូកទី២ ៖ ការលែងលះដោយការព្រមព្រៀង**

**ជំពូកទី៣ ៖ ការលែងលះដោយគ្មានការព្រមព្រៀង**

# ជំពូកទី១

# សញ្ញាណទូទៅនៃការលែងលះ

ការរៀបអាពាហ៍ពិពាហ៍ គឺមានសារៈសំខាន់ណាស់ចំពោះសង្គមកម្ពុជា។ អាពាហ៍ពិពាហ៍ គឺជាចំណងផ្លូវច្បាប់ ដោយអាពាហ៍ពិពាហ៍ជាកិច្ចសន្យាមួយបែប ដែលមិនដូចកិច្ចសន្យាដទៃទៀតក៏ដោយ ក៏ភាគីមិនអាចរំលាយអាពាហ៍ពិពាហ៍តាមទំនើងចិត្តបានទេ។ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ[1]។ ដូចនេះអាពាហ៍ពិពាហ៍ជាការប្តេជ្ញាមួយ ដែលបានកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងពីរនាក់ប្តីនិង ប្រពន្ធ។ ផ្ទុយទៅវិញ ការរស់នៅជាមួយគ្នាជា ជីវិតប្តីប្រពន្ធតែងមានការជួបប្រទះបញ្ហា ដោយសារភាពមិនចុះសម្រុងគ្នា ជាហេតុបណ្តាលឱ្យគ្រួសារបែកបាក់គ្នាដែលឈានរហូតដល់ការលែងលះ។ ដូចនេះភាគីទាំងពីរនាក់ ប្តី និងប្រពន្ធត្រូវរកសមត្ថកិច្ច ដើម្បីដោះស្រាយដែលមានតែតុលាការទេដែលអាចសម្រេចរឿងលែងលះបាន។

## ១.១. និយមន័យនៃការលែងលះ

ការលែងលះ គឺជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយស្របច្បាប់។ ជាក់ស្តែងនិយមន័យពាក្យថាលែងលះនេះមិនមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលចូលជាធរមាននោះឡើយ។ ប៉ុន្តែយោងតាមមាត្រា ៣៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧ បានឱ្យនិយមន័យពាក្យនេះថា ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់ ក្នុងពេលដែលប្តីប្រពន្ធនៅមានជីវិតទាំងពីរនាក់។

## ១.២. លក្ខខណ្ឌដែលអាចលែងលះបាន

ការលែងលះអាចធ្វើបានតាមផ្លូវតុលាការ លុះត្រាតែភាគីនៃបណ្តឹង គឺជាសហព័ទ្ធដែលមានអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដែលអ្នកទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន[2]។ អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ គឺជាមូលដ្ឋានចម្បងដែលធ្វើឱ្យសហព័ទ្ធមានទំនាក់ទំនងគតិយុត្តរវាងគ្នា និងអាចបង្កើតជាក្រុមគ្រួសារជាមួយគ្នាបានតាមក្បួនច្បាប់។ អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍បានដើរតួជាលក្ខខណ្ឌគ្រឹះនៅក្នុងរឿងក្តីនៃការលែងលះ ដោយហេតុថានៅពេលដំណើរការដោះស្រាយរឿងក្តីលែងលះ តុលាការតែងតែបង្គាប់ឱ្យសហព័ទ្ធផ្តល់នូវសំបុត្រអាពាហ៍ពិពាហ៍ ដើម្បី

[1] មាត្រា៣ នៃច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩

[2] មាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ធ្វើការពិនិត្យ។ ក្នុងករណីដែលសហព័ទ្ធមិនបានផ្តល់តាមការបង្គាប់នេះទេ តុលាការនឹងមិនជឿថាមានអង្គហេតុនៃការបង្កើតចំណងគតិយុត្តឡើយ ដូច្នេះពាក្យបណ្តឹងឬពាក្យសុំនឹងត្រូវបានច្រានចោលដោយដីកាសម្រេច។ ហេតុនេះដើម្បីរំលាយចំណងអាពាហ៍ពិពាហ៍ជាដំបូងសហព័ទ្ធ គឺត្រូវមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដែលជាមូលដ្ឋាននៃការដាក់ពាក្យបណ្តឹងលែងលះ។ មានន័យថាអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ ត្រូវបញ្ជាក់ដោយសំបុត្រអាពាហ៍ពិពាហ៍ដែលចេញ ដោយមន្ត្រីអត្រានុកូលដ្ឋានតាមការស្នើសុំពីសហព័ទ្ធទាំងពីរដូចនេះសហព័ទ្ធណាម្ខាងអាចធ្វើការដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបាន ដើម្បីឱ្យតុលាការធ្វើការសម្រេចបាន។ បន្ថែមពីនេះទៅទៀតនោះ ចំពោះពាក្យបណ្តឹងលែងលះ ត្រូវមានមូលហេតុត្រឹមត្រូវដូចដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រង់មាត្រា ៩៧៨។

## ១.៣. មូលហេតុនៃការលែងលះចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ការលែងលះដោយពុំមានការព្រមព្រៀង ត្រូវមានមូលហេតុដែលចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា ៩៧៨ កថាខណ្ឌទី១ រួមមានដូចជា ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ ការបាត់ដំណឹងរបស់សហព័ទ្ធអស់រយៈពេលជាង ០១ (មួយ) ឆ្នាំ ដោយមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់ ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ (មួយ) ឆ្នាំ និងករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានវិញបាន។

### ១.៣.១. ការប្រព្រឹត្តអំពើផិតក្បត់ទៅលើសហព័ទ្ធ

អំពើផិត គឺជាអំពើដែលសហព័ទ្ធម្ខាងមានចំណងអាពាហ៍ពិពាហ៍ ហើយមានចំណងផ្លូវភេទ (រួមសមគ្គសង្វាស) ជាមួយបុគ្គលដែលមិនមែនជាសហព័ទ្ធរបស់ខ្លួន[3]។ ក្នុងករណីនេះសហព័ទ្ធ ដែលទទួលរងនូវអំពើផិតក្បត់ពីសហព័ទ្ធម្ខាងទៀត អាចទាមទារឱ្យលែងលះបាន។

ឧទាហរណ៍ៈ លោក A ជាប្តី បានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី B ជាប្រពន្ធ។ ០២ (ពីរ) ឆ្នាំក្រោយមក លោក A បានមានសម្ព័ន្ធភាពផ្លូវភេទជាមួយនារី C ដែលជាស្រីខារ៉ាអូខេ។ លោកស្រី B បានដឹងរឿងនេះគាត់មានការឈឺចាប់យ៉ាងខ្លាំង និងលែងចង់រួមរស់ជាមួយលោក A តទៅទៀត។ ក្នុងករណីនេះ លោកស្រី B អាចសុំលែងលះជាមួយលោក A ដោយមូលហេតុបានប្រព្រឹត្តិអំពើផិត[4]។

ការអះអាងដើម្បីលែងលះដោយយកអំពើផិតរបស់សហព័ទ្ធមកធ្វើជាមូលហេតុ សហព័ទ្ធដែលទាមទារឱ្យលែងលះត្រូវបញ្ជាក់អំពីអង្គហេតុនៃការផិត ដូចជា ការថតរូប ឬ វីឌីអូ ដែលបង្ហាញពីទំនាក់ទំនងផ្លូវភេទរបស់សហព័ទ្ធម្ខាងទៀត ឬអង្គហេតុប្រហាក់ប្រហែលដែលអាចវាយតម្លៃបានថាមានអំពើផិត ដូចជា ការចាកចេញពី

[3] មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦

[4] ចំណុច ក នៃកថាខណ្ឌទី១ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី

បន្ទប់សណ្ឋាគារជាមួយគ្នាដោយមានភាពល្អក់ល្អិនជាដើម។ ហេតុនេះ ប្រសិនបើភាគី ដែលទាមទារឱ្យលែងលះ មិនអាចបង្ហាញថាមានអំពើផិតទេ តុលាការនឹងមិនសម្រេចឱ្យលែងលះនោះទេ។ នៅក្នុងការអនុវត្តជាក់ស្តែង ករណីលែងលះដោយមានមូលហេតុការប្រព្រឹត្តអំពើផិតនេះ មានចំនួនច្រើនជាងមូលហេតុផ្សេងៗទៀត។ ប៉ុន្តែ បើទោះបីជាសហព័ទ្ធដែលទាមទារលែងលះគ្មានភស្តុតាងបញ្ជាក់អំពីអំពើផិតក៏ដោយ ក៏តុលាការនៅតែសម្រេច ឱ្យលែងលះគ្នាបានដែរ ដោយយល់ឃើញថាការបង្ខំឱ្យរួមរស់នៅជាមួយគ្នាពុំមានលទ្ធផលល្អឡើយ ពេលខ្លះ បង្កឱ្យមានអំពើហិង្សាកើតឡើងថែមទៀតផង។

### ១.៣.២. ការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវ

ការបោះបង់សហពទ្ធ័ចោលដោយគ្មានមូលហេតុត្រឹមត្រូវ គឺជាការដែលសហព័ទ្ធមិនរួមរស់ជីវភាពជាមួយគ្នា សហការគ្នា សង្គ្រោះគ្នាទៅវិញទៅមក និងគ្មានឆន្ទៈបន្តជីវភាពរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៀតឡើយ[5]។

ឧទាហរណ៍ ៖ លោក A ជាប្តី និងលោកស្រីB ជាប្រពន្ធ បានឈ្លោះប្រកែកទាស់ទែងគ្នា។ A បានប្រមូល ទ្រព្យសម្បត្តិទាំងអស់ចាកចេញទៅនៅកន្លែងផ្សេងអស់រយៈពេលជាង ០១ (មួយ) ឆ្នាំហើយ។ ករណីនេះក៏ត្រូវ បានរាប់បញ្ចូលជាការបោះបង់ចោលសហព័ទ្ធដោយគ្មានមូលហេតុត្រឹមត្រូវដែរ។

### ១.៣.៣. ការបាត់ដំណឹងរបស់សហព័ទ្ធអស់រយៈពេលជាង ០១ (មួយ) ឆ្នាំ ដោយមិនដឹងថាសហព័ទ្ធស្លាប់ ឬរស់

ករណីដែលមិនដឹងថា សហព័ទ្ធស្លាប់ ឬរស់ អស់រយៈពេលជាង ១(មួយ) ឆ្នាំ គឺជាករណីដែលសហព័ទ្ធម្ខាង មិនបានទទួលដំណឹងអំពីសហព័ទ្ធម្ខាងទៀត ហើយមិនដឹងថាសហព័ទ្ធនោះ ស្លាប់ ឬរស់។

ឧទាហរណ៍ ៖ លោក A ជាប្តីរបស់លោកស្រី B។ លោក A បានចេញពីផ្ទះនៅថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៧ ដោយមិនបានត្រឡប់មកវិញអស់រយៈពេលជាង ០១ (មួយ) ឆ្នាំហើយ។ នៅក្នុងករណីនេះ លោកស្រី B ជា ប្រពន្ធអាចទាមទារឱ្យលែងលះបាន។

តើអំឡុងពេលជាង ០១ (មួយ) ឆ្នាំ ត្រូវគណនាគិតចាប់ពីពេលណា?

អំឡុងពេលជាង ០១ (មួយ) ឆ្នាំ ត្រូវគណនាដោយផ្អែកលើមាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ លោក A ជាប្តី បានចាកចេញពីផ្ទះនៅថ្ងៃ០១ ខែឧសភា ឆ្នាំ២០១៧ ហើយក៏បាត់ដំណឹងសូន្យមិនដឹងថា ស្លាប់ ឬ រស់ឡើយ។ ការបាត់ដំណឹងនេះ មានអំឡុងពេលជាង ០១ (មួយ) ឆ្នាំហើយ បើគិតចាប់ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៧ រហូតដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨។ ប៉ុន្តែប្រសិនបើសហព័ទ្ធ ដែលបានបាត់ពីផ្ទះជួបប្រទះក្នុង គ្រោះថ្នាក់ដូចជា ធ្លាក់យន្តហោះជាដើម ហើយគេមិនដឹងថា ស្លាប់ ឬរស់ នោះអំឡុងពេល ០១ (មួយ) ឆ្នាំ ត្រូវ បកស្រាយថាគិតចាប់ពីថ្ងៃដែលមានគ្រោះថ្នាក់នោះកើតឡើង។ ដូចនេះសហព័ទ្ធម្ខាងទៀត អាចដាក់ពាក្យសុំ

[5] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រកាសបាត់ខ្លួន ហើយតុលាការនឹងសម្រេចអំពីការប្រកាសអំពីការបាត់ខ្លួនតាមការស្នើសុំរបស់សហព័ទ្ធម្ខាងទៀតនៃជនរងគ្រោះបាន ដោយគ្រាន់តែបង្ហាញភស្តុតាងដែលអាចបញ្ជាក់អំពីស្ថានភាពដែលបាត់ដំណឹងអំពីសហព័ទ្ធដោយមិនដឹងថាស្លាប់ឬរស់អស់រយៈពេលជាង ០១ ឆ្នាំនោះគ្រប់គ្រាន់ដើម្បីលែងលះ។

ស្ថានភាពដែលមានបញ្ញត្តិនៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ខុសគ្នាអំពីស្ថានភាពបាត់ខ្លួនដែលមានបញ្ញត្តិនៅក្នុងមាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ការបាត់ខ្លួនដែលមានបញ្ញត្តិនៅក្នុងមាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺជាការរំលាយចំណងអាពាហ៍ពិពាហ៍ដោយមានមូលហេតុមរណភាព ពីព្រោះការបាត់ខ្លួនដែលត្រូវបានប្រកាសដោយតុលាការ មានអានុភាពស្មើនឹងមរណភាព។ ប៉ុន្តែការបាត់ខ្លួនដែលអនុលោមតាមបញ្ញត្តិនៃមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺជាការរំលាយចំណងអាពាហ៍ពិពាហ៍ដោយមូលហេតុលែងលះ និងមិនតម្រូវឱ្យមាននីតិវិធីប្រកាសពីបាត់ខ្លួននោះទេ ពោលគឺភាគីដែលទាមទារឱ្យលែងលះនោះ គ្រាន់តែបង្ហាញភស្តុតាងដែលអាចបញ្ជាក់អំពីស្ថានភាពដែលបាត់ដំណឹងរបស់សហព័ទ្ធដោយមិនដឹងថា ស្លាប់ ឬរស់ អស់រយៈពេលជាង ០១ (មួយ) ឆ្នាំ នោះគឺគ្រប់គ្រាន់ដើម្បីលែងលះ។

### ១.៣.៤. ការរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ (មួយឆ្នាំ)

ការរស់នៅបែកគ្នារបស់រយៈពេលជាង ០១ (មួយ) ឆ្នាំ គឺជាស្ថានភាពនៃការរស់នៅបែកផ្ទះគ្នាដោយមិនរួមរស់ជាមួយគ្នា ដូចជាប្ដី និងប្រពន្ធ ដែលមានលក្ខណៈផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។ ក្នុងករណីដែលប្ដី ប្រពន្ធ រស់នៅបែកគ្នា ប៉ុន្តែមានការរួមរស់ជាមួយគ្នា (សម្ព័ន្ធភាពផ្លូវភេទ) ទោះបីជាតិច ឬច្រើនក៏ដោយ មិនចាត់ទុកថាជាការរស់នៅបែកគ្នាដែលមានបញ្ញត្តិនៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នោះទេ ពីព្រោះថាថ្វីត្បិតតែរស់នៅបែកគ្នា ប៉ុន្តែពុំបានផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍នោះទេ។ ផ្ទុយទៅវិញ ប្រសិនបើប្ដី ប្រពន្ធរស់នៅបែកផ្ទះគ្នា ហើយប្ដីប្រពន្ធពុំមានសម្ព័ន្ធភាពផ្លូវភេទជាមួយគ្នា ទោះបីជាសហព័ទ្ធនោះត្រឡប់មកផ្ទះម្ដងម្កាលក៏ដោយ ក៏ត្រូវចាត់ទុកថាជាការរស់នៅបែកគ្នាដូចមានបញ្ញត្តិក្នុងចំណុច ឃ នៃកថាខណ្ឌទី១ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ដែរ។

ឧទាហរណ៍ៈ លោក A ជាប្ដី បានឈ្លោះប្រកែកទាស់ទែងគ្នា ជាមួយលោកស្រី B ដែលជាប្រពន្ធ។ លោក A បានចាកចេញពីផ្ទះមករស់នៅផ្ទះរបស់ឪពុកម្ដាយគាត់។ នៅពេលចុងសប្ដាហ៍លោក A បានត្រឡប់មកផ្ទះម្ដង ក្នុងគោលបំណងមកមើលកូន ហើយលែងមានសម្ព័ន្ធភាពផ្លូវភេទជាមួយ B ដែលជាប្រពន្ធចាប់ពីពេលនោះមក។ ក្នុងករណីនេះ B ជាប្រពន្ធ អាចទាមទារឱ្យលែងលះបាន។

### ១.៣.៥. ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ មិនអាចបដិទានវិញបាន

ក្រៅពីមូលហេតុដែលច្បាប់បានកំណត់ច្បាស់លាស់ខាងលើ នៅមានមូលហេតុជាច្រើនទៀតដែលច្បាប់មិនបានចែងលម្អិត។ ច្បាប់មានគោលបំណងទុកអំណាចឆន្ទានុសិទ្ធិដល់ចៅក្រម ជាអ្នកសម្រេចទៅលើអង្គហេតុនៃការលែងលះដទៃទៀត ដែលមានលក្ខណៈជាកំហុសឆ្គងធ្ងន់ធ្ងរ រហូតដល់មិនអាចអត់ឱនឱ្យបាន ឬមានមូលហេតុដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងរទៅដល់ភាគីម្ខាងទៀត។ កំហុសឆ្គងដែលអាចចាត់ទុកថាមានលក្ខណៈធ្ងន់ធ្ងរមានដូចជា ការជេរប្រមាថ ការប្រើអំពើហិង្សា ការប្រព្រឹត្តបទល្មើស ការមិនធ្វើការងារដោយគ្មានមូលហេតុត្រឹមត្រូវ ការចំណាយប្រាក់ខ្ជះខ្ជាយ ការជំពាក់បំណុលដែលគ្មានមូលហេតុត្រឹមត្រូវ ជំងឺធ្ងន់ធ្ងរជាអាទិ៍ ដែលបណ្ដាលឱ្យមានការបែកបាក់នឹងមិនអាចបដិទានវិញបានទេ ផ្អែកលើស្ថានភាពទាំងអស់នេះក្នុងករណីមានការបែកបាក់កើតឡើង ហើយមិនអាចបដិទានវិញបាន វាអាចក្លាយជាមូលហេតុនៃការលែងលះ។

## ១.៤. មូលហេតុដែលមិនអាចលែងលះបាន

ច្បាប់បានកំណត់ពីមូលហេតុនៃការលែងលះ ហើយស្របគ្នានេះដែរ ច្បាប់ក៏បានកំណត់ពីមូលហេតុដែលប្រឆាំងមិនឱ្យមានការលែងលះគ្នាដែរ។ ការលែងលះនឹងមិនអាចប្រព្រឹត្តទៅបាននោះទេ ប្រសិនបើតុលាការពិនិត្យឃើញថាមានភាពមិនប្រក្រតីនៃបណ្ដឹងលែងលះនោះ ហើយអានុភាពនៃការលែងលះនឹងនាំមកនូវហានិភ័យធ្ងន់ធ្ងរទៅលើសហព័ទ្ធម្ខាងទៀត។ ស្របគ្នានេះដែរ ប្រសិនបើតុលាការនៅតែអនុញ្ញាតឱ្យសហព័ទ្ធលែងលះគ្នានោះវាគឺជាកំហុសឆ្គងដ៏ធ្ងន់ធ្ងរមួយរបស់តុលាការ។ ដូចនេះមុននឹងតុលាការអនុញ្ញាតឱ្យលែងលះតុលាការគប្បីគិតគូរថ្លឹងថ្លែងឱ្យច្បាស់លាស់ប្រកបដោយវិចារណញ្ញាណអំពីផលល្អ និងផលអាក្រក់ពីការលែងលះ។

### ១.៤.១. ការលែងលះដែលប៉ះពាល់ទៅដល់ការទ្រទ្រង់ជីវភាព ឬការឈឺចាប់របស់សហព័ទ្ធ ឬ កូន

ទោះបីជាមានមូលហេតុលែងលះត្រឹមត្រូវដូចច្បាប់បានកំណត់ច្បាស់យ៉ាងណាក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាអានុភាពនៃការបែកបាក់គ្នានោះនឹងបណ្ដាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬ កូនមានការក្រលំបាកតោកយ៉ាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលមិនអាចទ្រាំទ្របាន តុលាការអាចច្រានចោលការទាមទារលែងលះគ្នាបានដោយពិចារណាទៅស្ថានភាពទាំងឡាយបាន[6]។

ដូចនេះ ប្រសិនបើចៅក្រមអនុញ្ញាតឱ្យមានការលែងលះគ្នាបានហាក់បីដូចជា ទម្លាក់បន្ទុកនៃភាពក្រីក្រមកលើគ្រួសារ ប្រទេសជាតិ និងដើរតាមការគេចវេសពីកាតព្វកិច្ចក្នុងការខិតខំរកទទួលទានចិញ្ចឹមជីវិតរបស់សហព័ទ្ធម្ខាងទៀត និងកូន។

[6] កថាខណ្ឌទី២ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

#### ១.៤.២. ការលែងលះដោយមានគំនិតទុច្ចរិត

ទោះបីជាមូលហេតុនៃការលែងលះដូចបានកំណត់នៅក្នុងចំណុចខាងលើនេះ ការរស់នៅ បែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ០១ (មួយ) ឆ្នាំ ដែលមានការផ្ទុយពីគោលបំណងអាពាហ៍ពិពាហ៍ ឬមានករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានក៏ដោយ ប្រសិនបើតុលាការ យល់ឃើញថាការទាមទារនោះផ្ទុយនឹងសុច្ចរិតភាព ដោយជនដែលទាមទារឱ្យលែងលះគ្នាធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងសហប្រតិបត្តិការជួយសង្គ្រោះចំពោះសហព័ទ្ធតុលាការអាចច្រានចោលការទាមទារលែងលះគ្នាដោយឆន្ទានុសិទ្ធិបាន[7]។ ការកំណត់បែបនេះពិតជាត្រឹមត្រូវ ព្រោះវាបានបង្ហាញពីភាពល្អិតល្អន់របស់ច្បាប់ ក្នុងគោលបំណងការពារកុំឱ្យមានជនខិលខូចមួយចំនួនអាចលើកយកនូវបញ្ហានេះ ឬបញ្ហានោះដើម្បីទាមទារឱ្យបាននូវការលែងលះ ដើម្បីតែសម្រេចបាននូវផលប្រយោជន៍របស់ខ្លួន ពោលគឺគំនិតអាត្មានិយមរបស់បុគ្គលទាំងអស់នោះ។

ក្រៅពីមូលហេតុនៃការលែងលះ និងមូលហេតុបដិសេធចំពោះការលែងលះដូចដែលបានលើកឡើងខាងលើ ដើម្បីឱ្យមានការលែងលះមួយស្របច្បាប់ គឺទាមទារនូវការប្រតិបត្តិរបស់សហព័ទ្ធនីមួយៗ ចំពោះការអនុវត្តច្បាប់ជាធរមាន។ ដូចនេះគូវិវាទគួរគប្បីយល់ពីនីតិវិធីក្នុងការលែងលះគ្នាផងដែរ ទើបអាចឱ្យមានការជឿទុកចិត្តច្បាស់អំពីអានុភាពនៃសាលក្រមលែងលះ ដោយមិនចាំបាច់ភ័យខ្លាចក្រែងរាល់ទង្វើរបស់ភាគីម្ខាងទៀតនោះទេ ព្រោះថាកាលណាដើរតាមនីតិវិធីច្បាប់ គឺច្បាប់នឹងការពារសុចរិតជនជាក់ជាមិនខាន។

### ១.៥. ប្រភេទនៃការលែងលះ

ការលែងលះមានពីរប្រភេទគឺ ការលែងលះដោយពុំមានការព្រមព្រៀង (១.៥.១) និងការលែងលះដោយការព្រមព្រៀង (១.៥.២)។

#### ១.៥.១. ការលែងលះដោយគ្មានការព្រមព្រៀងគ្នា

ការលែងលះដោយពុំព្រមព្រៀង ឬការលែងលះតាមបណ្តឹង គឺជាទាមទារឱ្យលែងលះដោយឆន្ទៈរបស់ភាគីម្ខាងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយផ្អែកលើមូលហេតុដែលកំណត់ដោយច្បាប់ ហេតុនេះក្នុងករណីពុំមានមូលហេតុដូចបានកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធនឹងមូលហេតុនៃការលែងលះទេនោះ តុលាការក៏មិនអាចសម្រេចឱ្យលែងលះបានដែរ។ ការលែងលះតាមបណ្តឹង ភាគីទាមទារឱ្យលែងលះត្រូវទទួលបន្ទុកបញ្ជាក់នូវអង្គហេតុនីមួយៗ ដែលជាមូលហេតុនៃការលែងលះដើម្បីឱ្យតុលាការសម្រេចឱ្យលែងលះ ហេតុនេះយើងឃើញថាការលែងលះតាមបណ្តឹង គឺមានភាពស្មុគស្មាញជាងការលែងលះដោយការព្រមព្រៀង។ លើសពីនេះទៅទៀត

[7] កថាខណ្ឌទី៣ នៃមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នៅក្នុងការលែងលះតាមបណ្ដឹង ភាគីអាចធ្វើការទាមទារបានច្រើនចំណុចជាងការលែងលះដោយការព្រមព្រៀង ដូចជាការទាមទារសំណងនៃការខូចខាត ការទាមទារអាហារកាតព្វកិច្ច ដែលចំណុចនេះមិនអាចទាមទារបានទេនៅក្នុងការលែងលះដោយការព្រមព្រៀង ។

**១.៥.២. ការលែងលះដោយការព្រមព្រៀង**

ការលែងលះដោយមានការព្រមព្រៀង គឺជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយមានការព្រមព្រៀងគ្នាពីភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍នោះ ប៉ុន្តែតុលាការអាចឱ្យលែងលះគ្នាបាន ក្រោយពីបានយល់ឃើញថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហពិពាហ៍។ ការលែងលះដោយមានការព្រមព្រៀង គឺត្រូវធ្វើឡើងដោយពាក្យសុំទៅតុលាការ ហើយតុលាការសម្រេចសេចក្ដីក្រោមរូបភាពជាដីកាសម្រេច។

ដូចដែលបានសិក្សារួចមកហើយថាការលែងលះអាចប្រព្រឹត្តទៅបាន លុះត្រាតែគូស្វាមីភរិយាដែលមានបំណងរំលាយអាពាហ៍ពិពាហ៍នោះជាគូស្វាមីភរិយានីតិសង្វាស។ ហើយវិធីដែលអាចលែងលះគ្នាមានពីរប្រភេទ គឺព្រមព្រៀងគ្នា និងមិនមានការព្រមព្រៀងគ្នា។ យើងនឹងបន្តសិក្សាលម្អិតអំពីនីតិវិធី ក៏ដូចជាអានុភាពនៃការលែងលះជាបន្ត។

# ជំពូកទី២

# ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀងត្រូវបានកំណត់នៅក្នុងមាត្រា ៣ កថាខណ្ឌទី១ នៃតារាងឧបសម្ព័ន្ធត្រង់ចំណុចទី ៥ ផ្នែកទី ៤ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ហេតុនេះចំពោះការលែងលះដោយការព្រមព្រៀងគ្នាត្រូវប្រព្រឹត្តទៅតាមច្បាប់នេះ។ ការលែងលះដោយការព្រមព្រៀង ត្រូវធ្វើឡើងនៅពេលដែលភាគីនៃអាពាហ៍ពិពាហ៍ បានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ដោយមិនមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយលែងលះឡើយ។ ក្នុងរឿងក្តីនៃការលែងលះដោយការព្រមព្រៀងមានតែភាគីប្តីប្រពន្ធទេដែលជាអ្នកចាប់ផ្តើមដំណើរការនីតិវិធីដោះស្រាយ តាមរយៈការដាក់ពាក្យសុំទៅតុលាការ មិនមែនជារឿងក្តីដែលតុលាការអាចចាប់ផ្តើមនីតិវិធីបណ្តឹងដោយឆន្ទានុសិទ្ធិឡើយ។

តើភាគីអាចទាមទារអ្វីខ្លះបាន នៅក្នុងនីតិវិធីលែងលះដោយការព្រមព្រៀង? តើការលែងលះដោយការព្រមព្រៀងមាននីតិវិធីបែបណាខ្លះ? តើពាក្យសុំត្រូវសរសេរចំណុចអ្វីខ្លះ?

## ២.១. នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

### ២.១.១. ពាក្យសុំលែងលះ

នីតិវិធីនៃការលែងលះដោយការព្រមព្រៀង គឺត្រូវបានចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ភាគីណាមួយទៅតុលាការ ហើយដើម្បីឱ្យពាក្យសុំមួយមានសុពលភាព ហើយត្រូវបានតុលាការចាត់ចែងតាមនីតិវិធីបានលុះត្រាតែពាក្យសុំនោះ ត្រូវបានសរសេរទៅតាមទម្រង់ដែលច្បាប់បានកំណត់ បើមិនដូច្នេះទេពាក្យសុំដែលបានដាក់រួចហើយទាមទារឱ្យធ្វើការកែតម្រូវជាថ្មីម្តងទៀត ឬ ជាមូលហេតុនៃការលើកពាក្យសុំចោល។ ជនដាក់ពាក្យសុំអាចដាក់ពាក្យសុំលែងលះគ្នា ជាលាយលក្ខណ៍អក្សរ (២.១.១.១) និងដោយផ្ទាល់មាត់ (២.១.១.២) បានផងដែរ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត[8] ។

#### ២.១.១.១. ពាក្យសុំលែងលះជាលាយលក្ខណ៍អក្សរ

យោងតាមបញ្ញត្តិកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយនៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ៖

-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់[9]៖ ប្តី ឬប្រពន្ធ ដែលយកពាក្យសុំមកដាក់ត្រូវសរសេរឈ្មោះ ភេទ អាយុ សញ្ជាតិ

[8] កថាខណ្ឌទី ១ នៃមាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[9] ចំណុច ក នៃកថាខណ្ឌទី២ នៃមាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

និងត្រូវបានសរសេរអាសយដ្ឋាននៅក្នុងពាក្យសុំ។ ប៉ុន្តែប្រសិនបើមានអ្នកតំណាងដោយអាណត្តិ ដែលច្បាប់បានកំណត់ ត្រូវសរសេរឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិនោះនៅក្នុងពាក្យសុំផងដែរ។ ភាគី គឺជាចំណុចមួយដែលទាមទារឱ្យមានការបញ្ជាក់ច្បាស់លាស់ ហើយភាគីជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតនៃពាក្យសុំ ដូច្នេះការកំណត់ឱ្យបាននូវឈ្មោះរបស់ភាគី អាចបញ្ចៀសបាននូវការភាន់ច្រឡំទៅលើបុគ្គលផ្សេងទៀតដែលគ្មានការពាក់ព័ន្ធជាមួយពាក្យសុំ។ ដើម្បីជៀសវាងនូវការភាន់ច្រឡំ ប្រសិនបើជារូបវន្តបុគ្គលត្រូវសរសេរឈ្មោះជននោះព្រមទាំងអាសយដ្ឋាន ហើយបើជានីតិបុគ្គលត្រូវសរសេរនាមករណ៍ និងទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បងនៅក្នុងពាក្យសុំនោះ។ មូលហេតុដែលចាំបាច់សរសេរបញ្ជាក់ឱ្យបានច្បាស់លាស់ ដោយសារតែតាមរយៈការសរសេរបញ្ជាក់នៅក្នុងលិខិតពាក្យសុំ អាចកំណត់បានច្បាស់លាស់ថាតើជនណាជាភាគីអ្នកដាក់ពាក្យសុំ ឬជាភាគីម្ខាងទៀតនៃពាក្យសុំ ងាយស្រួលសម្រាប់ធ្វើការបញ្ជូន ផ្ញើពាក្យសុំ និងឯកសារផ្សេងៗទៀត ហើយជាពិសេសគឺអានុភាពនៃដីកាសម្រេច ដែលចេញដោយតុលាការនឹងមានទៅលើអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ហើយចងភាគីនោះ។

-ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកពាក្យសុំទាមទារ[10] ៖ ជាកម្មវត្ថុនៃការវិនិច្ឆ័យ និងការសម្រេចសេចក្តីក្នុងបណ្តឹងរដ្ឋប្បវេណី ហើយក៏ជាការកម្រិតព្រំដែននៃការសម្រេចសេចក្តីរបស់តុលាការផងដែរ ដែលការទាមទារឱ្យតុលាការចេញមានដូចជា ការបែងចែកទ្រព្យសម្បត្តិ ការបែងចែកកូន ការទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ការប្រាស្រ័យទាក់ទងកូន ជាអាទិ៍។

-អង្គហេតុដែលជាមូលហេតុនៃការទាមទារ[11]៖ គឺសរសេរពីមូលដ្ឋានគតិយុត្តនៃការទាមទាររបស់ភាគី។ នៅក្នុងរឿងក្តីនៃរឿងលែងលះដោយការព្រមព្រៀង មូលដ្ឋានគតិយុត្តនៃការទាមទារមានដូចជា ការលែងលះ ការចាត់ចែងចំពោះកូន ការចាត់ចែងចំពោះទ្រព្យសម្បត្តិ។ ការលែងលះ គឺជាអង្គហេតុ ដែលអាចទាមទារឱ្យលែងលះបាន ពោលគឺអង្គហេតុ នៃការកើតឡើងចំណងអាពាហ៍ពិពាហ៍ ដែលបញ្ជាក់តាមសំបុត្រអាពាហ៍ពិពាហ៍ និងអង្គហេតុ នៃការបង្ហាញឆន្ទៈព្រមព្រៀងលែងលះដូចជាកិច្ចព្រមព្រៀង ឬការអះអាងរបស់គូភាគី។ រីឯការចាត់ចែងចំពោះកូន គឺជាអង្គហេតុដែលអាចទាមទារតុលាការចាត់ចែងចំពោះកូន ពោលគឺអង្គហេតុដែលបញ្ជាក់ថាចំណងអាពាហ៍ពិពាហ៍ បានបង្កើតបានកូន ដែលអាចបញ្ជាក់ដោយសំបុត្រកំណើតរបស់កូន។ លើសពីនេះទៀត ការចាត់ចែងទ្រព្យសម្បត្តិ គឺជាអង្គហេតុ ដែលអាចទាមទារឱ្យមានការចាត់ចែងទ្រព្យសម្បត្តិ ពោលគឺអង្គហេតុ

[10] ចំណុច ខ នៃកថាខណ្ឌទី២ នៃមាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[11] ចំណុច ខ នៃកថាខណ្ឌទី២ នៃមាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

ដែលបញ្ជាក់ពីការមានទ្រព្យសម្បត្តិរួមគ្នា ដែលអង្គហេតុនេះអាចបញ្ជាក់ដោយឯកសារនានាដូចជា ប័ណ្ណសម្គាល់សិទ្ធិម្ចាស់អចលនវត្ថុ ឬលិខិតម្ចាស់យានយន្ត ជាអាទិ៍។

### ២.១.១.២. ពាក្យសុំលែងលះដោយផ្ទាល់មាត់

យោងតាមបញ្ញត្តិមាត្រា ២៦ កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ពាក្យសុំអាចធ្វើឡើងដោយផ្ទាល់មាត់បានផងដែរ ហើយដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលមានកំណត់ក្នុងកថាខណ្ឌទី ២ នៅមុខក្រឡាបញ្ជី នៅក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ។ ម្យ៉ាងវិញទៀត នៅក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ[12]។

ជាការអនុវត្តជាក់ស្តែងជួនកាលនៅពេលដាក់ពាក្យសុំ ភាគីអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ក៏បានរៀបចំកិច្ចព្រមព្រៀងលែងលះ ឬកិច្ចសន្យាលែងលះគ្នាជាមុន ភ្ជាប់មកជាមួយពេលដាក់ពាក្យសុំផងដែរ។ កិច្ចព្រមព្រៀងលែងលះ គឺជាលិខិតមួយដែលបញ្ជាក់អំពីឆន្ទៈរបស់សហព័ទ្ធទាំងសងខាងថា ខ្លួនពិតជាមានបំណងដោយពិតប្រាកដក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍ ដោយមិនមានការបង្ខិតបង្ខំពីភាគីណាម្ខាងឡើយ។ ជាទូទៅនៅក្នុងកិច្ចព្រមព្រៀងលែងលះ ភាគីច្រើនសរសេរបញ្ជាក់អំពីឆន្ទៈរបស់គូភាគីក្នុងការព្រមព្រៀងលែងលះ ការបែងចែកសិទ្ធិអំណាចមេបាលើកូន ការកំណត់អំពីការជួបប្រាស្រ័យទាក់ទងកូន និងការបែងចែកទ្រព្យសម្បត្តិរួមជាអាទិ៍។ គួរបញ្ជាក់ផងដែរថា ចំណុចនេះ ពុំមែនជាលក្ខខណ្ឌតម្រូវក្នុងការដាក់ពាក្យសុំនោះទេ ព្រោះថាតុលាការអាចធ្វើការកោះហៅគូភាគី ហើយដំណើរការនូវនីតិវិធីសាកសួរ ដើម្បីបញ្ជាក់ពីឆន្ទៈរបស់គូភាគីបាន។

## ២.១.២.សមត្ថកិច្ចដោះស្រាយ

### ២.១.២.១. ឃុំ-សង្កាត់

ចំពោះការលែងលះដោយការព្រមព្រៀង គូភាគីអាចដាក់ពាក្យសុំទៅតុលាការតែម្តង ឬដាក់ពាក្យសុំទៅសាលាឃុំសង្កាត់ ដែលមានសមត្ថកិច្ចសិនក៏បាន[13]។ អាជ្ញាធរឃុំ-សង្កាត់ មិនមានសិទ្ធិអំណាចក្នុងការសម្រេចអនុញ្ញាតឱ្យប្តីប្រពន្ធលែងលះគ្នាបានទេ ពោលអាជ្ញាធរឃុំ-សង្កាត់ មានសមត្ថកិច្ចត្រឹមតែផ្សះផ្សាគូភាគីនៃចំណងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។ បន្ទាប់ពីទទួលបានពាក្យសុំនោះ អាជ្ញាធរឃុំ-សង្កាត់មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ

[12] កថាខណ្ឌទី ៤ នៃមាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[13] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្នុងការផ្សះផ្សាសហព័ទ្ធទាំងសងខាង[14]។ ក្នុងករណីផ្សះផ្សាមិនបានសម្រេច នោះក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យសុំលែងលះទៅតុលាការដែលមានសមត្ថកិច្ច[15]។

**២.១.២.២. សាលាដំបូងរាជធានីខេត្ត**

សាលាជម្រះក្តី ដែលមានសមត្ថកិច្ចលើរឿងក្តីលែងលះដោយការព្រមព្រៀង គឺតុលាការនៃលំនៅដ្ឋានប្តីឬប្រពន្ធ[16]។ នៅក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបានដោយសារច្បាប់ ឬហេតុការណ៍ពិត ឬករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនពិតប្រាកដ នោះសមត្ថកិច្ចនៃតុលាការ ត្រូវកំណត់ដោយតុលាការកំពូលដោយដីកាសម្រេចតាមពាក្យសុំ[17]។ សេចក្តីសម្រេចរបស់តុលាការកំពូល គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា[18]។ ប្រសិនបើតុលាការដែលទទួលពាក្យសុំ យល់ឃើញថា រឿងក្តីនោះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្តីនេះទៅតុលាការដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ[19]។ ពាក្យសុំនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់ពីមូលហេតុផងដែរ។ ក្នុងករណីដែលមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការ ដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះ ត្រូវជាតុលាការដែលមានសមត្ថកិច្ច[20]។ លើសពីនេះទៀតសមត្ថកិច្ចតុលាការ ត្រូវកំណត់យកនៅពេលដាក់ពាក្យសុំ[21] មានន័យថា តុលាការដែលដាក់ពាក្យសុំ គឺជាតុលាការដែលមានសមត្ថកិច្ច ទោះបីជានៅពេលក្រោយភាគីបានប្តូរលំនៅដ្ឋានក៏ដោយ ក៏តុលាការនៅពេលដាក់ពាក្យសុំនៅតែមានសមត្ថកិច្ចដដែរ។

**ក.ការពិនិត្យពាក្យសុំ**

ពាក្យសុំលែងលះ ត្រូវដាក់នៅក្នុងការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិកប្រចាំតុលាការ។ បន្ទាប់ពីទទួលពាក្យសុំ មន្ត្រីរដ្ឋបាលនឹងធ្វើការបញ្ជូនពាក្យសុំនោះទៅកាន់ក្រឡាបញ្ជី ហើយក្រឡាបញ្ជីគឺត្រូវធ្វើការពិនិត្យ ហើយធ្វើការចុះលេខលើសំណុំរឿងដែលបានទទួលនោះ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យសុំនោះមិនត្រឹមត្រូវតាមទម្រង់នៃច្បាប់ដែលបានកំណត់ទេនោះ គឺត្រូវរាយការណ៍ជូនចៅក្រមដើម្បីឱ្យចៅក្រមសម្រេចថា តើត្រូវ

[14] កថាខណ្ឌទី២ នៃមាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[15] កថាខណ្ឌទី២ នៃមាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[16] តារាងឧបសម្ព័ន្ធត្រង់ផ្នែកកថាខណ្ឌ៤ ចំណុចទី៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[17] កថាខណ្ឌទី១ នៃមាត្រា៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[18] កថាខណ្ឌទី២ នៃមាត្រា៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[19] កថាខណ្ឌទី១ នៃមាត្រា១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[20] កថាខណ្ឌទី២ នៃមាត្រា១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[21] កថាខណ្ឌទី២ នៃមាត្រា៤ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

បង្គាប់ឱ្យកែតម្រូវ ឬលើកពាក្យសុំចោល(ដីកាសម្រេច)។ ផ្ទុយមកវិញប្រសិនបើពិនិត្យឃើញថាពាក្យសុំនោះមានត្រឹមត្រូវតាមទម្រង់នៃច្បាប់បានកំណត់ហើយ ដូច្នេះក្រឡាបញ្ជីត្រូវបញ្ជូនពាក្យសុំនោះទៅចៅក្រម ដើម្បីសម្រេចបើកការជំនុំជម្រះ។ គួរបញ្ជាក់ផងដែរក្នុងការដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធលើពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល[22]។ ចំណែកឯប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធគឺ ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ[23]។ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ គឺជាប្រាក់ប្រដាប់ក្ដីតុលាការ ដែលភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការ ដូចជាការកំណត់ចាំបាច់សម្រាប់ការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយសម្រាប់ធ្វើដំណើរ ស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជី ក្នុងការពិនិត្យភស្តុតាងស្រាវជ្រាវអង្គហេតុសាកសួរភាគី ដែលប្រព្រឹត្តនៅក្រៅតុលាការ[24]។ ចំពោះសកម្មភាពដែលត្រូវបង់ប្រាក់ប្រដាក់ក្ដីនេះ តុលាការនឹងធ្វើការបង្គាប់ឱ្យភាគីអ្នកដាក់ពាក្យសុំ ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី បង់ប្រាក់តាមចំនួន ដែលតុលាការបានកំណត់នោះជាមុន[25]។ ក្នុងករណីដែលតុលាការបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីជាមុន ហើយសាមីខ្លួនមិនបានបង់ជាមុននោះទេ តុលាការនឹងលើកចោលពាក្យសុំដោយដីកាសម្រេច[26]។

**ខ. ការកោះហៅគូភាគី**

ជាគោលការណ៍ តុលាការត្រូវធ្វើការកំណត់កាលបរិច្ឆេទកោះហៅគូភាគីឱ្យចូលមកតុលាការ ដើម្បីដំណើរការនីតិវិធីនៃការលែងលះគ្នា។ ក្រៅពីការដាក់ពាក្យសុំ ភាគីត្រូវតែចូលមកបង្ហាញខ្លួនជានិច្ច នៅពេលមានការកោះហៅរបស់តុលាការ។ ប្រសិនបើភាគីមិនបានបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចធ្វើការផាកពិន័យជាប្រាក់បាន ដោយការពិន័យនេះមិនលើសពី ១.០០០.០០០ (មួយលាន) រៀលទេ[27]។ ការកោះហៅធ្វើឡើងក្នុងគោលបំណង ដើម្បីឱ្យអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ធ្វើការអះអាងជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ឬដើម្បីប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ឬភាគីម្ខាងទៀត ឬជនផ្សេងទៀតដែលតុលាការយល់ថាចាំបាច់។

[22] កថាខណ្ឌទី១ នៃមាត្រា២២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[23] កថាខណ្ឌទី៣ នៃមាត្រា២២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[24] កថាខណ្ឌទី១ នៃមាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[25] កថាខណ្ឌទី៣ នៃមាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[26] កថាខណ្ឌទី៤ នៃមាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[27] កថាខណ្ឌទី២ នៃមាត្រា២៩ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

### គ. ការសាកសួរដោយឆន្ទានុសិទ្ធិ

យោងតាមបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ដើម្បីចេញដីកាសម្រេចអំពីរឿងក្ដី ដែលកំណត់ក្នុងកថាខណ្ឌទី១ មាត្រា (វិសាលភាពនៃច្បាប់នេះ) តុលាការពុំចាំបាច់ធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឡើយ[28]។ ក្នុងករណីដែលតុលាការមិនធ្វើនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់នោះ ដូចនេះតុលាការអាចធ្វើការសាកសួរអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត[29]បាន ដើម្បីឱ្យគូភាគីធ្វើការអះអាងបញ្ជាក់ឱ្យកាន់តែច្បាស់ពីនូវឆន្ទៈព្រមព្រៀង របស់ខ្លួនលើគ្រប់បញ្ហាដែលបានធ្វើការទាមទារ។ ការសាកសួរនេះ ពុំចាំបាច់ត្រូវតែមានវត្តមានរបស់ភាគីទាំងសងខាងឡើយ[30]។

បន្ថែមពីនេះទៀត ការសាកសួរ ក្រៅពីការផ្ដល់វេទិកាដល់ភាគីឱ្យបញ្ជាក់ឱ្យកាន់តែច្បាស់លាស់នូវឆន្ទៈព្រមព្រៀងរបស់ខ្លួន លើគ្រប់បញ្ហាដែលបានទាមទារ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ឬធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិផងដែរ[31] មានន័យថាក្នុងការដឹកនាំនីតិវិធីនេះ តុលាការមិនឈរលើគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី ដូចការអនុវត្តក្នុងនីតិវិធីបណ្ដឹងធម្មតាឡើយ ពោលគឺតុលាការអាចលើកយកអង្គហេតុដែលភាគីមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបានផងដែរ[32]។

លើសពីនេះទៅទៀត ក្នុងករណីដែលយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន[33]។

ម្យ៉ាងទៀត ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ក៏បានអនុញ្ញាតឱ្យតំណាងអយ្យការចូលរួមក្នុងនីតិវិធី តាមរយៈការជូនដំណឹងរបស់តុលាការ ឬចូលរួមដោយឯកឯង ប្រសិនបើរឿងក្ដីមានការពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ[34]។

---

[28] កថាខណ្ឌទី១ នៃមាត្រា២៨ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[29] កថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[30] សេចក្ដីកំណត់មាត្រា២៨ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[31] កថាខណ្ឌទី២ នៃមាត្រា២៧ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[32] កថាខណ្ឌទី១ នៃមាត្រា២៧ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[33] កថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

[34] មាត្រា៣០ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងឆ្នាំ២០១០

### ២.១.៣. ការសម្រេចសេចក្តី

#### ២.១.៣.១. អំពីដីកាសម្រេច

ក្នុងករណីដែលចៅក្រមយល់ឃើញថា ការព្រមព្រៀងលែងលះ កើតចេញពីឆន្ទៈពិតប្រាកដរបស់គូភាគី ដោយគ្មានវិការៈក្នុងការបង្ហាញឆន្ទៈនោះ តុលាការនឹងសម្រេចឱ្យគូភាគីលែងលះ[35]។ ផ្ទុយទៅវិញ បើតុលាការយល់ឃើញថា ភាគីទាំងសងខាងមិនមានបំណងពិតប្រាកដក្នុងការផ្តាច់ចំណងអាពាហ៍ពិពាហ៍ទេ តួយ៉ាងដូចជាការលែងលះក្លែងក្លាយ ជាអាទិ៍ តុលាការ នឹងមិនអនុញ្ញាតឱ្យគូភាគីលែងលះគ្នាឡើយ[36]។ ក្នុងករណីដែលតុលាការសម្រេចឱ្យគូភាគីលែងលះគ្នានោះ តុលាការត្រូវសម្រេចសេចក្តីលើពាក្យសុំនោះដោយដីកាសម្រេច។ ដីកាសម្រេចឱ្យលែងលះតាមការព្រមព្រៀង ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវមានសំអាងហេតុ និងសរសេរសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខា លើសេចក្តីសម្រេចនោះផងដែរ[37]។ ដីកាសម្រេចនេះ អាចប្តឹងជំទាស់បានតាមបញ្ញត្តិនៃមាត្រា ៣៩ នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង ហើយដីកាសម្រេចនេះមានអានុភាពអនុវត្តដោយបង្ខំ[38]។

ក្រៅពីការសម្រេចអំពីការលែងលះ ចៅក្រមនឹងធ្វើការពិចារណាទៅលើចំណុចផ្សេងទៀតនៃខ្លឹមសារនៃការទាមទារដែលបានសរសេរនៅក្នុងពាក្យសុំផងដែរ ក្នុងករណីមានការទាមទារផ្សេងទៀតដូចជា ការទាមទារឱ្យបែងចែកសិទ្ធិអំណាចមេបា ការទទួលបន្ទុកសោហ៊ុយចំណាយ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន ការទាមទារឱ្យបែងចែកទ្រព្យជាអាទិ៍ តុលាការនឹងធ្វើការសម្រេចអំពីការទាមទារទាំងនោះ នៅផ្នែកសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេច។ ច្បាប់បានអនុញ្ញាតឱ្យភាគីប្តីប្រពន្ធ ដែលលែងលះគ្នា អាចធ្វើការពិភាក្សាគ្នាអំពីអ្នកមានអំណាចមេបាដោយកំណត់យកឪពុក ឬម្តាយណាម្ខាងតាមការពិភាក្សារបស់ឪពុកម្តាយ[39] និងអាចកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទងជាមួយកូន និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុក ដើម្បីគ្រប់គ្រងចិញ្ចឹមថែរក្សាកូន[40] ផងដែរ។ ដោយឡែកនៅក្នុងរឿងលែងលះដោយការព្រមព្រៀង គូភាគីតែងតែព្រមព្រៀងគ្នាជាស្រេច មិនមានអ្វីដែលឱ្យតុលាការពិបាកសម្រេចឡើយ។ ការព្រមព្រៀងនេះ គឺបិតនៅលើឆន្ទៈព្រមព្រៀងរបស់គូភាគី មិនថាភាគីម្ខាងណាបានតិច ឬភាគីម្ខាងបានច្រើនជាងទេ។ ក្នុងករណីនេះ ទោះបីជាទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិ

---

[35] មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[36] មាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[37] មាត្រា៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[38] មាត្រា៣៨ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[39] កថាខណ្ឌទី១ នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[40] កថាខណ្ឌទី២ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដោយឡែកក៏ដោយ ទ្រព្យសម្បត្តិរួមក៏ដោយ ពោលឱ្យតែគូភាគីសុខចិត្តព្រមព្រៀងដោយមិនមានការបង្ខិតបង្ខំ។ ការបែងចែកនេះរួមបញ្ចូលទាំងទ្រព្យសកម្ម និងទ្រព្យអកម្មផងដែរ។

#### ២.១.៣.២. ការជូនដំណឹងអំពីដីកាសម្រេច

ដីកាសម្រេចលែងលះដោយការព្រមព្រៀង ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ដោយការជូនដំណឹងអំពីដីកាសម្រេចនេះ ត្រូវធ្វើឡើងតាមរយៈការបញ្ជូន ឬការផ្ញើរជូនឯកសារចម្លងយថាភូតនៃដីកាសម្រេចនោះទៅភាគីនៃការលែងលះដោយសាមីខ្លួនក្នុងការលែងលះតែម្តង[41]។ ចំពោះការជូនដំណឹងនេះមិនចាំបាច់ដាច់ខាតត្រូវតែធ្វើការបញ្ជូន ដែលតម្រូវឱ្យក្រឡាបញ្ជីត្រូវប្រគល់ដោយផ្ទាល់ទេ គឺអាចធ្វើឡើងតាមរយៈប្រៃសណីយ៍ធម្មតាជាដើមក៏បាន[42]។

#### ២.១.៣.៣. ការចូលជាស្ថាពរនៃដីកាសម្រេច

ដីកាសម្រេច នឹងមិនត្រូវចូលជាស្ថាពរទេ កាលណាមិនទាន់ផុតរយៈពេលសម្រាប់ការប្តឹងជំទាស់ ហើយដីកាសម្រេចមិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរ[43] មានន័យថា បន្ទាប់ពីទទួលការជូនដំណឹងអំពីដីកាសម្រេចក្នុងរយៈពេល ០២ (ពីរ) សប្តាហ៍ ប្រសិនបើគ្មានបណ្តឹងឧបាស្រ័យណាមួយលើកឡើងទេ ដីកាសម្រេចលែងលះដោយការព្រមព្រៀងនឹងចូលជាស្ថាពរ[44]។

### ២.២. អានុភាពនៃការលែងលះដោយការព្រមព្រៀង

នៅពេលដែលដីកាសម្រេចចូលជាស្ថាពរអានុភាពនៃដីកាសម្រេចក៏កើតមាន ហើយអានុភាពដែលកើតមាននោះសម្រេចក្រោមរូបភាពឆ្លើយតបនឹងពាក្យសុំរបស់ភាគីដែលបានព្រមព្រៀងគ្នាលើគ្រប់ចំណុចនៅក្នុងការលែងលះដែលមានដូចតទៅ៖

#### ២.២.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត

អានុភាពចម្បងដែលកើតចេញពីការលែងលះ គឺជាការផ្តាច់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធ។ ការកាត់ផ្តាច់ទំនាក់ទំនងទាំងនោះរួមមាន ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ និងការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ។

[41] មាត្រា៣៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[42] មាត្រា២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[43] មាត្រា៣៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[44] មាត្រា៤០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

**២.២.១.១. ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ**

នៅពេលដែលបុរស និងស្ត្រីដែលមានពេញវ័យនីតិភាព ហើយរៀបអាពាហ៍ពិពាហ៍ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាដោយស្របច្បាប់ នោះពួកគេបានបង្កើតឡើងនូវចំណងគតិយុត្ត ដែលទទួលស្គាល់ដោយច្បាប់ថាពួកគេត្រូវជាសហព័ទ្ធនឹងគ្នាចាប់ពីពេលនោះតទៅ[45]។ នៅពេលដែលសហព័ទ្ធទាំងពីរបានលែងលះគ្នា នោះអានុភាពនៃការលែងលះបានកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធចាប់ពីពេលដីកាសម្រេចលែងលះចូលជាស្ថាពរ។ ត្រង់ចំណុចនេះបានសេចក្តីថា រវាងភាគីប្តី និងប្រពន្ធ មិនមានទំនងទំនងគតិយុត្តដែលបានទទួលស្គាល់ដោយច្បាប់ទៀតឡើយ។

**២.២.១.២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិពន្ធ**

អានុភាពនៃការលែងលះមិនមែនត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធនោះទេ ការលែងលះថែមទាំងនាំឱ្យមានការកាត់ផ្តាច់ដល់ទំនាក់ទំនងញាតិពន្ធផងដែរ។ ញាតិពន្ធ គឺសំដៅដល់សាច់ញាតិដែលមិនមានជាប់ខ្សែឈាមនឹងបុគ្គលជាប្តី ឬ ប្រពន្ធ តែជាញាតិខាងសហព័ទ្ធរបស់បុគ្គលជាប្តី ឬ ប្រពន្ធនោះ ដែលនិយាយតាមន័យសាមញ្ញ គឺញាតិសាច់ថ្លៃ។ នៅពេលដែលមានការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ នោះទំនាក់ទំនងញាតិពន្ធក៏ត្រូវបានបញ្ចប់រវាងសហព័ទ្ធទាំងសងខាងផងដែរ[46]។ ត្រង់ចំណុចនេះអានុភាពនៃការរំលាយចំណងអាពាហ៍ពិពាហ៍ដោយការលែងលះ គឺមានភាពខុសគ្នាទៅនឹងការរំលាយចំណងអាពាហ៍ពិពាហ៍ដោយសារមរណភាពរបស់សហព័ទ្ធណាម្ខាងដោយទំនាក់ទំនងញាតិពន្ធមិនបញ្ចប់នោះទេ លុះត្រាតែសហព័ទ្ធដែលនៅរស់រៀបអាពាហ៍ពិពាហ៍ថ្មី[47]។

**២.២.២. សិទ្ធិ និងកាតព្វកិច្ចក្រោយការលែងលះ**

ការលែងលះ គឺជាការបញ្ចប់ទំនាក់ទំនងគតិយុត្តរវាងសហព័ទ្ធដែលនៅរស់។ ទោះបីទំនាក់ទំនងគតិយុត្តនេះត្រូវបានបញ្ចប់ក៏ដោយក្តី ប៉ុន្តែអានុភាពនៃការលែងលះបានបន្សល់ទុកនូវសិទ្ធិ និងកាតព្វកិច្ចដល់គូភាគីដដែល។

**២.២.២.១. សិទ្ធិបន្សល់ក្រោយការលែងលះ**

ទោះបីអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ក៏ពិតមែន ក៏ប៉ុន្តែនៅក្រោយការលែងលះបានបន្សល់ទុកនូវសិទ្ធិមួយចំនួនចំពោះភាគី។ សិទ្ធិដែលបន្សល់ក្រោយការលែងលះ មានដូចជា សិទ្ធិទទួលបានអត្តាធីនភាព សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល សិទ្ធិលើអំណាចមេបាសិទ្ធិលើទ្រព្យសម្បត្តិ និងសិទ្ធិក្នុងការបង្កើតអាពាហ៍ពិពាហ៍ថ្មី។

[45] កថាខណ្ឌទី២ នៃមាត្រា៩៣៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[46] កថាខណ្ឌទី១ នៃមាត្រា៩៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[47] កថាខណ្ឌទី២ នៃមាត្រា៩៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ក. សិទ្ធិទទួលបានអត្តាធីនភាព

ក្នុងករណីដែលអនីតិជន ដែលបានទទួលអត្តាធីនភាពដោយការរៀបអាពាហ៍ពិពាហ៍ ហើយបានលែងលះគ្នា អានុភាពនៃអត្តាធីនភាពនៅតែមានដដែរ ពុំបានបញ្ចប់តាមអនុភាពដោយការលែងលះនោះទេ[48] មានន័យថា ទោះបីជាលែងលះក៏ដោយ ភាគីនៃចំណងអាពាហ៍ពិពាហ៍ដែលជាអនីតិជន នៅតែមានសិទ្ធិទទួលបានអត្តាធីនភាពដដែរ។

### ខ. សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ

នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ មានសហព័ទ្ធមួយចំនួនដែលប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធម្ខាងទៀត។ ដោយឡែកការប្រើប្រាស់ត្រកូលរបស់ភាគីម្ខាងទៀតពុំជាបញ្ហាចោទទេ ព្រោះថាបន្ទាប់ពីការលែងលះ ភាគីនៅតែមានសិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ។ ដោយច្បាប់បានផ្តល់ជម្រើសដល់ប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍អាចបន្តប្រើនាមត្រកូលនៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញបាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាបាន[49]។

### គ. សិទ្ធិលើអំណាចមេបា

នៅពេលលែងលះ កូនដែលបានកើតក្នុងចំណងអាពាហ៍ពិពាហ៍ ហើយដែលនៅក្នុងស្ថានភាពជាអនីតិជននៅឡើយ ត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្តាយ[50]។ ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នា នៅមុនកំណើតកូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ។ ប៉ុន្តែនៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុក ម្តាយបាន[51]។ ទន្ទឹមនឹងនេះផងដែរ ចំពោះឪពុក ឬ ម្តាយដែលពុំទទួលបានអំណាចមេបាលើកូនតាមការសម្រេចរបស់តុលាការក្រោយការលែងលះ ក៏ឪពុក ឬ ម្តាយនោះនៅតែមានសិទ្ធិក្នុងការចូលជួបកូន និងប្រាស្រ័យទាក់ទងគ្នា ជាមួយកូនដដែល[52]។ ការចូលជួប និងការប្រាស្រ័យទាក់ទងជាមួយកូនៗ តម្រូវឱ្យឪពុក និងម្តាយដែលបានលែងលះធ្វើការពិភាក្សាគ្នាលើការកំណត់វិធីនៃការណាត់ជួបកូនពីភាគីដែលមិនមានអំណាចមេបា[53]។ ប៉ុន្តែប្រសិនបើការពិភាក្សាពុំបានលទ្ធផលសម្រេចទេ នោះតុលាការត្រូវសម្រេចអំពី

[48] មាត្រា២១ មាត្រា២២ និងមាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[49] មាត្រា៩៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[50] កថាខណ្ឌទី១ នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[51] កថាខណ្ឌទី២ នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[52] កថាខណ្ឌទី១ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[53] កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៤០ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ចំណុចនេះ[54]។ ដោយឡែកចំពោះការលែងលះដោយការព្រមព្រៀង គឺវាមានភាពងាយស្រួលក្នុងការសម្រេចអំពីអ្នកមានអំណាចមេបាលើកូន និងការប្រាស្រ័យទាក់ទងជាមួយកូន ដោយហេតុថាគូភាគីតែងតែកំណត់ជ្រើសរើសរួចជាស្រេច។

### ឃ. សិទ្ធិលើទ្រព្យសម្បត្តិ

សហព័ទ្ធដែលបានចាប់ដៃកសាងគ្រួសាររួមគ្នា តែងតែមាននូវទ្រព្យសម្បត្តិដែលខិតខំស្វែងរកជាមួយគ្នានៅក្នុងអំឡុងពេលដែលមានចំណងអាពាហ៍ពិពាហ៍ ដូចនេះហើយនៅពេលដែលមានការលែងលះ ប្រាកដណាស់ថាសហព័ទ្ធនឹងត្រូវធ្វើការបែងចែងនូវទ្រព្យសម្បត្តិទាំងនោះ។ អនុលោមតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធបានបែងចែកជាពីរប្រភេទគឺ ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា និងប្រព័ន្ធទ្រព្យសម្បត្តិកំណត់ដោយច្បាប់។ ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិ នៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន[55]។ បានសេចក្តីថាប្តីប្រពន្ធ នៅមុន ឬ ក្រោយពេលរៀបអាពាហ៍ពាហ៍ អាចបណ្តើរគ្នាទៅចុះកិច្ចសន្យាទ្រព្យសម្បត្តិនៅក្រសួងយុត្តិធម៌ ដើម្បីងាយស្រួលសម្រាប់ប្តីប្រពន្ធនៅក្នុងគ្រួសារទៅថ្ងៃមុខ។ ដូច្នេះនៅពេលលែងលះនឹងមានការបែងចែកទ្រព្យសម្បត្តិ ជាហេតុនាំឱ្យចៅក្រមមិនពិបាកឡើយក្នុងការសម្រេចដោយអនុលោមទៅតាមការកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះ។ ផ្ទុយមកវិញ ប្រសិនបើប្តីប្រពន្ធនោះ មិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតាមកិច្ចសន្យាទេនោះ តុលាការអាចឱ្យភាគីប្តីប្រពន្ធនោះពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យបានដូចមានចែងនៅក្នុងកិច្ចសន្យា។ ដោយឡែកការលែងលះដោយការព្រមព្រៀង គឺគូភាគីតែងតែធ្វើការពិភាក្សាក្នុងការបែងចែកទ្រព្យសម្បត្តិរួមជាស្រេច។ ចំពោះទ្រព្យដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយករៀងៗខ្លួន។

### ង. សិទ្ធិក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ថ្មី

អានុភាពនៃការលែងលះ បានផ្តល់សិទ្ធិដល់ភាគីក្នុងការបង្កើតនូវចំណងអាពាហ៍ពិពាហ៍ថ្មីតាមឆន្ទៈរបស់ភាគី។ នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា ភាគីត្រូវបានហាមឃាត់ដោយច្បាប់មិនឱ្យមានចំណងអាពាហ៍ពិពាហ៍បន្ថែមជាមួយនឹងបុគ្គលដទៃផ្សេងទៀតឡើយ[56]។ នៅពេលមានដីកាសម្រេចលែងលះដែលបានចូលជាស្ថាពរ បានសេចក្តីថាភាគីមានសិទ្ធិសេរីភាពឡើងវិញក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយស្របច្បាប់ម្តងទៀត។ ទន្ទឹមនឹងនេះ រយៈពេលដែលភាគីខាងបុរស មានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មី មិនត្រូវបាន

[54] កថាខណ្ឌទី៤ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[55] កថាខណ្ឌទី១ នៃមាត្រា៩៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[56] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដាក់កំហិតដោយច្បាប់រដ្ឋប្បវេណីឡើយ។ ប៉ុន្តែចំពោះនារីវិញ ច្បាប់រដ្ឋប្បវេណីបានកំណត់អំពីរយៈពេលដែលនារីមានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ម្តងទៀត។ បន្ទាប់ពីលែងលះ នារីត្រូវរង់ចាំរយៈពេល ១២០ (មួយរយម្ភៃ) ថ្ងៃទើបអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ការរៀបអាពាហ៍ពិពាហ៍ថ្មីនេះ ក៏អាចធ្វើឡើងបានមុនរយៈពេលកំណត់ ១២០ (មួយរយម្ភៃ) ថ្ងៃ កាលបើមានលិខិតបញ្ជាក់ពីគ្រូពេទ្យថានារីនោះគ្មានផ្ទៃពោះ[57]។ ការកំណត់រយៈពេលក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីបែបនេះ ដើម្បីការពារករណីកុំឱ្យមានការយល់ច្រឡំលើទំនាក់ទំនងញាតិរបស់ទារកក្នុងផ្ទៃម្តាយ ពោលគឺកុំឱ្យមានការពិបាកក្នុងការបែងចែកអំពីបុរសដែលជាឪពុករបស់ទារក។ តែក្នុងករណីដែលស្ត្រីមានការបញ្ជាក់ច្បាស់លាស់ថាគ្មានផ្ទៃពោះ គឺមានសិទ្ធិរៀបចំណងអាពាហ៍ពិពាហ៍ថ្មី។ ជារួមក្រោយការលែងលះ ភាគីទាំងសងខាងសុទ្ធតែមានសិទ្ធិសេរីភាពឡើងវិញក្នុងការរៀបអាពាហ៍ពិពាហ៍សារជាថ្មីម្តងទៀត។

**២.២.២.២. កាតព្វកិច្ចបន្សល់ក្រោយការលែងលះ**

នៅក្រោយការលែងលះនឹងបន្សល់ទុកនូវកាតព្វកិច្ចមួយចំនួនចំពោះភាគីដូចជាកាតព្វកិច្ចបង់សោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន បញ្ចប់ករណីយកិច្ចសហព័ទ្ធ និងកាតព្វកិច្ចចំពោះតតិយជន។

**ក. កាតព្វកិច្ចបង់សោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន**

ឪពុក ឬ ម្តាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា[58]។ ប៉ុន្តែនៅក្រោយកាលែងលះ គឺត្រូវមានភាគីណាម្ខាងជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ដែលគេហៅថា អំណាចមេបាទោល។ ដោយសារតែការបែងចែកកូនមានការពាក់ព័ន្ធនឹងអាហារកាតព្វកិច្ចចិញ្ចឹមកូន ហេតុនេះហើយបានជានៅក្រោយពេលលែងលះតុលាការត្រូវពិចារណា ហើយសម្រេចឱ្យភាគីណាម្ខាង ឪពុក ឬ ម្តាយជាអ្នកមានអំណាចមេបាលើកូន។ ក្នុងករណីតុលាការ កំណត់ម្តាយជាអ្នកមានអំណាចមេបា ម្តាយត្រូវចាត់ទុកថាអ្នកមានសិទ្ធិលើសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ហើយឪពុកត្រូវចាត់ទុកថាអ្នកមានករណីយកិច្ចបង់សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន[59]។ ចំពោះចំណុចនេះឪពុក ម្តាយដែលលែងលះគ្នាអាចធ្វើការពិភាក្សាអំពីចំណុចនេះបាន[60]។ ផ្ទុយទៅវិញប្រសិនបើការពិភាក្សានោះពុំទទួលបានជោគជ័យ តុលាការត្រូវធ្វើការសម្រេចអំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងកូន[61] ដោយតុលាការធ្វើការសម្រេចអំពីចំនួននៃសោហ៊ុយចាំបាច់

[57] មាត្រា៩៥០ នៃក្រមរដ្ឋបប្បវេណីឆ្នាំ២០០៧

[58] វាក្យខណ្ឌទី១ នៃមាត្រា១០៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[59] កថាខណ្ឌទី១ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[60] កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[61] កថាខណ្ឌទី៤ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដើម្បីចិញ្ចឹមកូន ដោយពិចារណាទៅលើស្ថានភាពជីវភាព និងសេដ្ឋកិច្ចរបស់ឪពុក ឬម្តាយ ដែលមានករណីយកិច្ចត្រូវបង់នោះ[62]។ ប៉ុន្តែនៅក្នុងរឿងក្តីលែងលះដោយការព្រមព្រៀង គូភាគីតែងបានព្រមព្រៀងគ្នារួចជាស្រេច មិនមានអ្វីដែលឱ្យតុលាការពិបាកសម្រេចឡើយ។

**ខ. ការបញ្ចប់ករណីយកិច្ចសហព័ទ្ធ**

ជាការពិតណាស់ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាសហព័ទ្ធនឹងត្រូវមានករណីយកិច្ចរួមគ្នា ដូចជា ករណីយកិច្ចរួមរស់ជាមួយគ្នា ករណីយកិច្ចសហការគ្នា និងករណីយកិច្ចជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពគ្រួសារ ព្រមទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល[63]។ ប៉ុន្តែអ្វីៗទាំងអស់នេះនឹងបញ្ចប់ដោយការលែងលះគ្នា។ ដូច្នេះនៅពេលភាគីលែងលះបណ្តាលឱ្យភាគីរួចផុតពីករណីយកិច្ចសហព័ទ្ធទាំងឡាយនោះ ដោយសារអានុភាពនៃដីកាសម្រេច។

**គ.កាតព្វកិច្ចចំពោះតតិយជន**

កាតព្វកិច្ចចំពោះតតិយជន គឺសំដៅលើការដែលសហព័ទ្ធត្រូវទទួលខុសត្រូវបំពេញកាតព្វកិច្ចជូនជនដទៃទៀតដែលមានឋានៈជាម្ចាស់បំណុល ដែលត្រូវបានច្បាប់ទទួលស្គាល់។ សហព័ទ្ធទាំងពីរ ត្រូវមានករណីយកិច្ចសាមគ្គីគ្នា ក្នុងការទទួលខុសត្រូវចំពោះកាតព្វកិច្ច និងករណីយកិច្ចផ្សេងៗ ដែលសហព័ទ្ធបានព្រមព្រៀងជាមួយតតិយជន ដែលបានធ្វើឡើងក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍[64]។ ត្រង់ចំណុចនេះបានសេចក្តីថា ទោះបីភាគីមានការលែងលះជាមួយគ្នាក៏ដោយ តែភាគីទាំងពីរនៅតែត្រូវមានកាតព្វកិច្ចទទួលខុសត្រូវ ចំពោះតតិយជនដែលជាម្ចាស់បំណុលលើបំណុលទាំងឡាយណា ដែលបានជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយគ្នា។ បើបំណុលនោះ ជាបំណុលរួម នោះភាគីត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ហើយក្នុងករណីបំណុលនោះជាបំណុលដោយឡែក នោះភាគីម្ខាងៗ ត្រូវទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។ សរុបមក ថ្វីត្បិតតែចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ដោយការលែងលះក៏ដោយក្តី តែអានុភាពនៃការលែងលះ មិននាំឱ្យបញ្ចប់នូវកាតព្វកិច្ចមួយចំនួនដូចដែលបានរៀបរាប់ខាងលើនេះ។

ដូចនេះបន្ទាប់ពីបានសិក្សាជំពូកទី២ ការលែងលះដោយការព្រមព្រៀងខាងលើនេះរួចមក យើងនឹងបន្តការសិក្សានៅជំពូកទី៣ ការលែងលះដោយគ្មានការព្រមព្រៀងជាបន្តទៀត។

[62] កថាខណ្ឌទី៦ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[63] មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[64] មាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី

# ជំពូកទី៣
# ការលែងលះដោយគ្មានការព្រមព្រៀង

ការលែងលះដោយគ្មានការព្រមព្រៀង គឺស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហេតុនេះចំពោះការលែងលះដោយគ្មានការព្រមព្រៀងគ្នា ត្រូវប្រព្រឹត្តទៅតាមច្បាប់នេះ។ ការលែងលះដោយគ្មានការព្រមព្រៀង ត្រូវធ្វើឡើងនៅពេលដែលភាគីនៃចំណងអាពាហ៍ពិពាហ៍មិនបានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ឬភាគីមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយការលែងលះ។ ការលែងលះដោយគ្មានការព្រមព្រៀងនេះ ត្រូវឆ្លងកាត់នូវដំណាក់កាលនីតិវិធីរដ្ឋប្បវេណីជាច្រើនមុននឹងឈានដល់ការសម្រេចសេចក្តីដោយសាលក្រមរបស់តុលាការ។

តើនៅក្នុងបណ្តឹងនៃការលែងលះ មាននីតិវិធីនៃការលែងលះដូចម្តេចខ្លះ? តើបន្ទាប់ពីការលែងលះ នឹងបង្កើតឱ្យមានអានុភាពដូចម្តេចខ្លះ?

## ៣.១. នីតិវិធីបណ្តឹងលែងលះ

### ៣.១.១. ការផ្តើមនៃបណ្តឹងលែងលះ

ការលែងលះដោយការគ្មានការព្រមព្រៀង ចាប់ផ្តើមដំណើរការនីតិវិធី នៅពេលដែលសហព័ទ្ធម្ខាងបានដាក់ពាក្យបណ្តឹងទាមទារលែងលះ ដោយអនុលោមតាមច្បាប់ស្តីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ នៅក្នុងដំណើរការនីតិវិធីនេះ ជំហានដំបូង គឺភាគីត្រូវធ្វើបណ្តឹងលែងលះដោយភ្ជាប់មកជាមួយនឹងឯកសារ ព្រមទាំងភស្តុតាងពាក់ព័ន្ធផ្សេងៗ។ រួចភាគីត្រូវយកពាក្យបណ្តឹងលែងលះនោះទៅដាក់នៅក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងលំនៅឋានប្តីប្រពន្ធ ឬ ទីសំណាក់ ឬ ក៏យកទៅដាក់នៅតុលាការដែលមានសមត្ថកិច្ច និងត្រូវបង់ពន្ធតាមការកំណត់នៃច្បាប់[65]។

#### ៣.១.១.១. ការសរសេរពាក្យបណ្តឹង

ពាក្យបណ្តឹងលែងលះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលអនុវត្តតាមបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ពីព្រោះថាចំណងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ មិនមែនជាកិច្ចសន្យាធម្មតានោះទេ ពោលវាគឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ដែលធ្វើឡើងដោយប្តីប្រពន្ធតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួនបានឡើយ[66]។ ហេតុដូច្នេះបណ្តឹងលែងលះចាំបាច់ត្រូវតែដោះស្រាយតាមរយៈ

[65] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[66] មាត្រា៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧

តុលាការដែលមានសមត្ថកិច្ច ដោយភាគីជាដើមចោទត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដែលមានសមត្ថកិច្ច គឺតុលាការនៅទីលំនៅឋានរបស់សហព័ទ្ធណាម្ខាង[67]។

នៅក្នុងពាក្យបណ្តឹងលែងលះ ត្រូវសរសេរបញ្ជាក់អំពី៖

-ឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងឈ្មោះ និងអាសយដ្ឋានដែលច្បាប់បានកំណត់។

-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖ សំដៅលើអត្ថន័យនៃសាលក្រមដែលដើមចោទចង់ឱ្យតុលាការសម្រេចសេចក្តីដូចក្នុងពាក្យបណ្តឹងរបស់ខ្លួន។ ឧទាហរណ៍ ៖ នៅក្នុងរឿងក្តីលែងលះ ដែលជាបណ្តឹងទាមទារឱ្យរំលត់ទំនាក់ទំនងគតិយុត្ត ដូចនេះខ្លឹមសារនៃសាលក្រមដែលដើមចោទ ទាមទារឱ្យតុលាការចេញ គឺឱ្យដើមចោទ និងចុងចម្លើយលែងលះពីគ្នា ចាប់ពីពេលសាលក្រមចូលជាស្ថាពរ។

-អង្គហេតុចាំបាច់ ដើម្បីបញ្ជាក់អំពីការទាមទារ ៖ សំដៅលើអង្គហេតុ ដែលអាចធ្វើការកត់សម្គាល់កុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត អះអាងដោយដើមចោទ និងសិទ្ធិ ឬសិទ្ធិ និងទំនាក់ទំនងគតិយុត្តផ្សេងទៀត។ ឧទាហរណ៍ ៖ នៅក្នុងរឿងលែងលះ ដើមចោទត្រូវសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការលែងលះ។

-អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹង ពោលគឺដើម្បីបង្ហាញអំពីការកើតមានឡើងនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ។

-អង្គហេតុសំខាន់ៗ ដែលពាក់ព័ន្ធ និងភស្តុតាង គឺជាអង្គហេតុដែលធ្វើឱ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុចម្បង។

-ពាក្យបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួនត្រូវចាត់ទុកថាជាឯកសារត្រៀមផងដែរ។

### ៣.១.១.២. ការដាក់ពាក្យបណ្តឹង

ភាគីដែលមានបំណងចង់លែងលះ អាចធ្វើការដាក់ពាក្យសុំលែងលះគ្នា ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ខាងលំនៅឋាន ឬទីលំណាក់ បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដទេ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ។ ក្នុងករណីនេះក្រុមប្រឹក្សាឃុំ-សង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំនោះ។ បើមិនអាចបញ្ចុះបញ្ចូលឱ្យសះជាគ្នាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងលែងលះនោះទៅតុលាការជាបន្ទាន់[68] ព្រោះ

[67] មាត្រា៥ នៃច្បាប់ស្តីពីនិតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[68] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្រុមប្រឹក្សាឃុំ-សង្កាត់មិនមានសមត្ថកិច្ចក្នុងការសម្រេចសេចក្ដីឱ្យភាគីធ្វើការលែងលះ ឬមិនឱ្យមានការលែងលះឡើយ។

បណ្ដឹងទាមទារលែងលះគ្នា គឺជាបណ្ដឹងទាមទារឱ្យរលត់សិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដែលមានមូលហេតុនៃការលែងលះតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដោយត្រូវអនុលោមតាមបញ្ញត្តិច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០[69]។ យោងតាមមាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ និងមាត្រា ៥ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០ បណ្ដឹងលែងលះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅទីលំនៅឋានរបស់ភាគី នៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬលំនៅឋាននៅពេលដែលភាគីនោះទទួលមរណៈភាព[70]។

#### ៣.១.១.៣. ការទទួលពាក្យបណ្ដឹង

យោងតាមមាត្រា៦ ចំណុចទី១ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង បានផ្ដល់សមត្ថកិច្ចឱ្យការិយាល័យកិច្ចការតុលាការ ទទួលបន្ទុកលើការទទួលចាត់ចែងឯកសារចេញចូលរបស់សាលាដំបូង និងចុះបញ្ជីពាក្យបណ្ដឹង និងចាត់ចែងបន្តតាមនីតិវិធី។ ហេតុដូចនេះ នៅពេលភាគីដាក់ពាក្យបណ្ដឹងលែងលះ អាចដាក់ពាក្យបណ្ដឹងនៅលេខាធិការដ្ឋានរដ្ឋបាលរបស់សាលាដំបូងដែលមានសមត្ថកិច្ចនោះ។

នៅពេលដែលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធលើពាក្យបណ្ដឹង ដែលមានចំនួនទឹកប្រាក់ដោយគណនាតាមតម្លៃនៃកម្មវត្ថុនៃបណ្ដឹង ដែលត្រូវបានកំណត់ដោយច្បាប់[71]។ ការគណនាពន្ធលើពាក្យបណ្ដឹង គឺយកតម្លៃនៃកម្មវត្ថុបណ្ដឹង មកធ្វើជាមូលដ្ឋានដើម្បីធ្វើការគណនា[72] ប៉ុន្តែដោយសារពាក្យបណ្ដឹងលែងលះ គឺជាប្រភេទនៃកម្មវត្ថុបណ្ដឹងដែលទាមទារច្រើនចំណុច និងមានការពិបាកក្នុងការគណនាតម្លៃ ហេតុនេះតុលាការត្រូវកំណត់តម្លៃទាំងនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល នោះត្រូវចាត់ទុកថាតម្លៃកម្មវត្ថុបណ្ដឹងមានចំនួន ៥.៥០០.០០០ (ប្រាំលានប្រាំសែន) រៀល ដែលដើមចោទត្រូវបង់ពន្ធលើពាក្យបណ្ដឹងនោះ ចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល[73]។ ចំណែកឯការបង់ពន្ធលើប្រាក់ប្រដាប់ក្ដីតុលាការក្រៅពន្ធ ភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវ

[69] ចំណុច គ នៃមាត្រា៣ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[70] មាត្រា៥ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[71] កថាខណ្ឌទី១ នៃមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[72] មាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[73] មាត្រា៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បង់ដែលមានចំនួនប្រែប្រួលទៅតាមការកំណត់របស់តុលាការ និងធ្វើការបង់ជាមុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីបណ្ដឹងដើម្បីឱ្យតុលាការ[74]៖

-ធ្វើការពិនិត្យភស្ដុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀត តាមនីតិវិធីបណ្ដឹង។

-សោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅ ដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែលធ្វើការពិនិត្យភស្ដុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។ ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្ដឹង មិនបានបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធទេនោះ តុលាការនិងលើកពាក្យបណ្ដឹងចោលដោយដីកាសម្រេច[75]។

### ៣.១.១.៤. ការពិនិត្យ និងការបញ្ជូនពាក្យបណ្ដឹងទៅចុងចម្លើយ

នៅក្នុងការពិនិត្យពាក្យបណ្ដឹងតុលាការត្រូវពិនិត្យថា តើដើមចោទបានសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្ដឹងគ្រប់គ្រាន់តាមមាត្រា ៧៥ កថាខណ្ឌទី ២ ហើយឬនៅ? ហើយតើដើមចោទបានបង់ពន្ធលើពាក្យបណ្ដឹងដូចមានចែងក្នុងមាត្រា ៦១ និងបានបង់ពន្ធប្រាក់ប្រដាប់ក្ដីតុលាការក្រៅពន្ធតាមមាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ហើយឬនៅ? ក្នុងករណីដែលមានចំនុចខ្វះខាតលើពាក្យបណ្ដឹង និងមិនបានបំពេញលក្ខខណ្ឌដូចខាងលើ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្ដឹងនោះក្នុងអំឡុងពេលនោះ។ បើភាគីមិនបានកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការត្រូវលើកពាក្យបណ្ដឹងចោលដោយដីកាសម្រេច។ ដីកាសម្រេចនេះ អាចប្ដឹងជំទាស់បាន[76]។

បន្ទាប់ពីតុលាការបានពិនិត្យលើពាក្យបណ្ដឹងលែងលះឃើញថាមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងស្របតាមនីតិវិធី តុលាការបញ្ជូនពាក្យបណ្ដឹងលែងលះឱ្យចុងចម្លើយជាចាំបាច់[77] ព្រោះថាការបញ្ជូនពាក្យបណ្ដឹង គឺជាការផ្ដល់ឱកាសឱ្យភាគីចុងចម្លើយបានដឹងថាសហព័ទ្ធរបស់ខ្លួនបានប្ដឹងសុំលែងលះ។ កិច្ចការបញ្ជូន ត្រូវធ្វើឡើងដោយក្រឡាបញ្ជី ឬបុគ្គលិកប្រៃសណីយ៍ ឬអាជ្ញាសាលាជាដើម[78]។ ពាក្យបណ្ដឹងត្រូវបានបញ្ជូនទៅដល់ចុងចម្លើយ ទើបបណ្ដឹងនោះត្រូវបានចាត់ការ។ ក្នុងករណីដែលមិនអាចបញ្ជូនបណ្ដឹងបាន ដោយសារមូលហេតុអាសយដ្ឋានរបស់ចុងចម្លើយ ដែលដើមចោទផ្ដល់ឱ្យមិនមានភាពច្បាស់លាស់ ឬមានការផ្លាស់ប្ដូរអាសយដ្ឋានឬដើម តុលាការត្រូវបង្គាប់ឱ្យដើមចោទកែតម្រូវ ដោយទុកអំឡុងពេលសមរម្យ។

[74] ចំណុច ក និងចំណុច ខ នៃកថាខណ្ឌទី១ នៃមាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[75] កថាខណ្ឌទី៥ នៃមាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[76] កថាខណ្ឌទី៣ នៃមាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[77] មាត្រា៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[78] មាត្រា២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ៣.១.២. ការចាត់ចែងរក្សាការពារ

ជាទូទៅនៅក្នុងដំណើរការនៃបណ្ដឹងនៃការលែងលះទាមទារនូវពេលវេលាមួយយ៉ាងវែង ដោយសារតែច្បាប់តម្រូវឱ្យមានការសាកល្បងធ្វើការផ្សះផ្សា រួមទាំងនីតិវិធីរបស់តុលាការជាច្រើនទៀតនៅក្រោយពេលផ្សះផ្សា។ ហេតុនេះ ទើបតុលាការអាចបង្គាប់ឱ្យមានការចាត់ចែងរក្សាការពារវិធានការបណ្ដោះអាសន្ន។ ការចាត់ចែងរក្សាការពារ គឺជាវិធានការដើម្បីធានាឱ្យជីវភាពរស់នៅក្នុងគ្រួសារអាចបន្តទៅទៀតបានដោយសមរម្យ ទោះបីជាសហព័ទ្ធទាំងសងខាងកំពុងតែប្ដឹងទាមទារលែងលះគ្នាក៏ដោយ។ វិធានការនេះ គឺជាការណែនាំ ឬបញ្ជារបស់តុលាការបង្គាប់ទៅភាគីសហព័ទ្ធ ហើយចៅក្រមត្រូវចុះក្នុងកំណត់ត្រារបស់តុលាការ។ វិធានការទាំងនេះមានលក្ខណៈជាបណ្ដោះអាសន្ន ព្រោះវាមានប្រសិទ្ធិភាពតែក្នុងរយៈពេលដំណើរការនៃរឿងក្ដីប៉ុណ្ណោះ។ ពោលគឺនៅពេលដែលតុលាការ ចេញសាលក្រមស្ថាពររួច សាលក្រមនោះនឹងមកជំនួសឱ្យវិធានការបណ្ដោះអាសន្នហើយរាល់វិធានការទាំងអស់នោះនឹងត្រូវអស់សុពលភាព។ យោងតាមមាត្រា ៩៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អនុញ្ញាតឱ្យតុលាការចេញវិធានការចាត់ចែងរក្សាការពារ ៥យ៉ាងដូចតទៅនេះ ទី១ វិធានការដាក់ឱ្យសហព័ទ្ធត្រូវរស់នៅបែកគ្នា ទី២ វិធានការដាក់ឱ្យមានការថែរក្សាកូនបណ្ដោះអាសន្ន ទី៣ វិធានការទាក់ទងនឹងការថែរក្សាទ្រព្យសម្បត្តិជាបណ្ដោះអាសន្ន ទី៤ វិធានការទាក់ទងទៅនឹងការផ្គត់ផ្គង់សហព័ទ្ធ ឬផ្គត់ផ្គង់កូន និងទី៥ វិធានការរឹបអូសជាបណ្ដោះអាសន្ន។

#### ៣.១.២.១. វិធានការដាក់ឱ្យសហព័ទ្ធរស់នៅបែកគ្នាជាបណ្ដោះអាសន្ន

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧ អនុញ្ញាតឱ្យតុលាការចេញវិធានការឱ្យភាគីទាំងពីររស់នៅបែកគ្នាបណ្ដោះអាសន្ន ក្នុងអំឡុងពេលនៃនីតិវិធីលែងលះគ្នា ក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ។ ប៉ុន្តែក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនមានចែងអំពីវិធានការឱ្យសហព័ទ្ធត្រូវតែរស់ នៅបែកគ្នាបណ្ដោះអាសន្នទេក្នុងករណីភាគីទាំងពីរមានប្រើអំពើហិង្សាក្នុងគ្រួសារ និងបានប្ដឹងសុំលែងលះគ្នា តើតុលាការត្រូវដោះស្រាយបណ្ដឹងសំអាងលើច្បាប់អ្វី? ករណីនេះប្រហែលជាពួកគេពឹងផ្អែកទៅលើច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ដែលផ្ដល់អំណាចទៅឱ្យមេឃុំ-ចៅសង្កាត់ ក្នុងដំណាក់កាលនៃការជួយអន្តរាគមន៍លើកដំបូង។ មាត្រា ១៤ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ បានផ្ដល់សិទ្ធិអំណាចទៅដល់មេឃុំ ចៅសង្កាត់ អាចចាត់វិធានការបណ្ដោះអាសន្នដែលមានដូចជា៖

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬដោយអ្នកផ្សេង។

-ហាមបំផ្លាញទ្រព្យ ឬណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬរបស់ជនរងគ្រោះ ឬរបស់ញាតិសាលោហិតរបស់ជនរងគ្រោះ។

-ហាមជនមុខសញ្ញាចូលទៅជិត ឬចូលទៅក្នុងទីលំនៅឬមកន្លែងស្នាក់នៅ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច។

-ចាត់វិធានការស្របច្បាប់ផ្សេងទៀតដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពជនរងគ្រោះ និងសមាជិកគ្រួសារ ឬជនបានដែលពាក់ព័ន្ធ។

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះក៏អាចធ្វើបណ្តឹងទៅតុលាការរាជធានីខេត្ត ដើម្បីសុំចេញដីការក្សាការពារ។ តុលាការដែលទទួលបណ្តឹងដើម្បីចាត់ការអាចចេញដីការក្សាការពារដោយមានវត្តមាន ឬពុំចាំបាច់មានវត្តមានសហព័ទ្ធដែលបានប្រើអំពើហិង្សា។ ប្រសិនបើមានអំពើហិង្សាលើរូបរាងកាយប្រពន្ធ ឬកូន ឬក្នុងករណីមានអំពើឃោរឃៅលើស្មារតីធ្ងន់ធ្ងរ ពេលនោះប្រហែលជាប្រពន្ធចង់ស្នើសុំឱ្យភាគីទាំងពីររស់បែកគ្នាចាប់តាំងពីពេលចាប់ផ្តើមនីតិវិធីលែងលះគ្នា។

ចំណាត់ការបែបនេះគឺក្នុងគោលបំណងការពារនូវសុវត្ថិភាពរបស់ភាគីទាំងសងខាង នៅពេលដំណើរការនៃរឿងក្តី។ ម្យ៉ាងវិញទៀត ដើម្បីបញ្ចៀសនូវរាល់សកម្មភាពអវិជ្ជមាននានាទៅលើគ្នាទៅវិញទៅមក តាមរយៈការគុំគួនគ្នា ធ្វើទុក្ខបុកម្នេញ អំពើហិង្សា រហូតអាចឈានទៅដល់ការបាត់បង់ជីវិតក៏ថាបាន។ ដូចនេះការបែកលំនៅគ្នា អាចជាវិធានការដ៏ល្អក្នុងការបញ្ចៀសជម្លោះ ដោយសារតែពួកគេផ្សះផ្សាលែងបានហើយ និងមួយវិញទៀត ធ្វើឱ្យមានភាពងាយស្រួលចំពោះតុលាការផង។

### ៣.១.២.២. វិធានការដាក់ឱ្យមានការថែរក្សាកូនជាបណ្តោះអាសន្ន

បញ្ហាកូន ក៏ជាប្រធានបទក៏ក្តៅគគុកមួយចំពោះការលែងលះដែរ ពីព្រោះភាគច្រើននៃការលែងលះ ភាគីសុទ្ធតែប្តឹងទាមទារកូនរៀងៗខ្លួន។ ដូច្នេះដើម្បីការពារសុវត្ថិភាពកូន ក៏ដូចជាដើម្បីបញ្ចៀសនូវរាល់វិបត្តិផ្លូវចិត្តទៅលើកូន តុលាការនឹងអនុញ្ញាតឱ្យមានវិធានការគ្រប់គ្រងកូន។ តួយ៉ាងពេលឪពុកម្តាយប្តឹងលែងលះគ្នា វាគឺជាបញ្ហាមួយយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រួសារសម្រាប់កូន ពោលគឺកូននឹងត្រូវបាត់បង់ភាពកក់ក្តៅពីឪពុកម្តាយ។

ដោយឡែក ការគ្រប់គ្រងកូនក៏អាចខាងប្រពន្ធ មានអាទិភាពក្នុងការមើលថែទាំកូនជាងខាងប្តី ប្រសិនកូនគឺជាទារកដែលនៅបៅទឹកដោះម្តាយ ព្រោះត្រូវគិតគូរពីសុខភាពទារកផងដែរ។ ដូចដែលបានលើកឡើងនេះក៏ដូចជាការជៀសវាង នូវការបង្ខិតបង្ខំនានាទៅលើការសម្រេចចិត្តរបស់កូន។ តុលាការគប្បីមានចំណាត់ការឱ្យមានអ្នកមើលថែរក្សាកូន ដែលយល់ឃើញថាសមរម្យ ទើបអាចឱ្យការសម្រេចសេចក្តីមានយុត្តិធម៌ជាប្រយោជន៍ដល់កូន។

### ៣.១.២.៣. វិធានការទាក់ទងទៅនឹងការថែរក្សាទ្រព្យសម្បត្តិជាបណ្តោះអាសន្ន

ទ្រព្យសម្បត្តិ ជាកម្មវត្ថុដ៏ចម្បងមួយទៀតនៃបណ្តឹងលែងលះ ហើយដែលភាគីតែងខិតខំស្វែងរកកំហុសមកដាក់បន្ទុកឱ្យគ្នា ដើម្បីអាចទទួលបាននូវចំណែកនៃទ្រព្យសម្បត្តិច្រើនជាងគេ។ តុលាការ ឬភាគីត្រូវយកចិត្ត

ទុកដាក់លើការចាត់ចែងរក្សាការពារទ្រព្យសម្បត្តិឱ្យបានគង់វង្សដែរ ដោយជៀសវាងនូវការលក់ដូរ ឬការបំផ្លិចបំផ្លាញរបស់ភាគីណាមួយ ដែលអាចធ្វើឱ្យចំណែកមួយនៃកម្មវត្ថុនៃបណ្តឹងត្រូវបាត់បង់។ តាមការពិតទៅការចាត់ចែងរក្សាការពារទ្រព្យសម្បត្តិនៅក្នុងលក្ខខណ្ឌនេះ សំដៅតែលើការគ្រប់គ្រងទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធតែប៉ុណ្ណោះ ដោយតុលាការ មិនអាចលូកដៃចូលទៅគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងៗនោះទេ។ ចៅក្រមមានអំណាចចេញវិធានការបណ្តោះអាសន្នស្តីពីការថែរក្សាការពារ និងប្រើប្រាស់ទ្រព្យសម្បត្តិក្នុងអំឡុងពេលនីតិវិធីនៃការលែងលះ។ វិធានការនេះសំខាន់ណាស់ ពីព្រោះសហព័ទ្ធមួយអាចព្យាយាមយក ឬក៏លក់ ឬផ្ទេរទ្រព្យសម្បត្តិមុនពេលដែលតុលាការមានឱកាសស៊ើបអង្កេត និងធ្វើការបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌។ ម្យ៉ាងទៀតក៏ជួយការពារមិនឱ្យភាគីម្ខាងទៀត លក់ ធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនោះ។ ប្រសិនបើសហព័ទ្ធទាំងពីរជាម្ចាស់ផ្ទះ ចៅក្រមអាចសម្រេចថាអ្នកណានឹងរស់នៅក្នុងផ្ទះនោះ ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីការលែងលះគ្នានោះ។

### ៣.១.២.៤. វិធានការទាក់ទងនឹងការផ្គត់ផ្គង់សហព័ទ្ធ ឬកូនជាបណ្តោះអាសន្ន

វិធានការនេះ មានគោលបំណងរក្សាជីវភាពរស់នៅរបស់សហព័ទ្ធណាម្ខាង និងការផ្គត់ផ្គង់លើរាល់តម្រូវការរបស់កូនក្នុងអំឡុងពេលនៃនីតិវិធីលែងលះ។ ជាការពិតណាស់ គ្រួសារខ្លះអាចមានសហព័ទ្ធម្ខាងជាអ្នកចេញទៅក្រៅផ្ទះរកចំណូលមកធ្វើការផ្គត់ផ្គង់គ្រួសារ ហើយសហព័ទ្ធម្ខាងទៀតជាអ្នកមើលការខុសត្រូវនៅក្នុងផ្ទះ ទោះបីជាយ៉ាងណា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានឱ្យតម្លៃទៅលើការងារនៅក្រៅផ្ទះថាមានតម្លៃស្មើនឹងការងារនៅក្នុងផ្ទះដែរ។ ដូចនេះ សហព័ទ្ធដែលមានលទ្ធភាពមិនអាចបដិសេធកាតព្វកិច្ចសម្រាប់ការផ្គត់ផ្គង់នេះបានទេ ព្រោះប្រសិនបើគ្មានការផ្គត់ផ្គង់ជាបណ្តោះអាសន្នទេ វានឹងធ្វើឱ្យសហព័ទ្ធម្ខាងមានការលំបាកនៅក្នុងការទ្រទ្រង់ជីវភាព។

តុលាការមានអំណាចចេញវិធានការបណ្តោះអាសន្នស្តីពីការផ្គត់ផ្គង់កូនបណ្តោះអាសន្ន ហើយក្នុងករណីចាំបាច់ តុលាការក៏អាចសម្រេចឱ្យមានការផ្គត់ផ្គង់ដល់សហព័ទ្ធ។ ជាទូទៅតុលាការចាត់វិធានការនេះ ដោយផ្តោតសំខាន់លើសេចក្តីត្រូវការរបស់កូន លទ្ធភាពខាងហិរញ្ញវត្ថុរបស់ភាគីស្នើសុំ និង លទ្ធភាពហិរញ្ញវត្ថុរបស់អ្នកដែលត្រូវផ្គត់ផ្គង់។

តុលាការក៏អាចផ្តល់ការផ្គត់ផ្គង់បណ្តោះអាសន្នដល់សហព័ទ្ធដែលត្រូវការប្រាក់ ក្នុងអំឡុងពេលនីតិវិធីនៃការលែងលះគ្នា។ ម្យ៉ាងទៀតច្បាប់មិនបានណែនាំតុលាការ តើត្រូវសម្រេចផ្តល់ការផ្គត់ផ្គង់ដល់សហព័ទ្ធ ឬក៏មិនផ្តល់ ឬមានទឹកប្រាក់ចំនួនប៉ុន្មានដែលសហព័ទ្ធមួយត្រូវបង់ទៅឱ្យសហព័ទ្ធមួយទៀតជាបណ្តោះអាសន្នទេ។ ជាទូទៅតុលាការចេញវិធានការបណ្តោះអាសន្នបើអាចធ្វើបាន ដើម្បីរក្សាកម្រិតជីវភាពសហព័ទ្ធដែលធ្លាប់ទទួល

បានការផ្ដត់ផ្គង់ ដូចក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។ វិធានស្ដីពីការផ្ដត់ផ្គង់សហព័ទ្ធជាបណ្ដោះអាសន្ននេះ មិនអនុវត្តជាចាំបាច់ចំពោះការផ្ដត់ផ្គង់សហព័ទ្ធជាអចិន្ត្រៃយ៍នោះទេ ។

#### ៣.១.២.៥. ការរឹបអូសជាបណ្ដោះអាសន្ន

នៅក្នុងករណីមានបណ្ដឹងលែងលះគ្នា តុលាការ ក៏អាចចេញវិធានការឱ្យធ្វើការរឹបអូសជាបណ្ដោះអាសន្ន នូវទ្រព្យសម្បត្តិដែលជាចលនទ្រព្យ ឬអចលនទ្រព្យរបស់សហព័ទ្ធ ឬវត្ថុតាងណាមួយដោយឆន្ទានុសិទ្ធិបានដែរ ទោះបីភាគីមិនបានស្នើសុំក៏ដោយ។ ការរឹបអូសនេះមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីថែរក្សាទ្រព្យសម្បត្តិ ឬ ភស្តុតាងនានា ដើម្បីបង្ការកុំឱ្យសហព័ទ្ធម្ខាងទៀតបំផ្លាញ ឬធ្វើឱ្យមានការខូចខាតទ្រព្យសម្បត្តិ ឬមានការ ចាត់ចែងផ្សេងដូចជាការលក់ដូរ ការជួល ឬការបញ្ចាំ ការធ្វើអំណោយជាដើម។

## ៣.២. នីតិវិធីនៃការជម្រះក្ដី

### ៣.២.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីរៀបចំនូវការអះអាងរបស់ភាគី និងរៀបចំនូវចំណុច វិវាទនៃរឿងក្ដី ព្រមទាំងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ ដើម្បីឱ្យតុលាការអាចធ្វើការពិនិត្យភស្តុតាង ជាសមូហវិធី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់[79]។

នៅរាល់កាលបរិច្ឆេទនីមួយៗ នៃនីតិនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[80]។ នៅក្នុងកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចសំខាន់ៗដូចមានចែងក្នុងមាត្រា ១១០ និងមាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៧។

#### ៣.២.១.១. ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ទាញហេតុផល

បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ បើតុលាការយល់ឃើញថាពាក្យបណ្ដឹងលែងលះនោះស្របច្បាប់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងឆាប់រហ័ស និងធ្វើការកោះហៅ ភាគីក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់ដែលកាលបរិច្ឆេទនេះ ហៅថា "កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល"[81]។ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់នេះធ្វើឡើង ដើម្បីបង្ហាញអំពីចំណាត់ការលើពាក្យបណ្ដឹង និងផ្ដល់ ឱកាសឱ្យដើមចោទ និងចុងចម្លើយមានពេលវេលាសមស្របក្នុងការរៀបចំឯកសារផ្សេងៗ ឬការការពារខ្លួនជាដើម។

---

[79] មាត្រា១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[80] មាត្រា១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[81] មាត្រា៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ៣.២.១.២. ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលភាគីបានចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅក្នុងកាលបរិច្ឆេទដែលបានកំណត់រួចហើយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាជាលើកដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ[82]។ ការផ្សះផ្សានៅក្នុងរឿងក្ដីរដ្ឋប្បវេណី គឺជាផ្នែកមួយដ៏សំខាន់បំផុតនៃនីតិវិធីលែងលះ មុនពេលប្ដីប្រពន្ធត្រូវបានអនុញ្ញាតឱ្យលែងលះគ្នា ទោះបីជាភាគីម្ខាងបានទាមទារយ៉ាងខ្លាំង ចំពោះការលែងលះគ្នាយ៉ាងណាក៏ដោយ តុលាការអាចណែនាំឱ្យមានការផ្សះផ្សាតាមឆន្ទានុសិទ្ធិ ក្នុងគោលបំណងដើម្បីឱ្យភាគីដើមចោទឈប់ប្ដឹង និងបញ្ចុះបញ្ចូលគូភាគីឱ្យត្រូវរ៉ូវគ្នាជាប្ដីប្រពន្ធវិញ។ ជាពិសេសនៅពេលដែលប្ដីប្រពន្ធមានកូនជាអនីតិជន ឬ ក្នុងស្ថានភាពដែលសហព័ទ្ធម្ខាងដែលជួបការលំបាកលំបិនផ្នែកសេដ្ឋកិច្ចជាដើម[83]។

### ៣.២.១.៣. ការរៀបចំអះអាងចំណុចវិវាទ

នៅក្នុងករណីដែលការផ្សះផ្សាមិនបានសម្រេច តុលាការនឹងចាប់ផ្ដើមការត្រៀមទាញហេតុផល ដើម្បីកំណត់ចំណុចវិវាទ។ ចំណុចវិវាទ គឺជាចំណុចដែលគូភាគីមានការខ្វែងគំនិតគ្នា និងជាចំណុចដែលតុលាការត្រូវពិចារណា សម្រេចដោយចេញសាលក្រមតាមការទាមទាររបស់ភាគី ឬតាមឆន្ទានុសិទ្ធិរបស់តុលាការ។

ដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្ដី អង្គហេតុដែលមាន ឬគ្មានវិវាទ និងដើម្បីឈានដល់ដំណាក់កាលបន្ទាប់នៃនីតិវិធី តុលាការបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម ព្រោះវាមានសារៈសំខាន់សម្រាប់ដំណើរការដោះស្រាយបណ្ដឹងឱ្យបានឆាប់រហ័ស[84]។ នៅក្នុងឯកសារត្រៀមត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្ដីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនចំពោះភាគីម្ខាងទៀត[85]។ **មធ្យោបាយតទល់** គឺជាឯកសារទាំងឡាយដែលដើមចោទបានដាក់ជូនតុលាការ ដើម្បីបញ្ជាក់អំពីមូលហេតុនៃការទាមទាររបស់ខ្លួន[86]។ **មធ្យោបាយការពារខ្លួន** គឺជាឯកសារទាំងឡាយដែលចុងចម្លើយបានដាក់ជូនតុលាការ ដើម្បីបញ្ជាក់ថា ការទាមទាររបស់ដើមចោទពុំមានមូលហេតុត្រឹមត្រូវ[87]។ ឯកសារត្រៀម ដែលចុងចម្លើយបានដាក់លើកដំបូងហៅថា **ឯកសារចម្លើយ**[88]។ ការដាក់ឯកសារត្រៀមមិនទាន់គ្រប់គ្រាន់ទេ ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីខ្លឹមសារនៃ

---

[82] មាត្រា១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[83] សេចក្ដីកំណត់ចំពោះមាត្រា៩៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[84] សេចក្ដីកំណត់ចំពោះមាត្រា១០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[85] កថាខណ្ឌទី២ នៃមាត្រា ១០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[86] ការពន្យល់អំពីនីតិវិធីជម្រះក្ដីលើកទី១ (បោះពុម្ពលើកទី២) ឆ្នាំ២០០៩, ទំព័រទី២៨

[87] ការពន្យល់អំពីនីតិវិធីជម្រះក្ដីលើកទី១ (បោះពុម្ពលើកទី២) ឆ្នាំ២០០៩, ទំព័រទី២៨

[88] ការពន្យល់អំពីនីតិវិធីជម្រះក្ដីលើកទី១ (បោះពុម្ពលើកទី២) ឆ្នាំ២០០៩, ទំព័រទី២៧

ឯកសារត្រៀមនេះនៅកាលបរិច្ឆេទដូចការធ្វើសេចក្ដីថ្លែងការណ៍អំពីពាក្យបណ្ដឹងដែរ[89]។ សេចក្ដីថ្លែងការណ៍របស់ដើមចោទ ហៅថាមធ្យោបាយតទល់ ដែលអះអាងអំពីសិទ្ធិ និទំនាក់ទំនងគតិយុត្តដែលជាការទាមទារតាមផ្លូវបណ្ដឹងចំណែកឯសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ គឺជាមធ្យោបាយការពារខ្លួន។ ចំពោះចំណុចវិវាទនៅក្នុងរឿងក្ដីលែងលះអាចជា ការបែងចែកអ្នកមានអំណាចមេបា ការផ្ដល់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ការបែងចែកទ្រព្យសម្បត្តិជាដើម។ ចំណុចវិវាទមានលក្ខណៈស្មុគស្មាញផង និងមិនមានលក្ខណៈស្មុគស្មាញផង ដោយមានចំណុចខ្លះ តុលាការមិនចាំបាច់កំណត់ពីមូលហេតុ ដែលលើកឡើងនៅក្នុងចំណុចវិវាទឱ្យចំចំណុចនោះទេ ដោយគ្រាន់តែចោទសួរអំពីបញ្ហាជុំវិញនៃបណ្ដឹងបានហើយ។ រីឯចំណុចខ្លះទៀត ត្រូវតែកំណត់ឱ្យនូវចំណោទបញ្ហា ឬមូលហេតុនៃបណ្ដឹងដោយមានលក្ខណៈច្បាស់លាស់ ហើយដើម្បីឆ្លើយតបនឹងគោលបំណងរបស់ដើមបណ្ដឹង។

**៣.២.១.៤. ការរៀបចំពិនិត្យភស្តុតាង**

ការពិនិត្យភស្តុតាងត្រូវធ្វើឡើង តាមការស្នើសុំរបស់ភាគី[90]។ ប៉ុន្តែប្រសិនបើ តុលាការពុំបានសម្រេចថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដែលគូភាគីបានស្នើសុំឱ្យពិនិត្យនោះទេ តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួន[91]។

ការរៀបចំពិនិត្យភស្តុតាង ជាការប្រមូលនូវឯកសារ ការអះអាងរបស់គូភាគី ឬពាក់ព័ន្ធនឹងចំណុចវិវាទដែលត្រូវបំភ្លឺ ដើម្បីធ្វើជាមូលដ្ឋាននៅក្នុងការវិនិច្ឆ័យនៅពេលទាញហេតុផលដោយផ្ទាល់មាត់។ ការរៀបចំពិនិត្យភស្តុតាង មិនមែនជានីតិវិធីពិនិត្យភស្តុតាងនោះទេ ពោលគឺនៅនីតិវិធីសម្រាប់ការទាញហេតុផល អាចធ្វើសកម្មភាពពីរគឺ ការស្នើសុំ និងការសម្រេចទទួលយក ឬមិនទទួលយកចំពោះភស្តុតាងទាំង ០៥ (ប្រាំ) រួមមានការសាកសួរសាក្សី ការសាកសួរពីសាមីភាគី ការធ្វើកោសល្យវិច័យ ភស្តុតាងជាឯកសារ និងការត្រួតពិនិត្យ។ នៅក្នុងនីតិវិធីត្រៀម អាចពិនិត្យភស្តុតាងជាឯកសារ ចំណែកឯកភស្តុតាង ០៤ (បួន) ប្រភេទទៀត មិនអាចពិនិត្យបានទេគឺ ត្រូវពិនិត្យនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[92]។

[89] ការពន្យល់អំពីនីតិវិធីជម្រះក្ដីលើកទី១ (បោះពុម្ពលើកទី២) ឆ្នាំ២០០៩, ទំព័រទី២៨

[90] កថាខណ្ឌទី១ នៃមាត្រា១២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[91] កថាខណ្ឌទី២ នៃមាត្រា១២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[92] ការពន្យល់ពីនីតិវិធីជំនុំជម្រះលើកទី១ (បោះពុម្ពលើកទី២), ទំព័រទី៣៣

បន្ទាប់ពីបានរៀបចំចំណុចវិវាទនៃរឿងក្ដីហើយ តុលាការសួរបញ្ជាក់អំពីលទ្ធផលនៃការរៀបចំនេះ ដើម្បីឱ្យមានការឯកភាពគ្នា និងដើម្បីត្រៀមធ្វើការពិនិត្យលើភស្តុតាងឱ្យបានល្អិតល្អន់ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់[93]។

### ៣.២.២. នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់រួចរាល់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយត្រូវកោះហៅភាគីមកចូលរួម[94]។ ជាគោលការណ៍ដើម្បីចេញសាលក្រមលើបណ្ដឹង តុលាការចាំបាច់ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[95] ហេតុនេះនៅពេលដែលនីតិវិធីសម្រាប់ការត្រៀមទាញហេតុផលបានបញ្ចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម[96]។ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ច្បាប់មិនបានបញ្ញត្តិអំពីអំឡុងពេលប៉ុន្មាននោះទេ ប៉ុន្តែតុលាការត្រូវកំណត់កាលបរិច្ឆេទឱ្យបានឆាប់រហ័ស[97]។ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចមានវត្តមានបាន[98]។ ជាគោលការណ៍ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្ដឹងលែងលះ មិនត្រូវធ្វើជាសាធារណៈឡើយ[99]។

#### ៣.២.២.១. ការថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋម ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[100]។ សេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាសេចក្ដីថ្លែងការណ៍ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានលើកឡើងរួមគ្នាសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីយកមកធ្វើជាមូលដ្ឋាននៃសាលក្រម ដោយចាត់ទុកថាសកម្មភាពទាំងឡាយ ដែលបានធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងតុលាការ។

---

[93] សេចក្ដីកំណត់ចំពោះមាត្រា១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[94] មាត្រា១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[95] មាត្រា១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[96] មាត្រា១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[97] មាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[98] កថាខណ្ឌទី១ នៃមាត្រា១១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[99] កថាខណ្ឌទី១ នៃមាត្រា១៦ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[100] កថាខណ្ឌទី១ នៃមាត្រា១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ពេលធ្វើសេចក្តីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង ដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីអង្គហេតុដែលជាចំណុចវិវាទ និងធ្វើការអះអាងបន្ថែមទៀតអំពីអង្គហេតុ និងដាក់ភស្តុតាងទៀតបាន។

### ៣.២.២.២. ការពិនិត្យភស្តុតាងដោយសមូហវិធី

ការពិនិត្យភស្តុតាងនៅក្នុងរឿងលែងលះ មិនខុសគ្នានឹងការពិនិត្យភស្តុតាងនៅក្នុងរឿងរដ្ឋប្បវេណីទូទៅនោះទេ គឺតុលាការអាចធ្វើការពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[101]។ ការពិនិត្យភស្តុតាងមានដូចជា ការសាកសួរសាក្សី ឬសាមីភាគី និងការពិនិត្យភស្តុតាងជាឯកសារ[102]។ ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយបើយល់ឃើញថាត្រូវការជាចាំបាច់ពិសេស តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបានដោយដីកាសម្រេច[103]។

ជាចុងក្រោយ តុលាការអនុញ្ញាតឱ្យភាគីនីមួយៗ ធ្វើការទាញហេតុផលផ្ទាល់មាត់ជាលើកចុងក្រោយមុនពេលបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់[104]។ ទន្ទឹមនឹងនេះ នៅក្នុងដំណាក់កាលនីតិវិធីទាញហេតុផលផ្ទាល់មាត់ ក្រឡាបញ្ជី មានកាតព្វកិច្ចសំខាន់ក្នុងការកត់ត្រារាល់សកម្មភាព និងហេតុការណ៍ទាំងឡាយជូនតុលាការ។ ក្រឡាបញ្ជីត្រូវកត់ត្រានូវសញ្ញាណនៃរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជីដែលបានចូលរួម រួមជាមួយនឹងឈ្មោះភាគី និងបុគ្គលដែលពាក់ព័ន្ធផ្សេងទៀត ពេលវេលា និងទីកន្លែង។ ក្រុមប្រឹក្សាជំនុំជម្រះត្រូវពិនិត្យលើកំណត់ត្រានោះ រួចហើយធ្វើការចុះហត្ថលេខាផងដែរ[105]។

លើសពីនេះទៅទៀត ក្រឡាបញ្ជីក៏ត្រូវកត់ត្រាបន្ថែមពាក់ព័ន្ធនឹងចំណុចសារជាតុមួយចំនួនដែលមាននៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដូចជា កត់ត្រាអំពីសេចក្តីថ្លែងការណ៍របស់ភាគី សាក្សី និង សកម្មភាពផ្សេងៗទៀតដែលភាគីបានធ្វើអំឡុងពេលនៃនីតិវិធីនោះ[106]។ ចំណែកឯចៅក្រមវិញ ត្រូវកំណត់កាលបរិច្ឆេទមិនឱ្យលើសពី ៣០ថ្ងៃ ដើម្បីធ្វើការប្រកាសសាលក្រម បន្ទាប់ពីបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់[107]។

---

[101] កថាខណ្ឌទី១ នៃមាត្រា១២៧ នាំក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[102] កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា២១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[103] កថាខណ្ឌទី៤ នៃមាត្រា១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[104] កថាខណ្ឌទី៥ នៃមាត្រា១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[105] មាត្រា១១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[106] មាត្រា១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[107] មាត្រា១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

## ៣.៣. ការសម្រេចសេចក្តី

រឿងក្តីលែងលះដោយគ្មានការព្រមព្រៀង ឈានមកដល់នីតិវិធីចុងក្រោយបង្អស់ គឺការចេញនូវសាលក្រមសម្រេចលើបណ្តឹងទាមទារលែងលះ។ អនុលោមតាមស្មារតីនៃច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានបញ្ញត្តិថា ការសម្រេចសេចក្តីលើបណ្តឹងលែងលះ គឺត្រូវសម្រេចដោយការចេញសាលក្រមពីតុលាការ។

### ៣.៣.១.សាលក្រមលែងលះ

ការសម្រេចសេចក្តីនៅក្នុងរឿងលែងលះ គឺមានលក្ខណៈខុសគ្នាពីរឿងក្តីរដ្ឋប្បវេណីធម្មតា ព្រោះនៅក្នុងរឿងក្តីធម្មតាតុលាការត្រូវសម្រេចនូវអ្វីដែលភាគីបានទាមទារ និងមិនចេញសាលក្រមចំពោះមុខចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ[108] ប៉ុន្តែនៅក្នុងបណ្តឹងលែងលះ តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាន នៃសាលក្រមដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ទោះបីជាភាគីមិនបានស្នើសុំឱ្យពិនិត្យពីអង្គហេតុនោះក៏ដោយ[109]។ យ៉ាងណាមិញ ចំពោះបណ្តឹងទាមទារលែងលះ កាលបើតុលាការសម្រេចចេញសាលក្រមលែងលះដល់ភាគី នោះតុលាការត្រូវតែមានកាតព្វកិច្ចក្នុងការកំណត់អំពីអំណាចមេបាលើកូន និងការចាត់ចែងទ្រព្យសម្បត្តិរបស់ភាគីតាមឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងករណីដែលពុំមានពាក្យស្នើសុំពីភាគី[110]។ ត្រង់ចំណុចនេះគួរឱ្យកត់សម្គាល់ និងបានបង្ហាញថាតុលាការមានឆន្ទានុសិទ្ធិលើការសម្រេចដោយពិនិត្យលើការពិតជាក់ស្តែង និងមិនអនុញ្ញាតឱ្យភាគីចាត់ចែងដោយឆន្ទៈរបស់ខ្លួនឡើយ។ ប៉ុន្តែតុលាការត្រូវធ្វើការសម្រេចពីអំណាចមេបានេះ ដោយឆ្លងកាត់ការពិចារណាលើយោបល់របស់កូន និងអាយុកូន[111]។ ចំពោះបណ្តឹងលែងលះក្នុងការម្រេចសេចក្តី តុលាការត្រូវធ្វើការពិចារណានូវចំណុចដូចខាងក្រោម៖

-**នៅក្នុងការទាមទារលែងលះ** មានមូលហេតុ ដូចមានចែងនៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

-**ការសម្រេចអំពីទ្រព្យសម្បត្តិរួម** តុលាការសម្រេចតាមការពិភាក្សារបស់ភាគី ប៉ុន្តែបើក្នុងករណីដែលភាគីមិនអាចពិភាក្សាបានទេនោះ តុលាការបែងចែកដោយសហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១/២ នៃទ្រព្យរួម។ ប៉ុន្តែបើមានករណីពិសេស និងបើមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា៖ ទំហំនៃការបរិច្ចាគ របស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃ

[108] កថាខណ្ឌទី២ នៃមាត្រា១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[109] មាត្រា១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[110] មាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[111] កថាខណ្ឌទី១ នៃមាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

ទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលដែលរួមរស់នៅជាមួយគ្នា ក្នុងចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងជាប្រយោជន៍របស់កូនជាអាទិ៍ គេហកិច្ចមានតម្លៃស្មើគ្នានឹងការងារក្រៅផ្ទះផងដែរ[112]។

**-ការសម្រេចអំពីអំណាចមេបា** ក្នុងករណីដែលសព័ទ្ធមានកូនជាអនីតិជន នៅពេលដែលឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ[113]។ ប្រសិនបើឪពុកម្តាយមិនអាចស្វែងរកដំណោះស្រាយតាមរយៈការជជែកពិភាក្សាបានទេ គឺតុលាការត្រូវធ្វើជាអ្នកសម្រេច ហើយតុលាការត្រូវសម្រេចយកផលប្រយោជន៍របស់កូនជាធំ។ អ្នកទទួលសិទ្ធិគ្រប់គ្រងកូននោះទៀត គឺប្រាកដជាត្រូវឱ្យទៅឪពុក ឬម្តាយម្ខាងទៀត ដែលមានការងារធ្វើជាប់លាប់ជាង មានផ្ទះសម្បែងត្រឹមត្រូវ មានអត្តចរឹកសមរម្យ និងមានការយកចិត្តទុកដាក់ក្នុងការបីបាច់ថែរក្សាកូន។

**-ការសម្រេចអំពីសោហ៊ុយចាំបាច់ដើម្បីទទួលបន្ទុកគ្រប់គ្រង និងថែរក្សាកូន** ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព ឬស្ថានភាពសេដ្ឋកិច្ចរបស់ភាគីម្ខាងទៀតដែលពុំមានអំណាចមេបា[114]។

**-ការជួបប្រាស្រ័យទាក់ទងរបស់អ្នកគ្មានអំណាចមេបា** នៅក្នុងចំណុចនេះ តុលាការត្រូវសម្រេចអំពីរបៀបចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ចំពោះអ្នកដែលគ្មានអំណាចមេបាលើកូន ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព។

**-ការសម្រេចអំពីអាហារកាតព្វកិច្ច** ករណីមួយចំនួន នៅពេលដែលមានការលែងលះ បើករណីដែលភាគីម្ខាងទៀត គ្មានកំហុស ហើយមានការខ្វះខាត អាចស្នើសុំអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបាន។ ភាគីខាងក្រោយនេះ ត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ កំរិតអាហារកាតព្វកិច្ចត្រូវសម្រេចតាមការយល់ព្រមរបស់ភាគីទាំងសងខាង។ តុលាការត្រូវកំណត់អាហារកាតព្វកិច្ចនេះ ក្នុងករណីដែលដែលគូភាគីទាំងសងខាងមិនឯកភាពគ្នា។ ប៉ុន្តែបើជនដែលទទួលអាហារកាតព្វកិច្ចរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជននោះឈប់មានសិទ្ធិទទួលអាហារកាតព្វកិច្ចទៀតហើយ[115]។

**-ការសម្រេចអំពីប្រាក់ប្រដាប់ក្តី** យោងតាមមាត្រាមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ បានបញ្ញត្តិថា បន្ទុកប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី តែបើមានការពិភាក្សារវាងភាគីទាំង

[112] មាត្រា៩៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[113] កថាខណ្ឌទី១ នៃមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[114] កថាខណ្ឌទី៦ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[115] មាត្រា៧៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧

សងខាង នោះភាគីណាក៏អាចជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី[116]។ តុលាការត្រូវសម្រេច អំពីករណីយកិច្ចទទួលបន្ទុក ប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ[117]។

**៣.៣.២.ទម្រង់នៃសាលក្រមលែងលះ**

នៅពេលដែលខ្លឹមសារនៃសាលក្រមត្រូវបានបង្កើតឡើង ខ្លឹមសារដែលតុលាការសម្រេច ត្រូវសរសេរនៅក្នុងលិខិតសាលក្រម ដែលមានទម្រង់ដូចខាងក្រោម[118]៖

-តុលាការ

-ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

-ឈ្មោះ និងអាសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

-អង្គហេតុ និងចំណុចវិវាទ ត្រូវសរសេរខ្លឹមសារសំខាន់ៗ ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ភាគី

-នៅក្នុងលិខិតសាលក្រម ត្រូវមានចុះហត្ថលេខារបស់ចៅក្រម ដែលបានចេញសាលក្រមនោះ។

ក្រៅពីចំណុចចាំបាច់សរសេរក្នុងលិខិតសាលក្រម ដែលបានរៀបរាប់ដូចខាងលើនេះ តុលាការត្រូវសរសេរអំពីចំណុចផ្សេងទៀតដូចជា លេខសំណុំរឿង ប្រភេទនៃសាលក្រមជាដើម។ បើមិនបានសរសេរចំណុចចាំបាច់ណាមួយ នាំឱ្យខុសទម្រង់សាលក្រម[119]។

**៣.៣.៣. ការប្រកាសសាលក្រម**

បន្ទាប់ពីបានធ្វើលិខិតសាលក្រម តុលាការត្រូវធ្វើការប្រកាសសាលក្រម។ សាលក្រមមានអានុភាពដោយការប្រកាស[120]។ ការប្រកាសសាលក្រម ត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់[121]។ ការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងរឿងលែងលះមិនត្រូវបានធ្វើឡើងជាសាធារណៈបានឡើយ ដូចនេះការប្រកាសសាលក្រមត្រូវ ក៏ត្រូវធ្វើឡើងជាអសាធារណៈ[122]។

---

[116] មាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[117] កថាខណ្ឌទី៣ នៃមាត្រា១៨២ នៃក្រមនីតិតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[118] មាត្រា១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[119] សេចក្តីកំណត់ចំពោះមាត្រា១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[120] មាត្រា១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[121] កថាខណ្ឌទី១ នៃមាត្រា១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[122] មាត្រា១៦ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

#### ៣.៣.៤. ការចូលជាស្ថាពរនៃសាលក្រម

សាលក្រមនឹងមិនអាចចូលជាស្ថាពរ នៅមុនពេលផុតអំឡុងពេលដែលបានលកំណត់សម្រាប់ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលស្របច្បាប់ ឬការប្តឹងទាស់ដែលស្របច្បាប់បានទេ[123]។ ការចូលជាស្ថាពរនៃសាលក្រមនឹងត្រូវបានបង្អាក់ ដោយការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ឬពាក្យបណ្តឹងទាស់ ដែលត្រូវបានធ្វើ[124]។

### ៣.៤. អានុភាពនៃការលែងលះដោយគ្មានការព្រមព្រៀង

នៅពេលដែលសាលក្រមលែងលះចូលជាស្ថាពរហើយ នាំឱ្យសេចក្តីសម្រេចនោះបង្កើតអានុភាពដល់ភាគីដែលសម្រេចលែងលះនោះ។ អានុភាពនៃការលែងលះមានដូចជា ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត និងសិទ្ធិនិងកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះ។

#### ៣.៤.១. ការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត

ចំពោះការលែងលះដោយគ្មានការព្រមព្រៀងក៏មិនខុសពីការលែងលះដោយការព្រមព្រៀងដែរ នៅពេលដែលសាលក្រមលែងលះចូលជាស្ថាពរ នោះនឹងធ្វើឱ្យមានការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្ត ដែលការកាត់ផ្តាច់ទំនាក់ទំនងទាំងនោះរួមមាន ការកាត់ផ្តាច់ចំណងគតិយុត្តរវាងសហព័ទ្ធ និងការកាត់ផ្តាច់ទំនាក់ញាតិពន្ធ។

#### ៣.៤.២. សិទ្ធិ និងកាតព្វកិច្ចដែលបន្សល់ក្រោយការលែងលះ

ទោះបីជាចំណងអាពាហ៍ពិពាហ៍ ត្រូវបានបញ្ចប់ដោយការលែងលះក៏ដោយ ប៉ុន្តែអានុភាពនៃការលែងលះបានបន្សល់ទុកនូវសិទ្ធិ និងកាតព្វកិច្ចដល់គូភាគីដដែល។

##### ៣.៤.២.១. សិទ្ធិដែលបន្សល់ទុកក្រោយការលែងលះ

សិទ្ធិដែលបន្សល់ទុកក្រោយការលែងលះរួមមាន សិទ្ធិទទួលបានអត្តាធីនភាព សិទ្ធិក្នុងការប្រើប្រាស់នាមត្រកូល សិទ្ធិលើអំណាចមេបា សិទ្ធិលើទ្រព្យសម្បត្តិ និងសិទ្ធិក្នុងការបង្កើតអាពាហ៍ពិពាហ៍ថ្មី។ នៅក្នុងរឿងលែងលះដោយគ្មានការព្រមព្រៀង ការបែងចែកសិទ្ធិជាទូទៅតុលាការនឹងបែងចែកតាមឆន្ទៈព្រមព្រៀងរបស់ភាគី ក៏ប៉ុន្តែប្រសិនបើសិទ្ធិទាំងនោះភាគីមិនបានបែងចែកទេ ឬ ភាគីមិនអាចពិភាក្សាគ្នាបានជោគជ័យលើការបែងចែកសិទ្ធិ នោះតុលាការនឹងធ្វើការបែងចែកសិទ្ធិទាំងនោះទៅឱ្យភាគីតាមមូលដ្ឋានច្បាប់។ យ៉ាងណាមិញចំពោះសិទ្ធិលើអំណាចមេបា និងសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលភាគីមិនអាចធ្វើការពិភាក្សាគ្នាបាន ឬមិនបានធ្វើការទាមទារទេ តុលាការនឹងធ្វើការសម្រេចទៅការកំណត់របស់ច្បាប់។ ដោយឡែកសិទ្ធិនូវក្នុងការប្រើប្រាស់នាមត្រកូលនៅក្រោយការលែងលះចំពោះការលែងលះដោយគ្មានការព្រមព្រៀង ក៏មិនខុសគ្នាពីការលែងលះ

[123] កថាខណ្ឌទី១ នៃមាត្រា១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[124] កថាខណ្ឌទី២ នៃមាត្រា១៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ដោយការព្រមព្រៀងដែរ គឺអាស្រ័យទៅលើភាគី ដោយភាគីដែលបានប្រើប្រាស់នាមត្រកូលរបស់សហព័ទ្ធ អាចបន្តប្រើប្រាស់នាមត្រកូលដែលបានផ្លាស់ប្តូរនៅក្រោយរៀបអាពាហ៍ពិពាហ៍នោះដដែរ ឬអាចផ្លាស់ប្តូរនាមត្រកូលថ្មីនោះទៅនាមត្រកូលនៅមុនពេលរៀបអាពាហ៍ពិពាហ៍វិញក៏បាននៅពេលលែងលះ។

**គ. សិទ្ធិលើអំណាចមេបា**

នៅក្រោយការលែងលះ តុលាការនឹងសម្រេចអំពីអំណាចមេបាទៅលើកូនឱ្យភាគីណាម្ខាងជាអ្នកមានអំណាចមេបា អាចជាឪពុក ឬម្តាយ។ ការប្រគល់អំណាចមេបា គឺជាការប្រគល់សិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ថែរក្សា អប់រំកូន ទៅភាគីណាមួយក្រោយពីគូភាគីបានលែងលះគ្នា។ នៅក្នុងការលែងលះដោយគ្មានការព្រមព្រៀង ភាគីអាចធ្វើការពិភាក្សាគ្នាអំពីការបែងចែកអំណាចមេបាបាននៅពេលលែងលះ។ ផ្ទុយទៅវិញប្រសិនបើឪពុក និងម្តាយពុំមានការព្រមព្រៀងគ្នាសម្រេចបែងចែកអំណាចមេបាទេ ភាគីត្រូវទាមទារអំណាចមេបានេះតាមរយៈការទាមទារបន្ទាប់បន្សំនៅក្នុងបណ្តឹងលែងលះ ហើយទុកឱ្យតុលាការធ្វើការសម្រេចអំពីអ្នកដែលមានអំណាចមេបាចំពោះកូន។ តុលាការនឹងសម្រេចឱ្យភាគីមានអំណាចមេបា ដោយពិចារណាលើផលប្រយោជន៍របស់កូន[125]។ ប៉ុន្តែប្រសិនបើកូនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹង និងមានការសម្រេចចិត្តផ្ទាល់ខ្លួនសមស្របក្នុងការសម្រេចចិត្ត តុលាការនឹងធ្វើការសម្រេចតាមឆន្ទៈរបស់កូន[126]។

បន្ថែមពីនេះទៀត ចំពោះការលែងលះដោយការគ្មានការព្រមព្រៀងក៏មិនខុសពីការលែងលះដោយការព្រមព្រៀងដែរ ឪពុក ឬ ម្តាយដែលពុំទទួលបានអំណាចមេបាលើកូនតាមការសម្រេចរបស់តុលាការក្រោយការលែងលះ អាចធ្វើការពិភាក្សាអំពីសិទ្ធិក្នុងការចូលជួបប្រាស្រ័យទាក់ទងគ្នាជាមួយកូន និងករណីយកិច្ចលើសោហ៊ុយចាំបាច់សម្រាប់កូនពីភាគីដែលមិនមានអំណាចមេបា[127]។ ប៉ុន្តែប្រសិនការពិភាក្សាអំពីការកំណត់វិធីនៃការណាត់ជួបកូន និងករណីយកិច្ចលើសោហ៊ុយចាំបាច់កូនពុំបានលទ្ធផលសម្រេចទេ នោះតុលាការត្រូវសម្រេចកំណត់អំពីវិធីនៃការចូលជួប និងករណីយកិច្ចទាំងនោះ[128]។ ដូច្នេះការលែងលះមានអានុភាពត្រឹមតែកាត់ផ្តាច់ទំនាក់ទំនងរវាងសហព័ទ្ធប៉ុណ្ណោះ ក៏ប៉ុន្តែការលែងលះមិនបានកាត់ផ្តាច់ទំនាក់ទំនងរវាងឪពុក ឬ ម្តាយជាមួយនឹងកូនៗទេ។ អានុភាពនៃការលែងលះនៅតែផ្តល់សិទ្ធិអំណាចមេបាដល់ភាគីឪពុក ឬ ម្តាយ តាមឆន្ទៈតែភាគីបានព្រមព្រៀងគ្នា ឬ តាមការឆន្ទៈរបស់កូន ឬ តាមការសម្រេចដោយតុលាការ។

---

[125] មាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[126] មាត្រា១០៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[127] កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា១០៤០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[128] កថាខណ្ឌទី៤ នៃមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

គួរបញ្ជាក់ផងដែរថា នៅពេលដែលតុលាការធ្វើការដោះស្រាយលើបណ្ដឹងលែងលះ ទោះបីជាភាគីនៃបណ្ដឹងលែងលះ មិនបានទាមទារអំណាចមេបា វិធីចូលជួបប្រាស្រ័យទាក់ទងកូន និងបន្ទុកលើសោហ៊ុយចាំបាច់គ្រប់គ្រងថែរក្សាកូននៅក្នុងបណ្ដឹងលែងលះក៏ដោយ ក៏តុលាការមានសិទ្ធិក្នុងការសម្រេចដោយឆន្ទានុសិទ្ធិផងដែរ[129]។

**ខ. សិទ្ធិលើទ្រព្យសម្បត្តិ**

ពាក់ព័ន្ធនឹងសិទ្ធិលើទ្រព្យសម្បត្តិនេះ ភាគីក៏មានសិទ្ធិក្នុងការពិភាក្សាគ្នាលើការបែងចែកទ្រព្យ ដូចការពិភាក្សាលើការបែងចែកអំណាចមេបាដែរ។ ក្នុងករណីដែលភាគីមានការព្រមព្រៀងគ្នា លើការបែងចែកទ្រព្យនោះតុលាការនឹងសម្រេចទៅតាមឆន្ទៈរបស់ភាគី។ ប៉ុន្តែផ្ទុយមកវិញ ប្រសិនបើភាគីដែលលែងលះមិនអាចធ្វើការពិភាក្សាគ្នាបានសម្រេចលើការបែងចែកទេ ឬភាគីមិនបានធ្វើការទាមទារឱ្យមានការបែងចែកទ្រព្យសម្បត្តិទេ នាំឱ្យការបែងចែកនេះនឹងត្រូវបានសម្រេចដោយតុលាការ។ យោងតាមមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានផ្ដល់អំណាចដល់តុលាការ ដើម្បីសម្រេចបែងចែកទ្រព្យសម្បត្តិជំនួសការព្រមព្រៀងរបស់ភាគីតាមវិធី ០៣ (បី) យ៉ាងដូចតទៅ៖

**ទី១ សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែក** ៖ ទ្រព្យសម្បត្តិដោយឡែកមានដូចជា[130]៖

-ទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។

-ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។

-ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។

**ទី២ មានសិទ្ធិទទួលយកពាក់កណ្ដាលនៃទ្រព្យសម្បត្តិរួម** ៖ បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក១ ភាគ២ នៃទ្រព្យសម្បត្តិរួមដែលសហព័ទ្ធបានរកស៊ីជាមួយគ្នា។

**ទី៣ ការបែងចែកទ្រព្យសម្បត្តិរួមដោយករណីពិសេស** ៖ ក្នុងករណីពិសេស និងមានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ

[129] មាត្រា២២ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

[130] មាត្រា៩៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។ ការងារនៃគេហកិច្ចត្រូវចាត់ថាមានតម្លៃស្មើនឹងការងារក្រៅផ្ទះដែរ[131]។

### ៣.៤.២.២. កាតព្វកិច្ចដែលបន្សល់ទុកក្រោយការលែងលះ

ក្រៅពីសិទ្ធិដូចដែលបានរៀបរាប់ខាងលើ ក្រោយការលែងលះក៏បន្សល់ទុកនូវកាតព្វកិច្ចមួយចំនួនផងដែរ ហើយកាតព្វកិច្ចដែលបន្សល់ទុកក្រោយការលែងលះដោយការគ្មានការព្រមព្រៀង មានលក្ខណៈខុសពីការលែងលះដោយការព្រមព្រៀងបន្តិចត្រង់ថាបន្ថែមពីការបញ្ចប់ករណីយកិច្ចសហព័ទ្ធ និងកាតព្វកិច្ចចំពោះតតិយជន បន្ទាប់ពីការលែងលះក៏អាចបន្សល់ទុកនូវកាតព្វកិច្ចសងជម្ងឺចិត្ត ក៏ដូចជាកាតព្វកិច្ចបង់អាហារកាតព្វកិច្ចផងដែរ។ ចំពោះការបញ្ចប់ករណីយកិច្ចសហព័ទ្ធ និងករណីយកិច្ចចំពោះតតិយជន មិនខុសពីករណីយកិច្ចនៅក្នុងការលែងលះដោយការព្រមព្រៀងដែរ នៅក្រោយការលែងលះ ករណីយកិច្ចសហព័ទ្ធដែលធ្លាប់មានពីមុនក៏ត្រូវបញ្ចប់ដូចគ្នា ប៉ុន្តែទោះបីជាចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ក៏ដោយ ក៏ភាគីទាំងពីរនៅតែត្រូវមានកាតព្វកិច្ចទទួលខុសត្រូវចំពោះតតិយជន ដែលជាម្ចាស់បំណុលលើបំណុលទាំងឡាយណា ដែលបានជំពាក់នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយក្នុងករណីបំណុលនោះជាបំណុលដោយឡែក នោះភាគីម្ខាងៗត្រូវទទួលខុសត្រូវលើបំណុលនោះរៀងៗខ្លួន។ ។

#### ក. កាតព្វកិច្ចសងជំងឺចិត្តអាចកើតមាន

សំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ត្រូវបានទទួលស្គាល់នៅក្នុងករណីលែងលះ និងអាចទាមទារនៅក្នុងបណ្ដឹងលែងលះបាន[132]។ ក្នុងករណីលែងលះ ភាគីដែលគ្មានកំហុស ហើយត្រូវបានភាគីម្ខាងទៀតបំពាន ភាគីដែលទទួលរងនូវការបំពានអាចទាមទារសំណងនៃការខូចខាតបាន។

ឧទាហរណ៍៖ ប្ដី បានប្រព្រឹត្តអំពើជិត បានជេរប្រមាថ និងវាយតប់ B បណ្ដោយឱ្យ B ទទួលរងរបួសជាទម្ងន់ ដោយត្រូវចំណាយប្រាក់ថ្លៃព្យាបាលអស់ ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារ ហើយ B ទទួលរងនូវសម្ពាធផ្លូវចិត្តយ៉ាងខ្លាំង ក្នុងករណីនេះ B អាចទាមទារនូវសំណងខូចខាតចំពោះ A បានទាំងសំណងខូចខាតផ្នែកសម្ភារៈ និងផ្លូវចិត្ត។

#### ខ. កាតព្វកិច្ចបង់អាហារកាតព្វកិច្ច

ការទាមទារអាហារកាត្វកិច្ចក្នុងករណីលែងលះពុំមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ទេ ប៉ុន្តែមានបញ្ញត្តិមាត្រា ៧៦ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៧ បានទទួលស្គាល់ការទាមទារអាហារកាតព្វកិច្ច ហើយបញ្ញត្តិនេះនៅមានអានុភាពអនុវត្តនៅឡើយ តាមរយៈមាត្រា ៧៨ នៃច្បាប់ស្ដីពីការអនុវត្តក្រម

---

[131] មាត្រា៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[132] មាត្រា១១ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលឆ្នាំ២០១០

រដ្ឋប្បវេណី។ អាហារកាតព្វកិច្ច គឺសំដៅដល់កិច្ចដែលត្រូវបំពេញតាមច្បាប់ ឬ តាមសេចក្ដីសម្រេចរបស់តុលាការ ដែល តម្រូវឱ្យបុគ្គលណាម្នាក់ ឬ ច្រើននាក់ត្រូវបង់ប្រាក់ ឬ ទ្រព្យដើម្បីទៅផ្គត់ផ្គង់ជីវភាពរស់នៅ របស់បុគ្គលផ្សេងទៀត ដែលបុគ្គលនោះមានទំនាក់ទំនងញាតិនឹងគ្នា[133]។ អាហារកាតព្វកិច្ចនៅក្នុងការលែងលះ ភាគីអាចធ្វើការពិភាក្សាព្រមព្រៀងគ្នាលើកាតព្វកិច្ចនេះ ក៏ប៉ុន្តែប្រសិនបើភាគីមិនអាចពិភាក្សាលើការបែងចែកកាតព្វកិច្ចនេះបានសម្រេចទេ ភាគីអាចដាក់ជាចំណុចទាមទារបន្ទាប់បន្សំក្នុងបណ្ដឹងលែងលះ ហើយឱ្យតុលាការធ្វើការសម្រេចឱ្យបាន[134]។ ការទាមទារអាហារកាតព្វកិច្ចត្រូវបានទទួលស្គាល់ លុះត្រាតែភាគីគ្មានកំហុស ហើយមានការខ្វះខាតនៅក្នុងជីវភាពរស់នៅអាចទាមទារអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបាន។

ឧទាហរណ៍ ៖ លោក ក បានមានស្នេហាលួចលាក់ជាមួយនារី គ អស់រយៈពេលជាង ២ ឆ្នាំ រឿងនេះបានធ្វើឱ្យនារី ខ ដែលជាប្រពន្ធបានដឹង និងខឹងយ៉ាងខ្លាំង ហើយបានដាក់ពាក្យបណ្ដឹងទាមទារលែងលះ ប៉ុន្តែនារី ខ ពុំមានមុខរបរអ្វី ហើយក៏ពុំមានទ្រព្យសម្បត្តិដោយឡែកដែរ ក្នុងករណីនេះនារី ខ ដែលជាប្រពន្ធ អាចទាមទារឱ្យលោក ក បង់អាហារកាតព្វកិច្ចមកឱ្យខ្លួន។

ដូចនេះបន្ទាប់ពីបានសិក្សាជំពូកទី១ សញ្ញាណនៃការលែងលះ ជំពូកទី២ ការលែងលះដោយមានការព្រមព្រៀង និងជំពូកទី៣ ការលែងលះដោយគ្មានការព្រមព្រៀង ខាងលើនេះរួចមក យើងអាចធ្វើសេចក្ដីសន្និដ្ឋានជារួមមួយនៅចំណុចជាបន្តទៀត។

[133] សន្ទានុក្រមលេខ២០២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[134] មាត្រា១១៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយ និងការបង្ហាញអំពីការលែងលះនៅកម្ពុជា អាចធ្វើឱ្យយើងមានចំណេះដឹង និងការយល់ដឹងអំពីការលែងលះបានច្រើនជាងមុន។ ការលែងលះ អាចធ្វើឡើងតាមពីររបៀប គឺការលែងលះដោយការព្រមព្រៀងដែលមានបញ្ញត្តិនៅក្នុងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងការលែងលះតាមបណ្តឹង ឬការលែងលះដោយគ្មានការព្រមព្រៀង ដែលមានបញ្ញត្តិនៅក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ទោះបីជាប្រព័ន្ធច្បាប់កម្ពុជា ទទួលស្គាល់ការលែងលះដោយការព្រមព្រៀងក៏ដោយ នីតិវិធីនៃការលែងលះត្រូវតែធ្វើតាមផ្លូវតុលាការ ប៉ុន្តែរវាងការលែងលះដោយការព្រមព្រៀង និងការលែងលះតាមបណ្តឹង គឺមានមូលហេតុ និងនីតិវិធីខុសគ្នា។ ការលែងលះដោយការព្រមព្រៀង កំណត់យកការព្រមព្រៀងមកធ្វើជាមូលហេតុនៃការលែងលះ ហើយការសម្រេចអំពីការលែងលះ ត្រូវអនុលោមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងក្រោមរូបភាពជាដីកាសម្រេច។ ចំណែកឯការលែងលះដោយគ្មានការព្រមព្រៀង ឬការលែងលះតាមបណ្តឹង កំណត់យកមូលហេតុដែលមានបញ្ញត្តិនៅក្នុងមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មកធ្វើជាមូលហេតុនៃការលែងលះ ហើយនីតិវិធីនៃការលែងលះ ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្រោមរូបភាពជាសាលក្រម។

ការលែងលះ គឺជាបញ្ហារបស់សង្គមគ្រួសារ ដែលបណ្តាលឱ្យភាគីដែលជាសហព័ទ្ធនឹងគ្នា ព្រមទាំងស្ថាប័នមានសមត្ថកិច្ចលើរឿងនេះ ត្រូវប្រឈមមុខនឹងភាពស្មុគស្មាញជាច្រើន។ លើសពីនេះទៀត ការលែងលះ អាចជះឥទ្ធិពលដល់ការអភិវឌ្ឍន៍របស់សង្គមជាតិ ដោយសារតែវាបានលាតត្រដាងពីភាពមិនចុះសម្រុងគ្នារវាងប្តីប្រពន្ធនៅក្នុងសង្គមជាតិមួយ។ ម្យ៉ាងទៀតនោះ ការលែងលះបានធ្វើឱ្យប្តីប្រពន្ធទាំងសងខាងខាតបង់ប្រាក់កាក់បូករួមទាំងការចំណាយពេលវេលាប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត ដែលជាកត្តាអវិជ្ជមានមួយ ធ្វើឱ្យរាំងស្ទះដល់ដំណើរការការងារ និងវឌ្ឍនភាពនៅក្នុងគ្រួសារ។

ទន្ទឹមនឹងនេះដែរ កូនៗដែលមានឪពុកម្តាយលែងលះគ្នា ក៏ទទួលនូវការប៉ះទង្គិចជាច្រើនទាំងផ្នែកស្មារតី និងផ្នែកសម្ភារៈ។ ជាក់ស្តែងនៅពេលដែលឪពុកម្តាយរវល់ប្តឹងផ្តល់គ្នាដោយមិនទុកពេលវេលាចិញ្ចឹមបីបាច់ ថែរក្សាអប់រំកូន ហើយក៏មិនខិតខំរកប្រាក់ចំណូលដើម្បីមកបំពេញតម្រូវការរបស់កូន មុខជាកូននោះត្រូវរងទុក្ខវេទនាជាក់ជាមិនខាន។ តួយ៉ាងភាពងប់ងល់នឹងការចង់ឈ្នះចាញ់ ដោយសារតែសាលក្រមមួយសន្លឹក មានអានុភាពយ៉ាងធ្ងន់ធ្ងរលើកូនដែលអាចឱ្យកូននោះ ក្លាយជាក្មេងបាត់បង់ភាពកក់ក្តៅពីឪពុកម្តាយ គ្មានការអប់រំ ណែនាំប្រៀនប្រដៅ រហូតដល់អាចធ្វើឱ្យកូននោះរៀនមិនចូលព្រមទាំងប្រឈមនឹងការដើរផ្លូវខុស។

ទោះបីជាការលែងលះបានបន្សល់ទុកនូវផលវិបាកច្រើនក្តី ក៏ការកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍មានគុណសម្បត្តិខ្លះដែរចំពោះស្ថានភាពមួយចំនួន។ ឧទាហរណ៍ជាក់ស្តែង ក្នុងករណីដែលគ្រួសារមួយ ដែលមាន

ស្វាមី ឬ ភរិយាដែលជាបុគ្គលគ្មានសតិសម្បជញ្ញៈក្នុងខ្លួន ពាលា អាវាសែ ស្រីញី អូនបង លេងល្បែងស៊ីសង សេពគ្រឿងញៀន គ្រឿងស្រវឹង ជាអាទិ៍ នោះក៏មិនអាចស្តារឱ្យគ្រួសារនោះគង់វង្សរុងរឿងនោះឡើយ។ ការដែលមានមនុស្សជំពូកនេះ មិនត្រឹមតែមិនខិតខំរកប្រាក់កម្រៃ ដើម្បីយកមកផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារប៉ុណ្ណោះទេ ថែមទាំងបានបំផ្លាញលុយកាក់ ទ្រព្យសម្បត្តិ ធ្វើឱ្យគ្រួសារធ្លាក់ដុនដាប បាត់បង់ កិត្តយស អំពើហិង្សា និងអាចជាគំរូអាក្រក់ដល់កូន និងសង្គមជាតិទៀតផង។ ដូចនេះការលែងលះ គឺជាវិធីល្អបំផុតសម្រាប់ភាគីរងគ្រោះ ដែលអាចអនុញ្ញាតឱ្យគេស្វែងរកនូវជីវិតថ្មីដ៏ភ្លឺស្វាងមួយ និងជៀសខ្លួនឆ្ងាយពីទុក្ខវេទនាផ្សេងៗ។

បុច្ចុប្បន្ន នីតិវិធីនៃការលែងលះមានភាពងាយស្រួល និងមានលក្ខណៈបើកទូលាយហើយសាធារណជនទូទៅស្ទើរតែគិតថា ការលែងលះប្តីប្រពន្ធ ជារឿងធម្មតាហើយ ដែលជាកត្តាសត្យានុម័តៗ ទោះបីយើងសន្និដ្ឋានបានថាប្រជាពលរដ្ឋខ្មែរយើង ជាពិសេសស្ត្រីមានការយល់ដឹងច្រើនទៅលើការទទួលបានសិទ្ធិក្នុងរឿងលែងលះនេះក្តី ក៏យើងអាចវិនិច្ឆ័យជារួមបានថាការកើនឡើងនៃការលែងលះមិនមែនជារឿងល្អនោះទេនៅក្នុងសង្គមកម្ពុជានាពេលសព្វថ្ងៃនេះ។ កាលណាសកម្មភាពនៃការលែងលះកាន់តែមានច្រើនករណីនោះ កាន់តែបន្ថែមបន្ទុកទៅស្ថាប័នតុលាការ ហើយក៏វាហាក់បីដូចជាការបង្ហាញពីភាពរង្គោះរង្គើ ភាពខ្វះការអត់ឱន អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក។ ដោយឡែក គ្រួសារដែលទទួលអានុភាពនៃសាលក្រមលែងលះ នោះសមាជិកក្នុងគ្រួសារនោះហាក់បីដូចជា បាក់ស្លាបម្ខាង និង ធ្វឱ្យគ្រួសារបាត់បង់លំនឹង និងសុភមង្គល។

សរុបសេចក្តីមក កូនកម្លោះ កូនក្រមុំ គប្បីស្វែងយល់ពីគ្នាឱ្យបានច្បាស់ មុននឹងសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ មានន័យថាបុរស និងនារីដែលមានបំណងរៀបអាពាហ៍ពិពាហ៍នឹងគ្នា គួរតែធ្វើការសិក្សាពីគ្នាទៅវិញទៅមករវាងសាមីខ្លួនទាំងពីរ រួមទាំងបរិបទសង្គមគ្រួសារទាំងសងខាងផងដែរ ជៀសវាងការមិនអាចទទួលយកបានត្រង់ចំណុចណាមួយ ដែលជាហេតុនៃរឿងរ៉ាវនាំឱ្យឈានទៅដល់ការលែងលះគ្នានៅពេលក្រោយ។

# អនុសាសន៍

បន្ទាប់ពីឆ្លងកាត់តាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ការលែងលះនៅកម្ពុជាបច្ចុប្បន្ន ខាងលើរួចមក យើងខ្ញុំឃើញថាការអនុវត្តច្បាប់ទាក់ទងទៅនឹងការលែងលះនៅកម្ពុជា គឺមានភាពខ្វះចន្លោះនៅឡើយ ដែលជាមូលហេតុនាំឱ្យមានបញ្ហាប្រឈមនៃការលែងលះកើតឡើង ដូចនេះយើងខ្ញុំសូមអនុញ្ញាតសំណូមពរ និងផ្តល់មតិយោបល់ផ្ទាល់ខ្លួន ដើម្បីចូលរួមជាគំនិតក្នុងការលើកស្ទួយ និងកែប្រែវិស័យយុត្តិធម៌ឱ្យមានភាពប្រសើរឡើង។

-គប្បីមានការវិសោធនកម្ម ឬកែប្រែពាក្យណាមួយឱ្យមានភាពឯកភាពគ្នា ៖ យើងសង្កេតឃើញបញ្ហាពាក់ព័ន្ធជាមួយច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ចំពោះការប្រើប្រាស់ពាក្យពេចន៍ គឺមិនភាពច្បាស់លាស់នៅឡើយ និងមិនទាន់មានសុពលភាពគតិយុត្តនៅឡើយ។ តួយ៉ាងនៅក្នុងមាត្រា១៥ នៃច្បាប់ស្តីពីរឿងក្តីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០ ប្រើពាក្យជនដាក់ពាក្យសុំ រីឯមាត្រា២៦ នៃច្បាប់នេះដដែរប្រើពាក្យអ្នកដាក់ពាក្យសុំ។ តើជនដាក់ពាក្យសុំ និងអ្នកដាក់ពាក្យសុំ ខុសគ្នាបែបណា? តើយើងគួរប្រើមួយណា? ដូចនេះគប្បីមានការវិសោធនកម្ម ឬកែប្រែពាក្យណាមួយឱ្យមានភាពឯកភាពគ្នា ដើម្បីងាយស្រួលក្នុងការសិក្សា ក៏ដូចជាការអនុវត្ត។

-គប្បីព្យាយាមធ្វើការផ្សះផ្សារឱ្យអស់ពីលទ្ធភាព ៖ មន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ គួរតែបន្តពង្រឹងទៅលើការផ្សះផ្សាគូភាគី ដែលមានបំណងលែងលះគ្នានោះឱ្យមានការត្រូវរ៉ូវគ្នាវិញ។ ចំណែកឯដំណាក់កាលផ្សះផ្សានៅតុលាការវិញ តុលាការ គួរតែរិះរកគ្រប់មធ្យោបាយដែលពាក់ព័ន្ធនឹងការផ្សះផ្សាលើគូភាគី ដែលចង់ធ្វើការលែងលះ ដើម្បីឱ្យងាកមកប្តូរចិត្តឈប់ចង់ធ្វើការលែងលះ ហើយងាកមករស់នៅជាមួយគ្នាជាប្តីប្រពន្ធធម្មតាវិញ។

-គប្បីមានការការអត់ឱន អធ្យាស្រ័យគ្នា ៖ ចំពោះប្តីប្រពន្ធ ដើម្បីកុំឱ្យមានការកើតឡើងនៃការលែងលះ និងដើម្បីឱ្យគ្រួសារមួយមានសុភមង្គល គឺលុះត្រាតែភាគីប្តីប្រពន្ធគួរពិចារណាឱ្យបានត្រឹមត្រូវ គួរតែរស់នៅដោយភាពយោគយល់គ្នា ប្តីត្រូវបំពេញកាតព្វកិច្ចជាប្តីល្អ ប្រពន្ធត្រូវបំពេញកាតព្វកិច្ចជាប្រពន្ធល្អ ត្រូវចេះសហការគ្នា សង្គ្រោះគ្នាទៅវិញទៅមកដូចដែលមានចែងនៅក្នុងច្បាប់ បំពេញឱ្យបានគ្រប់ជ្រុងជ្រោយ នោះគ្រួសារនឹងជួបសុខសុភមង្គល។

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

-ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងអនុវត្តទូទាំងប្រទេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

-ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

-ច្បាប់ស្តីពីកាអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១

-ច្បាប់ស្តីពីរឿងរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០

-ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០

-ច្បាប់ស្តីអាពាហ៍ពិពាហ៍ និងគ្រួសារពីដែលប្រកាសឱ្យប្រើ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩

-ច្បាប់ស្តីពីការទប់ស្កាត់អំពីហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥

-អនុក្រឹត្យលេខ ២១ អនក្រ.បក, ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានសាលាដំបូង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦

-អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

-ប្រកាសលេខ២៨ កយប្រក/០៧ នៃទីស្តីការក្រសួងយុត្តិធម៌, ឆ្នាំ២០០៧

-ប្រកាសលេខ៥៤ កយប្រក/០៩ ស្តីពីប្រភេទពាក្យសុំដែលតម្រូវឱ្យបង់ពន្ធ ឆ្នាំ២០០៩

-ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឆ្នាំ២០១៣

## ២.សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗ

-សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

-សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-សៀវភៅពន្យល់អំពីក្រមរដ្ឋប្បវេណី

-សៀវភៅពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី

-សៀវភៅពន្យល់ពីនីតិវិធីជំនុំជម្រះលើកទី១ (បោះពុម្ពលើកទី២)

-សៀវភៅរបាយការណ៍លោកស្រី សំអាត សុខៃ ជាសិស្សក្រឡាបញ្ជីជំនាន់ទី៧ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ៖ កម្រងបទដ្ឋានគតិយុត្ត

- អនុក្រឹត្យស្តីពីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានសាលាដំបូង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦
- ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ២០១៣

## ឧបសម្ព័ន្ធទី២ ៖ ទម្រង់លិខិតបទដ្ឋានពាក់ព័ន្ធនឹងការលែងលះ

- កិច្ចព្រមព្រៀងលែងលះ
- ពាក្យសុំលែងលះតាមការព្រមព្រៀង
- ពាក្យបណ្តឹងលែងលះ
- ដីកាសម្រេចលែងលះតាមការព្រមព្រៀង
- សាលក្រមលែងលះ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### ស ម្រេ ច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងពង្រឹងយន្តការគ្រប់គ្រងការងាររដ្ឋបាលរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង ដើម្បីធានាគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្ដល់សេវា និងបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋក្នុងវិស័យយុត្តិធម៌។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី-ខេត្ត។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ៤.-**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដែលមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ ជាសេនាធិការឱ្យក្រសួងយុត្តិធម៌លើការងារនេះ។

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គឺជាសេនាធិការឱ្យសាលាដំបូង និងអយ្យការអមសាលាដំបូង លើការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងបំពេញការកិច្ចមួយចំនួន ដូចខាងក្រោម ៖

- គ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រាយការណ៍អំពីការងារ បុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជាប្រចាំជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា
- សម្របសម្រួលសកម្មភាពគ្រប់ផ្នែក រវាងសាលាដំបូង និងអយ្យការអមសាលាដំបូង ជាមួយនឹងក្រសួងយុត្តិធម៌
- ទំនាក់ទំនងការងារសាធារណៈ
- បញ្ជូនសាលក្រម និងសេចក្តីសម្រេចនានារបស់សាលាដំបូង ជូនទៅក្រសួងយុត្តិធម៌ឱ្យបានទៀងទាត់
- រៀបចំផែនការសកម្មភាព និងផែនការចាំបាច់ផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រៀបចំផែនការថវិកាផ្សេងៗរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង តាមការណែនាំរបស់ក្រសួងយុត្តិធម៌ និងគោលការណ៍ហិរញ្ញវត្ថុជាធរមាន ហើយត្រូវផ្ញើផែនការទាំងនោះមកក្រសួងយុត្តិធម៌ ដើម្បីប្រមូលផ្តុំ ដាក់ក្នុងកញ្ចប់ថវិការួម
- អនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- អនុវត្តតាមការណែនាំរបស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍លម្អិតនិងដាច់ដោយឡែក ពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុជូនក្រសួងយុត្តិធម៌
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់សាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

- រៀបចំ និងបញ្ជូនរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- បំពេញភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូង ប្រគល់ឱ្យ។

ដើម្បីធានាដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការការងារ លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមាន "ត្រាផ្លូវការ" សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន។

**មាត្រា ៥.-**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងត្រូវមានទំនាក់ទំនង និងកិច្ចសហការល្អជាមួយអាជ្ញាធររដ្ឋបាលដែនដីដែលខ្លួនតាំងនៅ។

**មាត្រា ៦.-**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានការិយាល័យចំណុះចំនួន ០៤(បួន) ដូចខាងក្រោម៖
- ការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- ការិយាល័យកិច្ចការហិរញ្ញវត្ថុ
- ការិយាល័យកិច្ចការតុលាការ
- ការិយាល័យកិច្ចការអយ្យការ។

ការិយាល័យនីមួយៗនៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ការិយាល័យ នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង មានថ្នាក់ស្មើនឹងការិយាល័យថ្នាក់កណ្ដាលនៃក្រសួងយុត្តិធម៌។

អង្គការលេខរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

១. ការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក ទទួលបន្ទុក ៖
- ទទួល និងចាត់ចែងឯកសារចេញ-ចូលរបស់សាលាដំបូង អយ្យការអមសាលាដំបូង និងលេខាធិការ-ដ្ឋានរដ្ឋបាលសាលាដំបូង
- គ្រប់គ្រងការងាររដ្ឋបាលទូទៅ និងការងារបុគ្គលិករបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ទទួល គ្រប់គ្រង ធ្វើចាចរឯកសាររដ្ឋបាលផ្សេងៗ និងរក្សាប្រព័ន្ធសន្តិសុខឯកសារ
- ទទួល និងចុះបញ្ជីពាក្យបណ្ដឹង និងចាត់ចែងបន្តតាមនីតិវិធី
- គ្រប់គ្រងសំណុំរឿងដែលចាត់ការរួច ទិន្នន័យ សាលក្រម និងព្រឹត្តិបត្រ
- គណនាកំណត់ចំនួនប្រាក់ពន្ធដាក់ពាក្យសុំ និងប្រាក់ផ្សេងទៀតតាមច្បាប់កំណត់
- តម្កល់ឯកសាររឿងក្ដីសំណៅដើម និងថតចម្លងឯកសាររឿងក្ដី ជូនអង្គភាពពាក់ព័ន្ធ
- គ្រប់គ្រងព័ត៌មានវិទ្យាសម្រាប់ដំណើរការរដ្ឋបាល និងរដ្ឋបាលនីតិវិធីសំណុំរឿង
- ចាត់ចែង និងសម្របសម្រួលការបញ្ជូនដីកា សាលក្រម ឬលិខិតផ្សេងៗដល់ភាគី និងអ្នកពាក់ព័ន្ធក្នុងរឿងក្ដី ស្របតាមនីតិវិធី
- សម្របសម្រួល និងទំនាក់ទំនងសេវាបកប្រែ និងសេវាចាំបាច់ផ្សេងៗ
- សម្របសម្រួលការក្បោជនល្មើស សាក្សី និងអ្នកពាក់ព័ន្ធ

- គ្រប់គ្រង ថែរក្សាវត្ថុតាងដែលមិនទាន់ចូលជាស្ថាពរ និងសម្របសម្រួលចលនាវត្ថុតាងតាមដំណើរការរឿងក្តី ក្រោមការទទួលខុសត្រូវរបស់សាលាដំបូង ឬអយ្យការអមសាលាដំបូង តាមច្បាប់កំណត់
- គ្រប់គ្រងត្រារបស់លេខាធិការដ្ឋានរដ្ឋបាល
- គ្រប់គ្រង រៀបចំការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យទូទៅ
- គ្រប់គ្រង រៀបចំ ទីតាំង អគារ សួនច្បារ អគ្គិសនី ទឹក និងកែលម្អសោភ័ណភាពផ្សេងៗ
- ផ្តល់ព័ត៌មានអំពីនីតិវិធីបឋមនៃសេវាសាធារណៈដល់សាធារណជន និងអង្គភាពពាក់ព័ន្ធ
- ស្រាវជ្រាវ និងលើកយោបល់ធ្វើទំនើបកម្មអំពីការផ្តល់សេវាយុត្តិធម៌
- រៀបចំ និងគ្រប់គ្រងបណ្ណាល័យ
- ប្រមូលផ្តុំព័ត៌មាន ចងក្រងឯកសារ រូបភាព វីដេអូ និងឯកសារសំខាន់ៗសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ប្រសិទ្ធភាពការងាររបស់អង្គការតុលាការ និងអង្គការអយ្យការ
- ចាត់ចែង សម្របសម្រួល និងសហការបញ្ជូនសាលក្រម សេចក្តីសម្រេច និងឯកសារផ្សេងៗជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមច្បាប់កំណត់
- រៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលា កិច្ចការពិធីការ និងពិធីបុណ្យផ្សេងៗ
- គ្រប់គ្រងបុគ្គលិក រៀបចំផែនការ តារាងបៀវត្ស និងស្ថិតិបុគ្គលិក ព្រមទាំងរៀបចំសំណុំលិខិតរដ្ឋបាលសម្រាប់គ្រប់គ្រងអាជីព
- រៀបចំសំណើជ្រើសរើស ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងរៀបចំសំណើផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗ
- ចូលរួមរៀបចំផែនការ ប្រមូលផ្តុំព័ត៌មានគ្រប់គ្រងធនធានមនុស្ស កម្មវិធីការងារទូទៅ និងកម្មវិធីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក
- រៀបចំ និងបូកសរុបរបាយការណ៍របស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

២. ការិយាល័យកិច្ចការហិរញ្ញវត្ថុ ទទួលបន្ទុក ៖

- គ្រប់គ្រងការងារផែនការ ថវិកា លទ្ធកម្ម បេឡា គណនេយ្យ សារពើភ័ណ្ឌ និងការងារហិរញ្ញវត្ថុទាំងឡាយរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ទទួល និងបូកសរុបផែនការសកម្មភាព និងផែនការថវិកាពីគ្រប់ការិយាល័យ និងអង្គភាពនានា ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- រៀបចំ និងគ្រប់គ្រង ការអនុវត្តថវិកា ដោយមានចុះកិច្ចបញ្ជិកាគណនេយ្យ
- រៀបចំបែបបទ សម្របសម្រួល គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីជាធរមាន
- រៀបចំបែបបទទូទាត់កិច្ចចំណាយដំណើរការរដ្ឋបាលផ្សេងៗ និងចំណាយកិច្ចលទ្ធកម្ម

- គ្រប់គ្រង តាមដាន និងធ្វើបញ្ជីបេឡាជាប្រចាំ
- រៀបចំបើកប្រាក់បៀវត្ស ប្រាក់បេសកកម្ម ប្រាក់ឧបត្ថម្ភផ្សេងៗ និងរៀបចំបែបបទទូទាត់
- គ្រប់គ្រងបញ្ជីសលាកបត្រ និងគណនេយ្យប្រជាគុ
- ទទួល ប្រមូល គ្រប់គ្រង និងចាត់ចែងប្រាក់ពន្ធ ប្រាក់ប្រដាប់ក្តី ប្រាក់ពិន័យ និងប្រាក់ចំណូលផ្សេងទៀត ព្រមទាំងបញ្ជូនសាច់ប្រាក់ តាមបទដ្ឋានគតិយុត្តជាធរមាន និងធ្វើរបាយការណ៍ជាប្រចាំ
- សម្របសម្រួល ប្រមូលផ្តុំ និងគ្រប់គ្រងរាល់ចំណូល ប្រាក់តម្កល់ ប្រាក់ប្រាតិភោគ ឬប្រាក់ផ្សេងៗទៀតរបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- គ្រប់គ្រង និងបើកប្រាក់រង្វាន់ ក្រោមការទទួលខុសត្រូវរបស់សាលាដំបូង និង/ឬ អយ្យការអមសាលាដំបូង តាមបទដ្ឋានគតិយុត្តជាធរមាន
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋ
- រៀបចំ គ្រប់គ្រង និងបែងចែកតាមតម្រូវការនូវសម្ភារៈ បរិក្ខារបច្ចេកទេស ប្រេងឥន្ធនៈ និងតម្រូវការផ្សេងៗ
- សម្របសម្រួល គ្រប់គ្រង និងថែរក្សាវត្ថុតាងដែលមានសាលក្រម ឬសាលដីកាស្ថាពរ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តការកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

៣. ការិយាល័យកិច្ចការតុលាការ ទទួលបន្ទុក ៖

- ទទួល និងចាត់ចែងបន្តលើសំណុំរឿងទាំងឡាយក្នុងសមត្ថកិច្ចសាលាដំបូង ពីការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- សម្របសម្រួលកិច្ចការចោទឯកសារសំណុំរឿង និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្តឹង និងដំណើរការនីតិវិធីសំណុំរឿងក្តីរបស់សាលាដំបូង
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធលើក ឬដាស់តឿនអំពីការឃុំខ្លួន
- សម្របសម្រួលការថតចម្លងឯកសារសំណុំរឿងក្តី
- សម្របសម្រួល រៀបចំកម្មវិធីសវនាការ និងគ្រប់គ្រងកិច្ចការរដ្ឋបាលនីតិវិធីនៃសវនាការ ដើម្បីធានាកិច្ចដំណើរការល្អ
- ទំនាក់ទំនងទៅក្រុម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា មន្រ្តីជំនួយយុត្តិធម៌ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្តី
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្តី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- សហការជាមួយផ្នែកព័ត៌មានវិទ្យានៃសាលាដំបូង ដើម្បីចុះទិន្នន័យសំណុំរឿងបឋម និងស្ថាពរដែលទាក់ទិនដល់នីតិវិធីនៃចំណាត់ការរឿងក្តី
- ប្រមូល និងចងក្រងសាលក្រមស្ថាពរ និងរូបមន្តអនុវត្តផ្សេងៗ
- រៀបចំការបញ្ជូនសាលក្រម សេចក្តីសម្រេច និងឯកសារផ្សេងៗ ជូនទៅក្រសួងយុត្តិធម៌ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមច្បាប់កំណត់
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ

- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

៤. ការិយាល័យកិច្ចការអយ្យការ ទទួលបន្ទុក ៖

- គ្រប់គ្រងនិងចាត់ចែងបន្តលើសំណុំរឿងនិងការងារទាំងឡាយក្នុងសមត្ថកិច្ចអយ្យការអមសាលាដំបូងពីការិយាល័យកិច្ចការរដ្ឋបាល និងបុគ្គលិក
- សម្របសម្រួលកិច្ចការចេរាចរឯកសារសំណុំរឿង និងប្រមូលព័ត៌មានទាក់ទងនឹងចំណាត់ការបណ្ដឹង និងដំណើរការនីតិវិធីសំណុំរឿងក្ដីព្រហ្មទណ្ឌ
- រៀបចំការបញ្ជូនសាលក្រមស្ថាពរទៅសាលាជម្រះក្ដី និង/ឬ ពន្ធនាគារដែលមានសមត្ថកិច្ច
- សម្របសម្រួលជាមួយចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី អាជ្ញាសាលា មន្ត្រីជំនួយយុត្តិធម៌ អ្នកជំនាញការ និងអាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចដំណើរការរឿងក្ដី
- ចូលរួមរក្សា និងតម្កល់ឯកសាររឿងក្ដី ព្រមទាំងចូលរួមធានាប្រព័ន្ធសុវត្ថិភាពនៃឯកសារសំណុំរឿង
- ប្រមូល និងចងក្រងសាលក្រមស្ថាពរក្នុងរឿងព្រហ្មទណ្ឌ
- សម្របសម្រួលការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរ ឬសេចក្ដីសម្រេចនានា
- សហការរៀបចំសិក្ខាសាលាពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ
- សម្របសម្រួលរៀបចំកម្មវិធីសវនាការព្រហ្មទណ្ឌ ដើម្បីធានាកិច្ចដំណើរការល្អ
- សម្របសម្រួលការថតចម្លងឯកសាររឿងក្ដីព្រហ្មទណ្ឌ
- លើកគម្រោងថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ការិយាល័យ
- រៀបចំរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានលេខាធិការដ្ឋានប្រគល់ឱ្យ។

## ជំពូកទី ៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៧.-**

ក្នុងករណីដែលការិយាល័យណាមួយ នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងណាមួយ មិនទាន់អាចដំណើរការបាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាសធ្វើការប្រគល់ភារកិច្ចរបស់ការិយាល័យនោះ ឱ្យទៅការិយាល័យណាមួយផ្សេងទៀតបាន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចេញប្រកាសធ្វើការកែសម្រួល និងបង្កើតការិយាល័យ ឬអង្គភាពមួយចំនួន ចំណុះឱ្យលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងបាន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌

p

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រកាស ស្តីពី
នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ដំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៤

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

## ប្រធានក្រុមការងារតាក់តែងច្បាប់

ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សមាសភាពក្រុមការងារក្រសួងយុត្តិធម៌ដែលទទួលបន្ទុកតាក់តែងប្រកាសស្តីពី "ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ"

| | | |
|---|---|---|
| លោកជំទាវ | **ចាន់ សុធាវី** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម | **យាន ស៊ីណា** | អតីតអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| លោក | **ទិត្យ ឫទ្ធី** | ចៅក្រមនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ម៉ៅ គិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **សូរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ |
| លោក | **ទូច ថារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **កែវ សេដ្ឋា** | អតីតអនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ហុក ច័ន្ទសុវណ្ណារ៉ា** | អនុប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **អុល ធីរៈ** | អនុប្រធានការិយាល័យកិច្ចការអយ្យការនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ឡាយ លីនណា** | អនុប្រធានការិយាល័យបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **សួន ណារី** | មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងយុត្តិធម៌ |

## ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌

| | | |
|---|---|---|
| លោក | Issei SAKANO | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Hiroshi KIYOHARA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Masayoshi HARADA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Emiko KANETAKE | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Ayako TAMIYA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Miha ISOI | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## សមាសភាពសាស្ត្រាចារ្យជប៉ុនដែលបានប្រឹក្សាយោបល់ក្នុងការរៀបចំប្រកាស

| | | |
|---|---|---|
| លោក | Akio MORISHIMA | សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក | Ikufumi NIIMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Meiji |
| លោក | Michitaro URAKAWA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Kaoru KAMATA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Yutaka YAMAMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Kyoto |
| លោក | Tsuneo MATSUMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Hitotsubashi |
| លោក | Yoshihisa NOMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushuin |

| | | |
|---|---|---|
| លោក | Toshifumi MINAMI | អតីតចៅក្រមសាលាឧទ្ធរណ៍នៃទីក្រុងតូក្យូ |
| លោក | Toyohiro NOMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushu-in |
| លោក | Masayuki TANAMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Keita SATO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Chuo |
| លោក | Atsushi MOTOYAMA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Ritsumeikan |
| លោក | Hiroshi MATSUO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Keio |
| លោក | Hisaya HATANAKA | ជំនួយការសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Fukuoka |
| លោក | Keisuke ENDO | មន្ត្រីនៃការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | Kazuo UESAKA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ |

## សមាសភាពលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាយោបល់

| | | |
|---|---|---|
| លោក | Atsuhito YOSHIMOTO | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |
| លោក | Hisashi NAGAYA | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |

## អ្នកបកប្រែ :

| | | |
|---|---|---|
| លោក | **គីម ពេជ្រជា** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែម ពិសី** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែម ម៉ាន្នី** | អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ឡៀម សុខសិរីយស** | អតីតជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ខែម ណារ័ត្ន** | មន្ត្រីច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **សោម តេសា** | ជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| កញ្ញា | **ស៊ី ច័ន្ទដឺម៉ា** | ជំនួយការរដ្ឋបាល នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

**ប្រកាស**

**ស្តីពី**

**នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**


**ជំពូកទី ១- បទប្បញ្ញត្តិទូទៅ**

ប្រការ ១ - គោលដៅ ..... ២

ប្រការ ២ - គោលបំណង ..... ២

ប្រការ ៣ - វិសាលភាព ..... ២

**ជំពូកទី ២- សមត្ថកិច្ចចុះបញ្ជី**

ប្រការ ៤ - ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី ..... ២

**ជំពូកទី ៣- ការបង្កើត ការគ្រប់គ្រងក្រឡា និងអំឡុងពេលរក្សាទុកឯកសារក្នុងក្រឡា**

**ផ្នែកទី ១- ការបង្កើតក្រឡា**

ប្រការ ៥ - ការបង្កើតក្រឡា ..... ៣

ប្រការ ៦ - ក្រឡាទទួលពាក្យសុំ ..... ៣

ប្រការ ៧ - ក្រឡាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ៤

ប្រការ ៨ - ក្រឡាសម្រាក់ដាក់ឯកសារពាក្យសុំ ..... ៤

ប្រការ ៩ - ក្រឡាលើកចោល ..... ៤

ប្រការ ១០ - ក្រឡាសម្រាក់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ..... ៤

ប្រការ ១១ - ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ..... ៤

**ផ្នែកទី ២- ការគ្រប់គ្រងក្រឡា**

ប្រការ ១២ - ការគ្រប់គ្រងក្រឡា ..... ៥

**ផ្នែកទី ៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រឡា**

ប្រការ ១៣ - ការរក្សាទុកឯកសារក្នុងក្រឡាទទួលពាក្យសុំ និងក្រឡាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ៥

ប្រការ ១៤ - អំឡុងពេលរក្សាទុកឯកសារក្នុងក្រឡាសម្រាប់ដាក់ពាក្យសុំ ក្រឡាលើកចោល ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ..... ៥

**ជំពូកទី ៤- បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី**

ប្រការ ១៥ - ពាក្យសុំចុះបញ្ជី ..... ៥

ប្រការ ១៦ - ទម្រង់នៃពាក្យសុំចុះបញ្ជី ..... ៦

ប្រការ ១៧ - ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី ..... ៦

ប្រការ ១៨ - ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់..........................................................................៧

## ជំពូកទី ៥- ពាក្យសុំចុះបញ្ជី

ប្រការ ១៩ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..........................................................៧
ប្រការ ២០ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..........................................៨
ប្រការ ២១ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..........................៨
ប្រការ ២២ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ
លែងលះអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ...............................................................................៩
ប្រការ ២៣ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ
មោឃភាព ការលុបចោល ឬ ការលែងលះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................................១០
ប្រការ ២៤ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ
សហព័ទ្ធណាម្នាក់បានស្លាប់...............................................................................................១០
ប្រការ ២៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើ
សាលក្រម ឬ សាលដីកាស្ថាពរ លែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ..១១
ប្រការ ២៦ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តី
សម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែល
មិនមែនជាបណ្តឹង...............................................................................................................១១
ប្រការ ២៧ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាម
សាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្ត
ក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ...............................................................១២
ប្រការ ២៨ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍.........................................................១២

## ជំពូកទី ៦- ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

ប្រការ ២៩ - ការទទួលពាក្យសុំចុះបញ្ជី ..........................................................................................១៣
ប្រការ ៣០ - ការដកពាក្យសុំចុះបញ្ជី..............................................................................................១៣
ប្រការ ៣១ - ការពិនិត្យពាក្យសុំចុះបញ្ជី..........................................................................................១៣
ប្រការ ៣២ - ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី...............................................................១៣
ប្រការ ៣៣ - ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ ......................................................................................១៤
ប្រការ ៣៤ - ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី ........................................១៤
ប្រការ ៣៥ - ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ...............................១៤
ប្រការ ៣៦ - អានុភាពនៃការចុះបញ្ជី.............................................................................................១៤

## ជំពូកទី ៧- របៀបចុះបញ្ជី និងរចនាក្រមនុកក្នុងក្រុណា

ប្រការ ៣៧ - របៀបចុះបញ្ជីក្នុងក្រុណាទទួលពាក្យសុំ..........................................................................១៥

ប្រការ ៣៨ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..............................១៥
ប្រការ ៣៩ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ...........១៥
ប្រការ ៤០ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ...........១៦
ប្រការ ៤១ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.១៦
ប្រការ ៤២ - របៀបចុះបញ្ជីក្នុងក្រ្កណ្ឌចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍..................១៦
ប្រការ ៤៣ - វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........................១៧
ប្រការ ៤៤ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ................................១៧
ប្រការ ៤៥ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌលើកចោល .....................................................១៧
ប្រការ ៤៦ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ.....................១៧
ប្រការ ៤៧ - របៀបចងក្រងរក្សាទុកក្នុងក្រ្កណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី....១៨

**ជំពូកទី ៨- នីតិវិធីនៃការចេញលិខិតបញ្ជាក់**

ប្រការ ៤៨ - របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ........................................................១៨
ប្រការ ៤៩ - ការចេញលិខិតបញ្ជាក់.......................................................................................១៨

**ជំពូកទី ៩- អវសានប្បញ្ញត្តិ**

ប្រការ ៥០ - កាលបរិច្ឆេទ នៃការអនុវត្ត ...............................................................................១៩

ឧបសម្ព័ន្ធទី ១ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..................................................២០
ឧបសម្ព័ន្ធទី ២ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ..............................២១
ឧបសម្ព័ន្ធទី ៣ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន ........................................២២
ឧបសម្ព័ន្ធទី ៤ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ...............២៣
ឧបសម្ព័ន្ធទី ៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ.......................២៤
ឧបសម្ព័ន្ធទី ៦ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ....................................២៥
ឧបសម្ព័ន្ធទី ៧ - ពាក្យសុំឲ្យចេញលិខិតបញ្ជាក់...........................................................................២៦
ឧបសម្ព័ន្ធទី ៨ - សន្លឹកក្រដាសទទួលពាក្យសុំ ...........................................................................២៧
ឧបសម្ព័ន្ធទី ៩ - សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ...................................................២៨
ឧបសម្ព័ន្ធទី ១០ - សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ....................................២៩
គំរូចុះបញ្ជី ១ - សន្លឹកក្រដាសទទួលពាក្យសុំ ...........................................................................៣០
គំរូចុះបញ្ជី ២ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) ....................................៣១
គំរូចុះបញ្ជី ៣ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា).......................៣២
គំរូចុះបញ្ជី ៤ - ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) ...................................៣៤
គំរូចុះបញ្ជី ៥ - ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ......................៣៥
គំរូចុះបញ្ជី ៦ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (សន្លឹកចុះបញ្ជី) .........................៣៧

គំរូចុះបញ្ជី ៧ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (ថៃ្ងកត់ត្រា) ........៣៨
គំរូចុះបញ្ជី ៨ - ការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋានជាអាទិ៍ (សន្លឹកចុះបញ្ជី)......................................៣៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ ៖ ០៤២.កយ.ប្រក/១៣

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ ៖ 023 216 322 023 2 7 841

# ប្រកាស
# ស្ដីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលបង្កើតអានុភាពរវាងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឲ្យបានត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

គោលបំណងនៃប្រកាសនេះ គឺអនុញ្ញាតឲ្យប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឲ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើចំណុច ដូចខាងក្រោម ៖

- ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- នីតិវិធីនៃការចេញលិខិតបញ្ជាក់។

## ជំពូកទី ២
## សមត្ថកិច្ចចុះបញ្ជី

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី**

១- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

២- មន្ត្រីដែលទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

៣- ក្រុណ្ឌទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

## ជំពូកទី ៣
## ការបង្កើត ការគ្រប់គ្រងក្រុណ្ឌ និងអំឡុងពេលរក្សាទុកឯកសារក្នុងក្រុណ្ឌ
### ផ្នែកទី ១
### ការបង្កើតក្រុណ្ឌ

**ប្រការ ៥ : ការបង្កើតក្រុណ្ឌ**

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ត្រូវបង្កើតក្រុណ្ឌ ដូចខាងក្រោម ៖

១. ក្រុណ្ឌទទួលពាក្យសុំ
២. ក្រុណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
៣. ក្រុណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ
៤. ក្រុណ្ឌលើកចោល
៥. ក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឱ្យពិនិត្យឡើងវិញ
៦. ក្រុណ្ឌសម្រាប់ដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

**ប្រការ ៦ : ក្រុណ្ឌទទួលពាក្យសុំ**

១- ក្រុណ្ឌទទួលពាក្យសុំ គឺជាក្រុណ្ឌសម្រាប់ចុះព័ត៌មាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងចុះលេខទទួលពាក្យសុំនៅលើពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និងពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

២- សន្លឹកក្រដាសទទួលពាក្យសុំ ដែលដាក់ក្នុងក្រុណ្ឌ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខរៀងទទួលពាក្យ
- កាលបរិច្ឆេទ នៃការទទួលពាក្យ
- ប្រភេទ នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ជាប្ដីប្រពន្ធ
- បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន)
- ផ្សេងៗ

**ប្រការ ៧ : ក្រឡាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- ក្រឡាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជាក្រឡាសម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- សន្លឹកចុះបញ្ជី ដែលដាក់ក្នុងក្រឡា ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខចុះបញ្ជី និង លេខទទួលពាក្យសុំ
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណង និងមូលហេតុនៃការចុះបញ្ជី
- ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការលុបការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

**ប្រការ ៨ : ក្រឡាសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រឡាសម្រាប់ដាក់ឯកសារពាក្យសុំ គឺជាក្រឡាសម្រាប់ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ដែលមន្ត្រីចុះបញ្ជីបានទទួលពីអ្នកដាក់ពាក្យសុំ ។

**ប្រការ ៩ : ក្រឡាលើកចោល**

ក្រឡាលើកចោល គឺជាក្រឡាសម្រាប់ដាក់លិខិតលើកចោលពាក្យសុំចុះបញ្ជីរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ១០ : ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ គឺជាក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ព្រមទាំងដាក់សេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកសារដែលភ្ជាប់មកជាមួយ ។

**ប្រការ ១១ : ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

ក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី គឺជាក្រឡាសម្រាប់ដាក់ពាក្យសុំឲ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

## ផ្នែកទី ២
## ការគ្រប់គ្រងក្រូណូ

**ប្រការ ១២ : ការគ្រប់គ្រងក្រូណូ**

ក្រូណូ គឺត្រូវគ្រប់គ្រង និងរក្សាទុកនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ។

## ផ្នែកទី ៣
## អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ

**ប្រការ ១៣ : ការរក្សាទុកឯកសារក្នុងក្រូណូទទួលពាក្យសុំ និងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

ឯកសារក្នុងក្រូណូទទួលពាក្យសុំ និងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកជានិរន្តរ៍ ។

**ប្រការ ១៤ : អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ ក្រូណូលើកចោល ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

១- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំ ។

២- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូលើកចោល មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតលើកចោល ។

៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ។

៤- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ។

## ជំពូកទី ៤
## បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី

**ប្រការ ១៥ : ពាក្យសុំចុះបញ្ជី** p

១- រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ ។

២- ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

ក. ការផ្លាស់ប្ដូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចសាលា ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជី ជំនួសប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ។

៤- បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់ ។

## ប្រការ ១៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរជាវចនានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ។

## ប្រការ ១៧ : ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី

១- នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្ដល់ឯកសារចាំបាច់មួយចំនួនទៅឲ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ ។

២- ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ ។

**ប្រការ ១៨ : ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់**

១- ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឲ្យប្រគល់វិញនៅពេលដាក់ពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង ។

២- ដើម្បីទាមទារឲ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ។

៣- ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឲ្យអ្នកទទួលការប្រគល់សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវករណី ដែលខ្លួនបានទទួលការប្រគល់ឯកសារនោះ និងចុះហត្ថលេខា ។

## ជំពូកទី ៥
## ពាក្យសុំចុះបញ្ជី

**ប្រការ ១៩ : ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើមានការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឃ- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ង- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

ប្រការ ២០ ៖ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្តូរ)

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- ឈ្មោះ ឬ អាសយដ្ឋានថ្មី

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្តូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ហាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

ប្រការ ២១ ៖ ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១- នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– គោលបំណង

ខ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

គ– ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន

- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី ក្រោយពេលមានការកែតម្រូវ
- លិខិតបញ្ជាក់អាសយដ្ឋាន
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២២ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយមូលហេតុរំលាយអាពាហ៍ពិពាហ៍ ឬ កំដាប់ពាក្យ**

១- ប្រសិនបើប្ដីប្រពន្ធបានរំលាយអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានរំលាយកំដាប់ពាក្យ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទរំលាយអាពាហ៍ពិពាហ៍ ឬ កំដាប់ពាក្យ)

ឯកសារភ្ជាប់:

- ដីកាសម្រេច ដែលរំលាយអាពាហ៍ពិពាហ៍តាមការព្រមព្រៀង
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹងពីការរំលាយកំដាប់ពាក្យ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៣ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានចុះបញ្ជីរួច ត្រូវបានមោឃៈ រំលាយ ឬ លុបចោល ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមោឃភាព, ការលុបចោល, ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់ថាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានមោឃៈ លុបចោល ឬ រំលាយ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៤ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ សហព័ទ្ធណាម្នាក់បានស្លាប់**

១- ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានស្លាប់ សហព័ទ្ធដែលនៅរស់ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលនៅរស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី p

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

ឯកសារភ្ជាប់:

- សំបុត្រមរណភាព
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៥ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ**

១- ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬ សាលដីការំលាយអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីការំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៦ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**

១- ប្រសិនបើតុលាការសម្រេចសេចក្តី អំពីការបែងចែកទ្រព្យសម្បត្តិ ដោយការរំលាយអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ)

ឯកសារភ្ជាប់:

- ដីកាសម្រេចការបែងចែកទ្រព្យសម្បត្តិដោយការលែងលះអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៧ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ**

១- នៅពេលមានសាលក្រម ឬ សាលដីកាស្ថាពរដែលកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ភាគីណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជី។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៨: ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

១- នៅពេលដែលបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរៀបអាពាហ៍ពិពាហ៍ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បុគ្គលនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឯកសារភ្ជាប់:

- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ជំពូកទី ៦
## ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

**ប្រការ ២៩ : ការទទួលពាក្យសុំចុះបញ្ជី**

នៅពេលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះ នូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការផ្លូវប្បវេណី ព្រមទាំងហត្ថលេខាបំពេញ និងឈ្មោះមន្ត្រីចុះបញ្ជីនោះ ។

**ប្រការ ៣០ : ការដកពាក្យសុំចុះបញ្ជី**

ពាក្យសុំចុះបញ្ជីអាចដកបានមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

**ប្រការ ៣១ : ការពិនិត្យពាក្យសុំចុះបញ្ជី**

១- មន្ត្រីចុះបញ្ជី ត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ ។

២- នៅពេលពិនិត្យពាក្យសុំ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន ។

**ប្រការ ៣២ : ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី**

១- មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ ដោយមានមូលហេតុ ដូចខាងក្រោម ៖

- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាសនេះ
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី

- ពុំបានបង់សោហ៊ុយ ឬ
- ពាក្យសុំនោះ មិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ផ្សេងទៀត ដែលពាក់ព័ន្ធ។

៦-ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជី ពុំបានកែតម្រូវនៅក្នុងអំឡុងពេលសមស្របនោះទេ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ។

**ប្រការ ៣៣ : ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ**

ក្នុងករណីពាក្យសុំចុះបញ្ជីត្រូវបានដក ឬ លើកចោល មន្ត្រីចុះបញ្ជីត្រូវប្រគល់ឯកសារភ្ជាប់ឲ្យទៅអ្នកដាក់ពាក្យសុំវិញ បើមានការស្នើសុំ ។

**ប្រការ ៣៤ : ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី**

១- ការលើកចោលពាក្យសុំរបស់មន្ត្រីចុះបញ្ជី ដូចមានចែងក្នុងប្រការ ៣២ នៃប្រកាសនេះ អ្នកដាក់ពាក្យសុំចុះបញ្ជីមានសិទ្ធិដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

២- ពាក្យសុំឲ្យពិនិត្យឡើងវិញក្នុងកថាខណ្ឌទី១ ខាងលើនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំនោះ ។

**ប្រការ ៣៥ : ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានដូចខាងក្រោម ៖

- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋានរបស់ភាគី
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុនៃការចុះបញ្ជី និងកាលបរិច្ឆេទ
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ប្រការ ៣៦ : អានុភាពនៃការចុះបញ្ជី**

ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានអានុភាពនៅពេលដែលចុះហត្ថលេខា និងប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

p

# ជំពូកទី ៧
# របៀបចុះបញ្ជី និងរក្សាទុកក្នុងក្រុណ្ឌ

**ប្រការ ៣៧ :  របៀបចុះបញ្ជីក្នុងក្រុណ្ឌទទួលពាក្យសុំ**

នៅពេលដែលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំនូវព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី២ ប្រការ ៦ នៃប្រកាសនេះ ។

**ប្រការ ៣៨ :  របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- បន្ទាប់ពីមន្ត្រីចុះបញ្ជីបានពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ១៩ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ) រួច មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចដូចខាងក្រោមនេះ ៖

- ឈ្មោះ អាសយដ្ឋាន និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ភាគីនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)

២- ចំពោះសន្លឹកចុះបញ្ជីនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះលេខចុះបញ្ជីផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រុណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៣៩ :  របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ ដែលបានកំណត់ក្នុងប្រការ ២០ (ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរ គោលបំណងនៃការចុះបញ្ជី មូលហេតុ និងកាលបរិច្ឆេទ ព្រមទាំងខ្លឹមសារនៃកិច្ចសន្យាទាំងអស់ឡើងវិញ នៅក្នុងសន្លឹក "**ផ្លាស់ប្ដូរ**" ។

២- ចំពោះការផ្លាស់ប្ដូរខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រុណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

៤- ចំពោះការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន មន្ត្រីចុះបញ្ជីត្រូវសរសេរឈ្មោះ ឬ អាសយដ្ឋានថ្មី មូលហេតុនៃការផ្លាស់ប្តូរ និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ចូលក្នុងសន្លឹកដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ នៅក្នុងខ្ទង់ពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរឈ្មោះ និង អាសយដ្ឋាន" រួចមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជីនោះ។

**ប្រការ ៤០ : របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

បញ្ញត្តិនៃប្រការ ៣៩ (របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

**ប្រការ ៤១ : របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២២ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ) ប្រការ ២៣ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ប្រការ ២៤ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់) ប្រការ ២៥ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ) ប្រការ ២៦ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) និងប្រការ ២៧ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពីគោលបំណង មូលហេតុ និងកាលបរិច្ឆេទ នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រង់ខ្ទង់ "ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ។

២- ចំពោះសន្លឹកចុះបញ្ជីក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រុណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៤២ : របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២៨ (ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពី

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍នៅខ្ទង់ "កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍" នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ៤៣ : វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ពាក់ព័ន្ធនឹងការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅត្រង់ខ្ទង់ "ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឬ ខ្ទង់ "ការផ្លាស់ប្តូរទ្រព្យសម្បត្តិប្តីប្រពន្ធ" មន្ត្រីចុះបញ្ជីក៏អាចចុះថា "**ផ្ទុចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ**" រួចភ្ជាប់នូវលិខិតថតចម្លងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះជាមួយគ្នាក្នុងសន្លឹកចុះបញ្ជីនៃក្រូណូបាន។ ក្នុងករណីនេះ មន្ត្រីចុះបញ្ជីត្រូវកត់ត្រានូវលេខចុះបញ្ជី និង លេខទទួល នៅក្នុងលិខិតថតចម្លងនៃកិច្ចសន្យា ដែលបានភ្ជាប់មកជាមួយនោះ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "បានពិនិត្យរួច" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច។

២- ក្រោយពេលពិនិត្យ និងសម្រេចរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងចុះហត្ថលេខា និងប្រថាប់ត្រានៅគ្រប់សន្លឹកនៃលិខិតថតចម្លងដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៤៤ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះហត្ថលេខា និងប្រថាប់ត្រារួច មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំចុះបញ្ជី និង ឯកសារភ្ជាប់ក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ ទៅតាមលំដាប់លេខរៀង និងកាលបរិច្ឆេទទទួលពាក្យសុំ ។

**ប្រការ ៤៥ : របៀបចងក្រងរក្សាទុកក្នុងក្រូណូលើកចោល**

នៅពេលដែលមន្ត្រីចុះបញ្ជី បានលើកចោលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកលិខិតលើកចោលក្នុងក្រូណូលើកចោល ទៅតាមលំដាប់លេខលិខិតលើកចោល និងកាលបរិច្ឆេទ ។

**ប្រការ ៤៦ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក្យសុំឲ្យពិនិត្យឡើងវិញ និងឯកសារភ្ជាប់ ក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅតាមលំដាប់លេខពាក្យសុំឲ្យពិនិត្យឡើងវិញ និងកាលបរិច្ឆេទ ។

p

**ប្រការ ៤៧ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

រាល់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំនោះនៅក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ទៅតាមលំដាប់លេខនៃការទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី និងកាលបរិច្ឆេទ ។

## ជំពូកទី ៨
## នីតិវិធីនៃការចេញលិខិតបញ្ជាក់

**ប្រការ ៤៨ : របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់**

១- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

២- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ។

៣- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ ។

៤- អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤៩ : ការចេញលិខិតបញ្ជាក់**

១- នៅពេលបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅឲ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅលើឯកសារថតចម្លងថា ៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី..........ខែ.........ឆ្នាំ.........)
- ហត្ថលេខាបំពេញរបស់មន្ត្រីចុះបញ្ជី និង ហត្ថលេខា និង ប្រដាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចឲ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

២- ក្រោយពីបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឲ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឲ្យលើសពីរយៈពេល ៣ ថ្ងៃ ។

# ជំពូកទី ៦
# អវសានប្បញ្ញត្តិ

**ប្រការ ៥០ : កាលបរិច្ឆេទ នៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែបានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

ថ្ងៃទី០៩....ខែ[illegible]ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍានៈ

p

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចព្រមព្រៀងលែងលះ</u>

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅថ្ងៃទី ....... ខែ ...... ឆ្នាំ.........រវាង៖

ឈ្មោះ ................. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត:...................... មានទីលំនៅផ្ទះលេខ: ........... ផ្លូវ............... សង្កាត់ ............... ខណ្ឌ ............... រាជធានីភ្នំពេញ ភាគីប្ដីតទៅនេះហៅកាត់ថា **ភាគី-ក**-។

**<u>និង</u>**

ឈ្មោះ .................. ភេទ ស្រី ថ្ងៃខែឆ្នាំកំណើត: .................... មានទីលំនៅផ្ទះលេខ: .............. ផ្លូវ ............... សង្កាត់................. ខណ្ឌ ............... រាជធានីភ្នំពេញ ។

**<u>បុព្វកថា</u>**

**ដោយហេតុថា: ភាគី -ក-** និង **ភាគី -ខ-** បានរៀបការជាមួយគ្នានៅឆ្នាំ ........... និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី.......... ខែ .......... ឆ្នាំ .......... នៅសាលាខណ្ឌ ........... រាជធានីភ្នំពេញ ហើយបង្កើតបានកូនចំនួន ........... នាក់ ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ២១.០១.២០០១។ ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធនេះតែងតែមានភាពរកាំរកូស ពុំមានសេចក្ដីសុខក្នុងគ្រួសារ មិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន ហើយយើងខ្ញុំក៏អស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដីប្រពន្ធជាមួយគ្នា និង ព្រមព្រៀងលែងលះឈប់រស់នៅជាមួយគ្នាជាប្ដីប្រពន្ធចាប់ពីពេលនេះតទៅ ។

**<u>ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោយ</u>**:

**<u>ប្រការ១</u>**: **ភាគី -ក-** និង **ភាគី -ខ-** ឯកភាពយល់ព្រមលែងលះឈប់រស់នៅជាមួយគ្នាជាប្ដីប្រពន្ធដោយស្ម័គ្រចិត្តពីថ្ងៃចុះហត្ថលេខា និងផ្ដិតមេដៃនេះតទៅ ។

ទ្រព្យសម្បត្តិរួមមាន៖

មានកូនឈ្មោះ .............. ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: .............................................។

១-ដីទំហំ ..... ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: .....................ចុះថ្ងៃទី................ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី .........................។

២-ដីទំហំ .......... ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ................. ចុះថ្ងៃទី........... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី .........................។

៣-ដីទំហំ ......... ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ:.................. ចុះថ្ងៃទី ................... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដី ................។

**<u>ប្រការ២</u>**: **ភាគី -ខ-** យល់ព្រមប្រគល់សិទ្ធិគ្រប់គ្រង និងជាអ្នកមានអំណាចមេបាលើកូនឈ្មោះ .......................... ភេទ ប្រុស ថ្ងៃខែឆ្នាំកំណើត: ..........................អោយ**ភាគី -ក-** ។**ភាគី -ក-** ឯកភាពតាម**ភាគី -ខ-** ។

**<u>ប្រការ៣</u>**: **ភាគី -ក-** មិនទាមទារអោយ **ភាគី -ខ-**បង់អាហារកិច្ចចិញ្ចឹមបីបាច់កូនទេ ។ **ភាគី -ខ-** គ្មានសិទ្ធិគ្រប់គ្រង និងគ្មានអំណាចមេបាលើកូន តែមានសិទ្ធិជួលសួរសុខទុក្ខកូនតាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារហើយ **ភាគី -ក-** ដែលមានសិទ្ធិគ្រប់គ្រង និងជាអ្នកមានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ **ភាគី -ខ-** ក្នុងការមកជួបកូន ។

**<u>ប្រការ៤</u>**: **ភាគី "ក"** និង **ភាគី "ខ"** យល់ព្រមបែងចែកទ្រព្យសម្បត្តិរួមដូចតទៅ :

-ដីទំហំ ........ម៉ែត្រការ៉េ ដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុលេខ: ........... ចុះថ្ងៃទី ......... ........... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសុរិយោដី ....................................។

(មានសិទ្ធិចាត់ចែង គ្រប់គ្រង និងអាស្រ័យផល ។

**ភាគី "ខ"** ទទួលបាន:

-ដីទំហំ ........ ម៉ែត្រការ៉េ ដែលមានសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ: .................. ចុះថ្ងៃទី........ ...................... ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និង សុរិយោដី .....................។

(មានសិទ្ធិចាត់ចែង គ្រប់គ្រង និងអាស្រ័យផល នៅពេលមានអាយុ ៣០ ឆ្នាំ )

ក្នុងកំឡុងពេលបច្ចុប្បន្នរហូតដល់អាយុក្រោម ៣០ ឆ្នាំ **ភាគី "ក"** ជាអ្នកថែរក្សា និងជាអ្នកមើលខុសត្រូវជួស ។

ធ្វើនៅថ្ងៃទី ...... ខែ..... ឆ្នាំ.......

| | | |
|---|---|---|
| **បានឃើញ និងបញ្ជាក់ថា** | **ស្នាមមេដៃស្តាំ** | **ស្នាមមេដៃស្តាំ** |
| គូភាគីពិតជាបានផ្តិតមេដៃស្តាំចំពោះ | **ភាគី "ក"** | **ភាគី "ខ"** |
| មុខមេធាវីពិតប្រាកដ ។ | | |
| **ហត្ថលេខា និងត្រា** | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូ
ពាក្យសុំលែងលះ
ដោយព្រមព្រៀង

## ពាក្យស្នើសុំលែងលះតាមការព្រមព្រៀង

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...........................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ.............. មានទីលំនៅបច្ចុប្បន្ន...........................................................។

**សូមគោរពជូនចំពោះ**

**ឯកឧត្តមប្រធានសាលាដំបូង**.........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្តាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ.........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

...........................................................................................

...........................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

...........................................................................................

...........................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ)..........................................................................

...........................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖

(បើមានសូមសរសេរ)..........................................................................

...........................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ......ចុះថ្ងៃទី..................... របស់.....................។

- .......................................................................................

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់............................ តាមលិខិតលេខ............ ចុះថ្ងៃទី.................... ។ នៅពេលនេះ យើងខ្ញុំបានអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធនឹងគ្នាទៀតហើយ ។ យើងខ្ញុំបានព្រមព្រៀងលែងលះគ្នាដោយស្ម័គ្រចិត្ត ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនិងសម្រេចតាមការស្នើសុំខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១.....

ស្នាមមេដៃស្តាំចុងចម្លើយ
(ស្នាមមេដៃស្តាំ)

.................

ស្នាមមេដៃស្តាំដើមចោទ
(ស្នាមមេដៃស្តាំ)

....................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូ
ពាក្យសុំលែងលះ
ក្នុងការព្រមព្រៀង

## ពាក្យបណ្ដឹងលែងលះ

**ដើមចោទ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...............................................................។

**ចុងចម្លើយ** ៖ ឈ្មោះ.................... ភេទ.......... អាយុ....... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
លេខ............... មានទីលំនៅបច្ចុប្បន្ន...............................................................។

**សូមគោរពជូនមក**

**ចៅក្រមប្រធានសាលាដំបូង**..........................

**កម្មវត្ថុ** ៖ សុំឲ្យតុលាការចេញដីកាសម្រេច មានខ្លឹមសារដូចខាងក្រោម ៖

១- ឲ្យ ដើមចោទ និងចុងចម្លើយ ផ្ដាច់សមគ្គសង្វាស់ តាមផ្លូវច្បាប់ ។

២-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ..........

៣-សម្រេចឲ្យ (ដើមចោទ/ចុងចម្លើយ) បង់អាហារកាតព្វកិច្ច និងអាចចូលសួរសុខទុក្ខកូនតាមច្បាប់កំណត់ ។

៤-សម្រេចឲ្យ ដើមចោទ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

...........................................................................................................

៥-សម្រេចឲ្យ ចុងចម្លើយ មានសិទ្ធិលើទ្រព្យសម្បត្តិដូចខាងក្រោម៖

...........................................................................................................

៦-សម្រេចឲ្យ ដើមចោទ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ).....................................................................................

៧-សម្រេចឲ្យ ចុងចម្លើយ សងបំណុលដូចខាងក្រោម៖
(បើមានសូមសរសេរ).....................................................................................

**យោង** ៖ -សំបុត្រអាពាហ៍ពិពាហ៍លេខ.......ចុះថ្ងៃទី...................... របស់.......................។
- ...........................................................................................................

កាលពីថ្ងៃទី.....ខែ....ឆ្នាំ..... នាងខ្ញុំ/ខ្ញុំបាទ បានចងអាពាហ៍ពិពាហ៍ ជាឈ្មោះ......................... ។ ប៉ុន្តែក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ឈ្មោះនេះ (សរសេរពីមូលហេតុដែលនាំឲ្យមានការទាមទារ) ........................ ...........................................................................................................។

អាស្រ័យហេតុនេះ សូម **ចៅក្រមប្រធាន** មេត្តាទទួល និងសម្រេចតាមការប្ដឹងសុំខាងលើ ដោយក្ដីអនុគ្រោះ ។

សូម **ចៅក្រមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ.................. ថ្ងៃទី......... ខែ......... ឆ្នាំ២០១......

| | |
|---|---|
| ស្នាមមេដៃស្ដាំចុងចម្លើយ | ស្នាមមេដៃស្ដាំដើមចោទ |
| (ស្នាមមេដៃស្ដាំ) | (ស្នាមមេដៃស្ដាំ) |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ១៣៣ "ច"

## ដីកាសម្រេច

យើង **សេខ នាខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

-បានឃើញមាត្រា ៩៧៩មាត្រា ១០៣៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ៨៦ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០១៤ ដែលមាន៖

**អ្នកដាក់ពាក្យសុំ**

ឈ្មោះ **កសខ** ភេទស្រី កើតថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ ទីលំនៅ បច្ចុប្បន្ន ផ្ទះលេខ១៣៧C ផ្លូវលេខ ៥៣BT សង្កាត់បឹងទំពន់ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី **គមស** ការិយាល័យមេធាវី **ក្រុមមេធាវីកម្ពុជា**ស្ថិតនៅអគារលេខ១៥៩-១៦០ ផ្លូវលេខ១១៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ភាគីម្ខាងទៀត**

ឈ្មោះ **កណរ** ភេទប្រុសកើតថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៧២ សញ្ជាតិខ្មែរទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៣៧C ផ្លូវលេខ ៥៣BT សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ការទាមទាររបស់អ្នកដាក់ពាក្យសុំ៖**

សុំដីកាសម្រេចលែងលះពីឈ្មោះ កណរ តាមកិច្ចព្រមព្រៀងលែងលះ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីសាកសួរឃើញថា ៖

១. ឈ្មោះ **កសខ** និងឈ្មោះ **កណរ** ពិតជាបានរៀបការ និងចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានក្នុងសេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍លេខ ៨៧ ឃ.ដ.ត ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ ១៩៩៥ប្រាកដមែន ។

២. ក្រោយពេលរៀបអាពាហ៍ពិពាហ៍ គឺពិតជារស់នៅមិនចុះសម្រុងនឹងគ្នា ដែលធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាមួយគ្នាប្រាកដមែន។ ម្យ៉ាងទៀត បើពិនិត្យលើកិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៤ និងការអះអាងរបស់គូភាគី បញ្ជាក់ថា ភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ ពិពាហ៍ប្រាកដមែន។

៣. ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍គូភាគីមានកូនបីនាក់មានឈ្មោះ **រសម** ភេទស្រី កើតថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៤ ឈ្មោះ **រសយ** ភេទស្រី កើតថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងឈ្មោះ **រជនភេទ** ប្រុស កើតថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ គូភាគីបានព្រមព្រៀងគ្នាកំណត់យកឪពុកឈ្មោះ **ភឈរ** ជាអ្នកមានអំណាចមេបាលើកូនទាំងបីនាក់។

៤. អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដីតាមមាត្រា ២២ កថាខណ្ឌទី ៣ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

## សេចក្ដីសម្រេចបញ្ចប់

**១.** ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ **ភសជ** ដែលមានអំណាចមេបាលើកូនឈ្មោះឈ្មោះ **រសម** ភេទស្រី កើតថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤ ឈ្មោះ **រសយ** ភេទស្រី កើតថ្ងៃ ទី២១ ខែធ្នូ ឆ្នាំ១៩៩៩ និងឈ្មោះ **រជន** ភេទប្រុស កើតថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ តាមការព្រមព្រៀងរបស់គូភាគី និងភាគីម្ខាងទៀតឈ្មោះ **ភឈរ** លែងលះគ្នា។ តាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៤

**ចៅក្រម**

ហត្ថលេខា និងត្រា **សេខ នាខ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

**ចៅក្រម**

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង............**

-សំណុំរឿងរដ្ឋប្បវេណីលេខ ...........
ចុះថ្ងៃទី........ ខែ........ឆ្នាំ........
-សញ្ញាណរឿងក្តី : បណ្តឹងសុំលែងលះប្តី
-សាលក្រមរដ្ឋប្បវេណីលេខ : .........
ចុះថ្ងៃទី........ ខែ........ឆ្នាំ........

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង...........

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។
-បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។
-បានប្រកាសសាលក្រម នៅថ្ងៃទី..... ខែ...... ឆ្នាំ..... ។

### ចៅក្រមជំនុំជម្រះ

លោក .......................... **ចៅក្រម** សាលាដំបូង...........................

### ក្រឡាបញ្ជី

លោក .......................... **ក្រឡាបញ្ជី** សាលាដំបូង.......................

-ដើមចោទឈ្មោះ .................ភេទ...... កើតនៅថ្ងៃទី...... ខែ........ ឆ្នាំ...... ជនជាតិខ្មែរ មុខរបរ .............. ទីលំនៅសព្វថ្ងៃនៅភូមិ........... សង្កាត់ ........... ក្រុង........... ខេត្ត........... ។

-ចុងចម្លើយឈ្មោះ .................ភេទ...... កើតនៅថ្ងៃទី...... ខែ........ ឆ្នាំ...... ជនជាតិខ្មែរ មុខរបរ .............. ទីលំនៅសព្វថ្ងៃនៅភូមិ........... សង្កាត់ ........... ក្រុង........... ខេត្ត........... ។

### អង្គហេតុ និងចំណុចវិវាទ

I-**ការទាមទាររបស់ដើមចោទ**

**+ដើមចោទបានប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រមសម្រេច :**

**១-**សុំលែងលះពីចុងចម្លើយឈ្មោះ ........... ។

**២-**សុំមានអំណាចមេបាលើកូនប្រុសឈ្មោះ ........... ។

**៣-**សុំឱ្យចុងចម្លើយផ្តល់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។

II-**ការអះអាងរបស់គូភាគី :**

**ក/-ការអះអាងរបស់ដើមចោទ**

ដើមចោទឈ្មោះ ...........បានធ្វើសេចក្តីថ្លែងការណ៍ថា :

**ខ/-ការអះអាងរបស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ ............ បានធ្វើសេចក្តីថ្លែងការណ៍ថា :

III -**ចំណុចវិវាទ**

-..........................................................................................................................។

**<u>សំអាងហេតុ</u> :**

**តាមលទ្ធផលនៃការសាកសួរសោម៉ីភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា :**

១-.........................................................................................................................។

២-.........................................................................................................................។

៣-.........................................................................................................................។

៤-.........................................................................................................................។

៥-.........................................................................................................................។

៦-.........................................................................................................................។

៧-.........................................................................................................................។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

I-ឱ្យដើមចោទឈ្មោះ ................. លែងលះគ្នាពីចុងចម្លើយឈ្មោះ ..............ចាប់ពីពេលនេះតទៅ។

II-ឱ្យដើមចោទឈ្មោះ .................. ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ......................... ភេទ......កើតនៅថ្ងៃទី......ខែ...... ឆ្នាំ......។

III-ឱ្យចុងចម្លើយឈ្មោះ ..................ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាព។

IV-ឱ្យចុងចម្លើយឈ្មោះ ........................... ទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី តាមមាត្រា **៦៤** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** ......

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

............ ថ្ងៃទ...... ខែ...... ឆ្នា......

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**